

WWF

# ផ្ដៅ
# នៅកម្ពុជា

រៀបរៀងដោយ ឃូ អៀងហួត

ម.ឯ.ឯ.ក AIDOC
Code: 171-002
Date:
Donated by:

# ឆ្នៅ
# នៅកម្ពុជា

រៀបរៀងដោយ យូ អៀងហួត

ភាគ ១

# អារម្ភកថា

ផ្តៅ គឺជាអនុផលព្រៃឈើដ៏សំខាន់មួយក្នុងចំណោមអនុផលព្រៃឈើផ្សេងៗទៀត ដែលអាចជួយបង្កើនជីវភាពរស់នៅរបស់ប្រជាជនដូចជា ប្រភពប្រាក់ចំណូល ចំណីអាហារ និងលើកតម្កើនដល់សេដ្ឋកិច្ចជាតិ តាមរយៈសិប្បកម្មតម្បាញ និងគ្រឿងសង្ហារឹម។ រហូតមកដល់បច្ចុប្បន្ននេះ ផ្តៅនៅក្នុងប្រទេសកម្ពុជាមានចំនួន ២០ប្រភេទ ហើយប្រភេទភាគច្រើនត្រូវបានសហគមន៍ប្រមូលដើម្បីប្រើប្រាស់ប្រចាំថ្ងៃ និងផ្គត់ផ្គង់ដល់សិប្បកម្មកែច្នៃផ្តៅ។

ធនធានផ្តៅនៅកម្ពុជាកំពុងថយចុះដោយសារការប្រមូលផលដ៏លើសលប់ និងការបាត់បង់ស្ថានប្រព័ន្ធព្រៃឈើ នោះចាំបាច់ត្រូវមានតម្រូវការបន្ទាន់មួយដើម្បីបញ្ឈប់និន្នាការនេះ និងរិះរកគ្រប់មធ្យោបាយដើម្បីអភិរក្សជីវចម្រុះនេះដែលដើរតួនាទីសំខាន់ដល់សេដ្ឋកិច្ចជាតិ។

សៀវភៅនេះជាជំហ៊ានមួយឆ្ពោះទៅរកការគ្រប់គ្រងធនធានផ្តៅប្រកបដោយនិរន្តរភាពព្រោះវាបង្ហាញនូវប្រភេទផ្តៅ និងរបាយរបស់វា។ នេះ គឺជាការសិក្សាអំពីផ្តៅលើកដំបូងបង្អស់នៅក្នុងប្រទេសកម្ពុជា និងអាចធ្វើជាឯកសារបង្អែក។ ខ្ញុំសូមសំដែងនូវសេចក្តីអំណរគុណដ៏ស្មោះស្ម័គ្រដល់លោក យូ អៀងហួត រុក្ខវិទូជាន់ខ្ពស់ បម្រើការងារអោយអង្គការ WWF ដែលបានចំណាយរយៈពេល២ឆ្នាំចុងក្រោយ ដើម្បីចងក្រងសៀវភៅផ្តៅនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់បណ្ឌិត Tom Evans ទីប្រឹក្សាបច្ចេកទេសផ្នែកគ្រប់គ្រងធនធានធម្មជាតិរបស់អង្គការសង្គមអភិរក្សសត្វព្រៃនៅកម្ពុជា លោកបណ្ឌិត Andrew Henderson មកពីវិទ្យាស្ថានរុក្ខប្រព័ន្ធនៃស្ថាប័នសួនរុក្ខជាតិញូវយ៉ក លោកបណ្ឌិត Maxwell មកពីតិណាល័យឈៀងម៉ៃ នាយកដ្ឋានជីវសាស្ត្រ មហាវិទ្យាល័យវិទ្យាសាស្ត្រ សាកលវិទ្យាល័យឈៀងម៉ៃប្រទេសថៃ ដែលបានផ្តល់ការណែនាំ និងគាំទ្រផ្នែកបច្ចេកទេសដល់លោករហូត។

ចុងបញ្ចប់ ខ្ញុំសូមលើកទឹកចិត្តដល់មិត្តអ្នកអានឯកសារនេះទាំងអស់អោយចូលរួមវិភាគទានដល់ការកែលម្អ និងធ្វើអោយប្រសើរឡើង និងចែករំលែកព័ត៌មាននេះទៅអ្នកដទៃទៀតដែលអាចប្រើប្រាស់ព័ត៌មាននេះបាន។

**លោក សេង ទៀក**

នាយកអង្គការ WWF

# មាតិកា

នំព័រ


អារម្ភកថា

សេចក្តីថ្លែងអំណរគុណ

1- សេចក្តីផ្តើម ............................................. ១

2- របៀបអានសៀវភៅ ............................................. ១

3- ផ្តៅនៅប្រទេសកម្ពុជា ............................................. ២

4- ការប្រើប្រាស់ ............................................. ៣

5- អេកូឡូស៊ី និងទីជម្រករបស់ផ្តៅ ............................................. ៣

6- លក្ខណៈរូបសាស្ត្រផ្តៅ ............................................. ៤

6.1 ទិដ្ឋភាពដើម ............................................. ៥

6.2 ដើមផ្តៅ ............................................. ៥

6.3 ស្រទបស្លឹក ............................................. ៦

6.4 ស្លឹក និងកូនស្លឹក ............................................. ៨

6.5 ដៃតោង ............................................. ១០

6.6 កញ្ចុំផ្កា ............................................. ១១

6.7 ផ្កា ............................................. ១២

6.8 ផ្លែ ............................................. ១៣

7- ការប្រមូលសំណាក ............................................. ១៥

7.1 វិធីសាស្ត្រប្រមូលសំណាក ............................................. ១៥

7.2 ការកត់ត្រាសំណាក ............................................. ១៦

7.3 ការថែរក្សា និងការសំងួត ............................................. ១៦

8- ឈ្មោះក្នុងតំបន់ ............................................. ១៦

9- គន្លឹះធ្វើអត្តសញ្ញាណផ្តៅ ............................................. ២០

9.1 Calamus L. ............................................. ២១

9.2 Daemonorops Bl. ............................................. ៤៧

9.3 Korthalsia Bl. ............................................. ៥០

9.4 Myrialepis Becc. ............................................. ៥៣

9.5 Plectocomia Mart. ex Bl. ............................................. ៥៦

9.6 Plectocomiopsis Becc. ............................................. ៦២

តារាងបញ្ជីផ្តៅនៅកម្ពុជា និងសេចក្តីសង្ខេបអំពីភាពសម្បូរ និងរបាយ ............................................. ១៨

បច្ចេកស័ព្ទ ............................................. ៦៥

ឯកសារយោង ............................................. ៦៦

បញ្ជីប្រភេទផ្តៅ ............................................. ៦៧

សំណាកដែលបានសិក្សា ............................................. ៦៧

# សេចក្ដីថ្លែងអំណរគុណ

ឯកសារនេះចងក្រងដោយ លោក ឃូ អៀងហួត ធ្វើការនៅក្រសួងបរិស្ថាន ដោយមានការឧបត្ថម្ភ និងជំនួយផ្នែកបច្ចេកទេសពីលោកបណ្ឌិត Tom Evans ទីប្រឹក្សាបច្ចេកទេសផ្នែកគ្រប់គ្រងធនធានធម្មជាតិរបស់អង្គការសង្គមអភិរក្សសត្វព្រៃ បណ្ឌិត Andrew Henderson អ្នកគ្រប់គ្រងតិណាល័យនៅវិទ្យាស្ថានរុក្ខប្រព័ន្ធសួនរុក្ខជាតិញូវយ៉ក និងបណ្ឌិត J. F. Maxwell បម្រើការងារនៅតិណាល័យស៊ីអឹមយូនៃនាយកដ្ឋានជីវវិទ្យា មហាវិទ្យាល័យវិទ្យាសាស្ត្រ របស់សាកលវិទ្យាល័យឈៀងម៉ៃ។

កូនសៀវភៅនេះរៀបរៀងឡើង ដោយផ្អែកលើសំណាកផ្តៅដែលរក្សាទុកនៅស្នាក់ការរបស់អង្គការមូលនិធិដើម្បីអភិរក្សធម្មជាតិនៅកម្ពុជា WWF-Cambodia និងឯកសារចាស់ៗ និងផ្តល់ចំណេះដឹងអំពីពួក និងប្រភេទចម្រុះដែលមាននៅក្នុងប្រទេសកម្ពុជា។ ប្រភេទផ្តៅនៅកម្ពុជាមានចំនួនតិច បើប្រៀបធៀបទៅនឹងចំនួនប្រភេទផ្តៅទាំងអស់( មានតែ២០ប្រភេទនិងពួកចំនួន៦ ក្នុងចំណោម៦០០ប្រភេទនិងពួកចំនួន១២ ដែលបានស្គាល់នៅទូទាំងពិភពលោក)។ ដូចនេះ ប្រភេទផ្តៅដែលបានពណ៌នានៅក្នុងកូនសៀវភៅនេះមិនអាចតំណាងអោយគ្រប់លក្ខណៈរូបរាងរបស់ពួកទាំងនេះទេ។ ក្នុងស្ថានភាពនេះ ការពណ៌នាអំពីពួកនីមួយៗបានចម្លងចេញពីសៀវភៅផ្តៅឧបទ្វីបម៉ាឡេស៊ី (Dransfield,J., ១៩៧៩)។ លើសពីនេះទៀត សំណាកផ្តៅជាច្រើនពុំមានកញ្ចុំផ្កា និងផ្លែ។ ដូចនេះ ព័ត៌មានខ្លះអំពីផ្កា និងផ្លែបានចម្លងចេញពីឯកសារផ្តៅនៅ ប្រទេសឡាវ ឯកសារស្តីពីរុក្ខជាតិឥណ្ឌូចិន និងឯកសារផ្តៅនៅសាបា(Dransfield,J., ១៩៨៤)។ ការពណ៌នាអំពីផ្នែកលូតលាស់ដូចជា ស្រទបស្លឹក ដៃតោង និងស្លឹក យកចេញពីឯកសារផ្តៅនៅប្រទេស ឡាវ (Evans, T. et al., ២០០២). ប្រភេទទាំងនេះភាគច្រើនក៏មាននៅក្នុងប្រទេសឡាវ វៀតណាម និងថៃផងដែរ តែមានប្រភេទតិចតួចប៉ុណ្ណោះមានវត្តមាននៅតំបន់ម៉ាឡេ។

ការរួមវិភាគទានផ្នែកបច្ចេកទេស

អ្នកកែសម្រួល : លោក គ្រីស គ្រិនរ៉ូដ / អ្នកស្រី មេរីល ហាឡេ

វិចិត្រករ : លោក ខាត់ ពុធមករា / បាន់សា ថាម៉ាវង្ស

ផែនទីអំពីរបាយផ្តៅ : លោក ហ៊ុយ គារុំធ

អ្នកផ្តល់យោបល់កែលំអ និងប្រឹក្សា : លោក ធីបុល ឡេដិច / លោក ទេព អស្នារិទ្ធិ

អ្នករួមវិភាគទានកែសម្រួលភាសាខ្មែរ : សាស្ត្រាចារ្យ យក់ លីន / លោក ឆាង ភូរិន្ទ និងលោក អ៊ូ រតនៈ

ការកំណត់ឈ្មោះតំបន់ភូមិសាស្ត្រនៅក្នុងឯកសារនេះ និងការបង្ហាញព័ត៌មាននានា មិនមានន័យថាជាការសំដែងយោបល់ណាមួយរបស់អ្នកនិពន្ធ ឬអង្គការ WWF ដែលទាក់ទងនឹងស្ថានភាពចំពោះមុខច្បាប់នៃប្រទេស ដែនដី តំបន់ ឬសមត្ថកិច្ច ឬការទាក់ទងនឹងការកំណត់ព្រំដែន និងព្រំប្រទល់ប្រទេសនានាឡើយ ។

WWF មិនទទួលខុសត្រូវរាល់ការបកស្រាយខុសណាមួយនៅក្នុងឯកសារនេះ ដែលអាចបណ្តាលមកពីការបកប្រែឯកសារនេះទៅជាភាសាផ្សេងៗទៀត ។

ការបោះពុម្ពឡើងវិញនៅក្នុងផ្នែកណាមួយរបស់ឯកសារនេះ( មិនរួមបញ្ចូលរូបថត) សម្រាប់ការអប់រំ ការអភិរក្ស និងគោលបំណងមិនរកប្រាក់ចំណេញផ្សេងៗ ត្រូវផ្តល់សិទ្ធិដោយមិនចាំបាច់ផ្តល់ការអនុញ្ញាតជាមុនពីម្ចាស់កម្មសិទ្ធិបញ្ញា ដោយគ្រាន់តែធ្វើសេចក្តីយោងពេញលេញដល់ឯកសារនេះ ។

រូបភាពដែលមាននៅក្នុងឯកសារនេះមិនត្រូវយកមកបោះពុម្ពឡើងវិញ ដោយមិនមានការអនុញ្ញាតពីអ្នកបោះពុម្ពឡើយ ។ ការផលិតឯកសារនេះឡើងវិញដើម្បីលក់បន្ត ឬគោលបំណងពាណិជ្ជកម្មផ្សេងៗ ត្រូវហាមឃាត់ដោយពុំមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិបញ្ញា ។

សំណើសម្រាប់ការចុះសេចក្តីយោង: WWF ២០១០ សៀវភៅផ្តៅនៅកម្ពុជា ។ល ។ (?) អ្នកនិពន្ធ: ឯកសារ ។ WWF មហាតំបន់មេគង្គ កម្មវិធីអភិរក្សនៅកម្ពុជា ។

រូបថតទាំងអស់ ថតដោយលោក ឃួ អៀងហួត លើកលែងរូបថតលេខ៥ ក្នុងទំព័រ ៦១ ថតដោយបណ្ឌិត កុយ រ៉ា ។

រៀបចំទំព័រក្នុងកុំព្យូទ័រដោយ: 3Q Color Seperation

កែសម្រួលការរៀបចំទំព័រក្នុងកុំព្យូទ័រដោយ : អេង ម៉េងអ៊ី អង្គការ WWF កម្ពុជា

សម្របសម្រួលការបោះពុម្ពដោយ : លោក លី សារ៉េត និង អេង ម៉េងអ៊ី អង្គការ WWF កម្ពុជា

បោះពុម្ពដោយ :

ឯកសារនេះមាននៅស្នាក់ការ WWF មហាតំបន់មេគង្គ កម្មវិធីអភិរក្សនៅកម្ពុជា

ផ្ទះលេខ៥៤ ផ្លូវលេខ៣៥២ សង្កាត់បឹងកេងកង១ កម្ពុជា

ទូរស័ព្ទលេខ (៨៥៥) ២៣ ២១៨ ០៣៤    ទូរសារលេខ (៨៥៥)២៣ ២១១ ៩០៩

អ៊ីម៉ែល: **wwfcambodia@wwfgreatermekong.org**

បោះពុម្ពក្នុងឆ្នាំ ២០១០ ដោយអង្គការ WWF មហាតំបន់មេគង្គ កម្មវិធីអភិរក្សនៅកម្ពុជា ការបោះពុម្ពសារឡើងវិញទាំងស្រុង ឬដោយផ្នែករបស់ឯកសារនេះត្រូវដាក់ចំណងជើង និងសេចក្តីយោងអ្នកបោះពុម្ពដែលបានលើកឡើងខាងលើជាម្ចាស់កម្មសិទ្ធបញ្ញា ។

អត្ថបទឆ្នាំ ២០១០ រក្សាសិទ្ធិគ្រប់បែបយ៉ាង រូបភាពគម្របខាងមុខ និង ខាងក្រោយ ។

## ១. សេចក្តីផ្តើម

យើងទាំងអស់គ្នាស្គាល់ផ្កៅ តាមរយៈផលិតផលសម្រេចដូចជា កៅអី តុ និងធ្នើរជាដើម ប៉ុន្តែមានមនុស្សតិចតួចណាស់ដែលស្គាល់ដើមវាពិតប្រាកដនៅក្នុងព្រៃ ឬថាតើវាមានប៉ុន្មានប្រភេទនៅក្នុងប្រទេសកម្ពុជា ?

ដើម្បីបំពេញនូវកង្វះខាតចំណេះដឹងនេះ WWF មហាតំបន់ទន្លេមេគង្គ តាមរយៈគម្រោងប្រមូលផលនិងផលិតកម្មផ្តៅប្រកបដោយនិរន្តរភាព បានចងក្រងសៀវភៅមគ្គុទេសផ្តៅលើកទីមួយនៅក្នុងប្រទេសកម្ពុជា។

គោលបំណងរបស់សៀវភៅមគ្គុទេសផ្តៅនេះ គឺដើម្បីបង្ហាញប្រភេទផ្តៅនៅប្រទេសកម្ពុជា និងដើម្បីជួយដល់ការធ្វើអត្តសញ្ញាណផ្តៅ ។ ប្រភេទផ្តៅត្រូវបានគេប្រើប្រាស់ច្រើនយ៉ាងសម្រាប់គ្រឿងតម្បាញ គ្រឿងសង្ហារឹម និងម្ហូបអាហារ។ ការសិក្សាអំពីប្រភេទផ្តៅនៅក្នុងប្រទេសកម្ពុជា ពុំធ្លាប់បានធ្វើក្នុងទ្រង់ទ្រាយធំទេ។ ការខ្វះខាតចំណេះដឹងផ្នែករុក្ខវិទ្យា (ឈ្មោះប្រភេទ) គឺជាឧបសគ្គដ៏ចម្បងមួយនៅក្នុងការងារអភិវឌ្ឍន៍ឧស្សាហកម្មផ្តៅ ជាពិសេសការជ្រើសរើសប្រភេទត្រឹមត្រូវសម្រាប់ការកែច្នៃ និងធ្វើពាណិជ្ជកម្ម ។

ដើម្បីជម្នះផលលំបាក សៀវភៅនេះបានចងក្រងប្រភេទផ្តៅចម្រុះ ទីជម្រក អេកូឡូស៊ី និងផ្តល់ព័ត៌មានបន្ថែមទៀតអំពីការប្រើប្រាស់ផ្តៅ ការលួតលាស់ និងការធ្វើពាណិជ្ជកម្ម។

## ២. របៀបអានសៀវភៅ

សៀវភៅនេះមានបីផ្នែកធំៗ ដោយសារតែលក្ខណៈរូបសាស្ត្ររបស់ផ្តៅខុសប្លែកពីរុក្ខជាតិដ៏ទៃទៀត ពាក្យវិទ្យាសាស្ត្ររបស់វាក៏ខុសប្លែកគ្នាដែរ។ ដូច្នេះ ផ្នែកទីមួយនៅក្នុងសៀវភៅនេះ ផ្តល់ព័ត៌មានជារួមអំពីផ្តៅ ចំណែកឯផ្នែកទីពីរ លម្អិតលក្ខណៈរូបរាងរបស់ផ្តៅ និងផ្នែកចុងក្រោយបង្អស់ គឺពណ៌នាលម្អិតអំពីលក្ខណៈរូបរាងរបស់ផ្តៅចំនួន ១៨ប្រភេទក្នុងចំណោម ២០ប្រភេទនៅក្នុងប្រទសកម្ពុជា។ អ្នកដែលមានបំណងទទួលនូវចំណេះដឹងអំពីផ្តៅតែមិនទាន់យល់ច្បាស់អំពីវា គួរតែមើលលក្ខណៈរូបរាងរបស់វាសិន ហើយបន្ទាប់មកចាប់ផ្តើមមើលគន្លឹះការធ្វើអត្តសញ្ញាណកម្មអំពីពួក និងប្រភេទដើម្បីដឹងថាតើវាខុសប្លែកគ្នា ឬស្រដៀងគ្នាប៉ុនណា បើយោងទៅតាមលក្ខណៈរូបរាងពិសេស ឬរូបរាងទូទៅ។ បន្ទាប់ពីគន្លឹះការធ្វើអត្តសញ្ញាណកម្ម ការពិពណ៌នាលម្អិតដែលរួមមានពីរផ្នែក គឺការពណ៌នាអំពីលក្ខណៈរូបរាងរបស់វា និងលក្ខណៈសំគាល់ពិសេស។ ការពិពណ៌នាលម្អិតអំពីលក្ខណៈរូបសាស្ត្ររបស់វាផ្តល់ព័ត៌មានអំពីលក្ខណៈរូបរាងលម្អិតរបស់ប្រភេទនីមួយៗ ហើយលក្ខណៈសំគាល់ពិសេសប្រាប់តែលក្ខណៈរូបរាងពិសេស ដែលញែកប្រភេទពីរស្រដៀងគ្នាដាច់ចេញពីគ្នា។

ការពណ៌នាផ្នែករុក្ខវិទ្យាផ្តល់ព័ត៌មានលម្អិត អំពីលក្ខណៈរូបរាងផ្តៅដែលរួមមាន ទិដ្ឋភាពដើម ទំហំរូបរាង ពណ៌ វាយនភាព និងការតម្រៀបន្លា។ ការកត់សំគាល់នៅទីវាល ប្រាប់លក្ខណៈរូបរាងសំខាន់ពិសេស

ដែលជួយក្នុងការធ្វើអត្តសញ្ញាណកម្មប្រភេទផ្តៅបានយ៉ាងរហ័ស និងញែកប្រភេទស្រដៀងគ្នា។ រូបភាពពណ៌របស់ប្រភេទនីមួយៗ ជួយសម្រួលដល់ការធ្វើអត្តសញ្ញាណកម្មផ្តៅបានយ៉ាងលឿន ។

## ៣. ផ្តៅនៅក្នុងប្រទេសកម្ពុជា

ការសិក្សាស្រាវជ្រាវប្រភេទផ្តៅនៅកម្ពុជារហូតមកដល់បច្ចុប្បន្ននេះ បានចងក្រងឯកសារផ្តៅចំនួន ១៨ប្រភេទនៅទូទាំងប្រទេស ។ ផ្តៅចំនួន ២ប្រភេទទៀតដែលមិនបានពណ៌នាលម្អិតក្នុងសៀវភៅមគ្គុទេសនេះ តែបានដាក់បញ្ចូលនៅក្នុងតារាងគឺ *Calamusa canthophyllus* ដែលបានកត់ត្រានៅក្នុងខេត្តព្រះវិហារ (កត់ត្រាដោយបណ្ឌិត Evans, T.) និងប្រភេទដើមត្រង់ដែលបានរកឃើញនៅកំពូលភ្នំខ្មោច និងភ្នំសំកុសក្នុងដែនជម្រកសត្វព្រៃភ្នំសំកុស និងភ្នំធំក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ (កត់ត្រាដោយ លោក ឃូ អៀងហួត) ។ គេរំពឹងទុកថាផ្តៅអាចមានចំនួនរហូតដល់ជាង៣០ប្រភេទ(បណ្ឌិត Evans,T.) បើសិនជាមានការសិក្សាស្រាវជ្រាវបន្ថែមទៀត និងមានការសិក្សាពីលក្ខណៈរូបរាងប្រកបដោយការប្រុងប្រយ័ត្ន ។

គេចាត់ទុកផ្តៅ ថាជាអនុផលព្រៃឈើដែលមានសក្តានុពលយ៉ាងធំធេង ក្នុងការរួមចំណែកដល់ការអភិវឌ្ឍន៍ជីវភាពរស់នៅតាមជនបទក្នុងប្រទេសកម្ពុជា និងដល់សេដ្ឋកិច្ចជាតិ តាមរយៈការកែច្នៃនៅក្នុងប្រទេស ។ ទោះបីផ្តៅជាប្រភេទអនុផលព្រៃឈើមួយដែលមានសារៈសំខាន់ដល់សហគមន៍ជនបទក៏ដោយ គេពុំទាន់ប្រមូលផលវាប្រកបដោយនិរន្តរភាពនៅឡើយទេ ហើយបរិមាណរបស់វាបានថយចុះនៅទូទាំងប្រទេស ។

យោងតាមការសិក្សាស្រាវជ្រាវទូទាំងប្រទេស ដោយអង្គការ WWF (លោក វុឌ្ឍី និង ហួត ២០០៦) ការគម្រាមកំហែងផ្តៅចម្បង៧គឺ ការប្រមូលផលលើសលប់ ការបំផ្លិចបំផ្លាញព្រៃឈើ តាមរូបភាពរានដីព្រៃ និងភ្លើងឆេះព្រៃញឹកញាប់ ។

ការថយចុះធនធានផ្តៅប៉ះពាល់ដល់ជីវភាពរស់នៅរបស់សហគមន៍នៅតាមតំបន់ព្រៃ និងជីវចម្រុះក្នុងប្រទេសកម្ពុជា ។ បច្ចុប្បន្ននេះ ការប្រមូលផលផ្តៅមិនទទួលបានការត្រួតពិនិត្យអោយបានគ្រប់ជ្រុងជ្រោយទេ ហើយពុំមានការដាំដុះឡើងវិញឡើយ ។ កត្តាទាំងនេះថែមទាំងធ្វើអោយកាន់តែពិបាកថែមទៀតក្នុងការធានាអោយមានការផ្គត់ផ្គង់ធនធានផ្តៅជាប្រចាំ (មិនថាតែវត្ថុធាតុដើមផ្តៅ ផ្តៅកែច្នៃហើយ និងផលិតផលសម្រេចទេ) ដល់ជីវភាពសហគមន៍ ទីផ្សារ និងការធ្វើពាណិជ្ជកម្ម ។ បច្ចុប្បន្ននេះ ជំនាញ និងបច្ចេកទេសកែច្នៃផ្តៅ និងការអភិវឌ្ឍន៍ផលិតផលពុំទាន់មានការរីកចម្រើននៅឡើយទេ ដូច្នេះធ្វើអោយទីផ្សាររបស់វានៅមានកម្រិតសម្រាប់សហគមន៍ជនបទដែលអាស្រ័យលើធនធានព្រៃឈើដើម្បីជីវភាពរស់នៅរបស់ពួកគេ។

លើសពីនេះទៀត ដោយសារតែកង្វះខាតការគាំទ្រផ្នែកគោលនយោបាយ ហើយនឹងទីផ្សារវត្ថុធាតុដើមផ្ដៅនៅក្នុងប្រទេសកម្ពុជាមានតម្លៃទាប ជាហេតុបណ្ដាលអោយផ្ដៅភាគច្រើនដឹកយកទៅលក់អោយប្រទេសជិតខាង ជាជាងការលក់ក្នុងប្រទេស ឬនាំចេញក្នុងទ្រង់ទ្រាយធំ។ ផលិតផលកែច្នៃ និងផលិតផលសម្រេចអំពីផ្ដៅ (ឧ.ទា. គ្រឿងតម្បាញ និងគ្រឿងសង្ហារិម ។ល។) ត្រូវបានផលិត និងលក់ចែកចាយទៅអោយអ្នកទិញនៅក្នុងស្រុក។ ជារួមផលិតផលកែច្នៃ និងផលិតផលសម្រេចទាំងនេះមិនមានគុណភាពគ្រប់គ្រាន់សម្រាប់ការនាំចេញទេ។

## ៤. ការប្រើប្រាស់

សហគមន៍មូលដ្ឋាន បានប្រើប្រាស់ផ្ដៅជាច្រើនសតវត្សមកហើយសម្រាប់ធ្វើជាអាហារ គ្រឿងសំណង់ ឱសថបុរាណ និងគ្រឿងសង្ហារិម។ គមផ្ដៅច្រើនប្រភេទក្នុងពួក*Calamus* និងផ្ដៅសោមអាចហូបបាន ហើយសហគមន៍ក្នុងតំបន់ព្រៃចូលចិត្តហូបណាស់។ គមវាជាទូទៅចត់បន្តិច និងផ្អែមបន្តិច។ សហគមន៍តំបន់ព្រៃក្នុងខេត្តកំពង់ធំក៏ប្រមូលដួងដែលរស់នៅក្នុងគមផ្ដៅសោមដើម្បីលក់ផងដែរ ដួងមួយមានតម្លៃ ១៥០០រៀល (០.៣៥ ដុល្លាអាមេរិក)។ ស្លឹកផ្ដៅសោម និងផ្ដៅដំបងត្រូវបានគេប្រើប្រាស់សម្រាប់ប្រកផ្ទះនៅតាមសហគមន៍តំបន់ព្រៃមួយចំនួន។ ឫសប្រភេទផ្ដៅខ្លះដូចជារពាក់ គេប្រើធ្វើជាឱសថបុរាណផងដែរ។

ផ្ដៅ គេប្រើប្រាស់សម្រាប់ធ្វើផលិតផលផ្សេងៗ រាប់ពីឧបករណ៍ប្រើប្រាស់នៅតាមផ្ទះ រហូតដល់ធ្វើគ្រឿងសង្ហារិម។ ជាទូទៅ ដើមផ្ដៅតូចៗត្រូវបានគេប្រើប្រាស់ជាខ្សែចំណង និងតម្បាញ និងផលិតពពួកល្អីច្រើនប្រភេទ។ ផ្ដៅដើមធំមធ្យម និងដើមធំៗដូចជា ផ្ដៅសោម ព្រះផ្ដៅ និងផ្ដៅដំបង គេប្រើសម្រាប់ធ្វើស៊ុម(ឆ្អឹង/គ្រោង) និងគ្រឿងសង្ហារិមដូចជា កៅអី សាឡុង គ្រែ និងទូសំលៀកបំពាក់ជាដើម។

## ៥. អេកូឡូស៊ី និងជីវសាស្ត្ររបស់ផ្ដៅ

ប្រភេទផ្ដៅភាគច្រើនដុះលូតលាស់នៅក្នុងព្រៃដោយតោងឡើងរុក្ខជាតិផ្សេងៗ ដោយដៃតោងដែលមានបន្លារាងកោង។ កូនសំណាប ដុះលូតលាស់ល្អក្នុងលំហគម្របព្រៃដែលពន្លឺថ្ងៃអាចចាំងចូលដល់ស្រទាប់ដី។ ដើមផ្ដៅដុះលូតលាស់យឺតនៅពេលវានៅជាកូនសំណាប ប៉ុន្តែដុះលូតលាស់លឿនឡើងៗនៅពេលវាធំពេញវ័យ។

ប្រភេទផ្ដៅខុសៗគ្នា ដុះលូតលាស់ល្អនៅក្រោមលក្ខខណ្ឌកំដៅ ពន្លឺ និងប្រភេទដីខុសៗគ្នា ដូច្នេះហើយទើបប្រភេទមួយចំនួនដុះនៅក្នុងប្រភេទព្រៃខុសៗគ្នា។ ឧ.ទា. ផ្ដៅទឹក (*Calamus siamensis*) និងផ្ដៅដំបង(*Calamus rudentum*) ជាទូទៅដុះនៅតាមមាត់ច្រាំងស្ទឹង/ទន្លេ ឬនៅតាមតំបន់ផ្សេងៗទៀត ដែលលិចទឹកក្នុងរយៈពេលខ្លីៗ ចំណែកផ្ដៅទឹក(*Calamus godefroyi*)ដុះនៅតាមទំនាបលិចទឹកដែលអាចធន់នឹងទឹកលិច

បានច្រើនខែ។ មានប្រភេទជាច្រើនដុះនៅក្នុងព្រៃស្រោង ចំពោះផ្តៅក្រែកសម្បូរដុះនៅក្នុងព្រៃឈ្មោះចម្រុះ និងព្រៃឈ្មោះឱបតេរ៉ូកាប។ ប្រភេទផ្តៅ *Calamus acanthophyllus* គ្មានដើម រកឃើញនៅក្នុងព្រៃឈ្មោះផ្លែស្លាបដែរ។

មានតែប្រភេទទាំងពីរនេះទេ ដែលទំនងជាធន់ទៅនឹងភ្លើងព្រៃដែលកើតមានជាញឹកញាប់នៅរដូវប្រាំង។ រពាក់ រាប់ចូលក្នុងប្រភេទផ្តៅមួយពិសេសក្នុងប្រទេសកម្ពុជាដែលដុះនៅក្រៅតំបន់ព្រៃ។ វាមានសម្បូរដុះនៅតាមវាលស្មៅធម្មជាតិ តាមភ្លឺស្រែ ចិញ្ចើមផ្លូវ និងតាមគម្ពោតព្រៃទំនាបៗ។

ផ្លែផ្តៅមានសំបករាងដូចស្រកាហើយគ្រាប់ផ្តៅមានសាច់ព័ទ្ធជុំវិញ (sarcotesta)។ សាច់ផ្លែផ្តៅរបស់ប្រភេទមួយចំនួនមានរសជាតិជូរឯម ដែលធ្វើអោយសត្វស្លាប ថនិកសត្វ និងមនុស្សចូលចិត្តហូប។ គ្រាប់ផ្តៅពិបាកដុះណាស់ បើសិនជាសាច់មិនរបេះចេញពីគ្រាប់។ សត្វ មានតួនាទីសំខាន់ណាស់ក្នុងការរំលាយសាច់ចេញពីគ្រាប់តាមរយៈការលេបផ្លែចូលទៅក្នុងពោះ ហើយបញ្ចេញគ្រាប់មកក្រៅ និងពង្រាយគ្រាប់ទាំងនេះតាមលាមករបស់វា។

## ៦. លក្ខណៈរូបសាស្ត្ររបស់ដើមផ្តៅ

រូបរាងរបស់ផ្តៅអាចចែកចេញជាពីរផ្នែកធំៗ។ **ផ្នែកលូតលាស់** រួមមាន ឬស ដើម ស្រទបស្លឹក ស្លឹក ដៃតោង និងបន្លា។ ផ្នែកទាំងនេះ មានសារៈសំខាន់ណាស់ដល់ការធ្វើអត្តសញ្ញាណផ្តៅត្រឹមពួករបស់វា ហើយអាចស្គាល់ដល់ប្រភេទមួយចំនួន។ **ផ្នែកបន្តពូជ** (មានកញ្ចុំផ្កា ផ្កា និងផ្លែ) សម្រាប់ធ្វើអត្តសញ្ញាណកម្មប្រភេទ។

ដូចពួកតាលព្រឹក្សដទៃទៀតដែរ ដើមផ្តៅដុះលូតលាស់ទៅលើចេញពីចុង។ ស្លឹកដុះចេញម្តងមួយៗនៅខាងចុងដើម ហើយស្លឹកនីមួយៗមានគល់រាងជាបំពង់ ឬហៅថាស្រទបស្លឹក។ ស្រទបស្លឹកនីមួយៗបន្ទុរល់ទុកសំលាករាងរង្វង់នៅលើថ្នាំង ដែលមានចន្លោះថ្នាំងរលោងនៅសងខាង។ កញ្ចុំផ្កាបែកទង និងមានទម្រង់សាញ៉ាញ៉ាំ ហើយ ប្រភេទខ្លះកញ្ចុំផ្កាអាចមានប្រវែងច្រើនម៉ែត្រ។ ទោះបីជាកញ្ចុំផ្កាទាំងនេះដុះចេញពីថ្នាំងក៏ដោយវាជាប់ទៅនឹងស្រទបស្លឹកប៉ែកខាងក្រៅខាងលើថ្នាំង។

រូបរាងផ្តៅមានការប្រែប្រួលខ្លាំងណាស់ អាស្រ័យទៅនឹងលក្ខខណ្ឌដុះលូតលាស់ដូចជា ពន្លឺ ដី និងការបាក់បែករូបរាង។ ដូច្នេះ គួរប្រុងប្រយ័ត្នពេលហៅឈ្មោះប្រភេទ។ ស្លឹក និងស្រទបស្លឹករបស់ដើមខ្ចី អាចមានលក្ខណៈខុសពីដើមចាស់ខ្លាំងណាស់។



ដុះជាគុម្ព



ដើមទោល

## ៦.១ និស្ស័យភាពដើម

ប្រភេទផ្តៅជាច្រើននៅក្នុងប្រទេសកម្ពុជា**ដុះជាគុម្ព** គឺថាឫសមេមួយមានដើមច្រើនដែលមានវ័យខុសៗគ្នា។ ប្រភេទទាំងនេះ អាចដុះដើមថ្មី បន្ទាប់ពីកាប់ដើមចាស់។ បើសិនជាឫសមេដុះដើមតែមួយ គេហៅថា **ដើមទោល**។ ដើមទោលនីមួយៗងាប់នៅពេលគេកាប់ដែលធ្វើអោយប្រភេទនេះងាយនឹងទទួលរងនូវការប្រមូលផលលើសលប់ បើសិនជាតម្រូវការទីផ្សារប្រភេទនេះមានកម្រិតខ្ពស់។

## ៦.២ ដើមផ្តៅ

នៅពេលគេកាប់ដើមផ្តៅ ហើយសកយកស្រទបស្លឹកចេញ គេហៅថា *Cane*។ នៅក្នុងប្រទេសកម្ពុជាប្រភេទផ្តៅភាគច្រើនជាប្រភេទដើមតោងឡើង ចំណែកឯ *Calamus acanthophyllus* **មិនមានដៃតោង ឬអត់មានដើម**។ ដើមផ្តៅមិនបែកមែកទេ លើកលែងតែក្នុងពួកព្រះផ្តៅដែលបែកមែកច្រើនពេលវាតោងឡើងដល់តម្របម្លប់ដើមឈើ។ ជាលិកាខ្ចី និងទន់នៅខាងចុងដើមបង្អស់ហៅ **ត្រួយផ្តៅ**។

ដើមផ្តៅដែលនៅជាប់ស្រទបស្លឹកមានពណ៌ប្រផេះ ឬពណ៌លឿង និងមានទឹកច្រើនក្នុងសាច់ផ្តៅ ហើយនៅពេលសំងួត ដើមមានសភាពជ្រួញ និងងាយដុះផ្សិត។ ផ្នែកដើមចាស់ដែលគ្មានស្រទបស្លឹក មានពណ៌បៃតង និងរឹងមាំ មានទឹកក្នុងសាច់ផ្តៅតិច និងជាប់បានយូរ។ គ្រប់ផ្តៅទាំងអស់មានខ្សែវ័ណ្ឌជុំវិញដើម( ឧ.ទា. ថ្នាំង) ដែលជាកន្លែងជាប់ស្លឹក។



ដើមតោងឡើង



ដើមបែកមែក



ពុំមានតួដើម/ពុំមានដៃតោង

## ៦.៣ ស្រទបស្លឹក

នៅលើស្រទបស្លឹកមានចំនុចសំខាន់ចំនួនបីគឺ បន្លា ពកគល់ទងស្លឹក និងស្រកីស្រទប។ បន្លានៅលើស្រទបស្លឹកជួយការពារដើម។ ចំនួន និងការតម្រៀបបន្លាពីប្រភេទមួយទៅប្រភេទមួយទៀត និងពីដើមមួយទៅដើមមួយទៀតក្នុងប្រភេទដូចគ្នា មានការប្រែប្រួលខុសៗគ្នា។ ប្រភេទភាគច្រើនមានបន្លាច្រើនស្អេកស្កះ ដុះរាយប៉ាយពេញលើស្រទបស្លឹកទាំងមូល។ ផ្តៅ *Calamus lateralis* មានបន្លាតិចតួច ឬគ្មានសោះតែម្តងនៅលើស្រទបស្លឹក។ បន្លារបស់ដើមផ្តៅឬស្សី និងផ្តៅឬស្សីយក្សដុះតម្រៀបជាជួរ។ ប្រភេទផ្តៅខុសៗគ្នាក្នុងពួក *Calamus* ដុះបន្លាខុសៗគ្នា និងបែរមុខទៅទិសដៅផ្សេងៗគ្នា។ ប្រភេទផ្តៅជាច្រើនមានគល់បន្លារាងរមូល និងបន្លាសំប៉ែត ចំណែកឯខ្លះទៀតមានគល់បន្លារាងដូចកោន និងបន្លាដូចម្ជុល។



គ្មានបន្លា



គល់បន្លារមូលសំប៉ែត



គល់បន្លារាងកោន

បន្លាផ្តៅរបស់ប្រភេទជាច្រើនមានពណ៌បៃតងទៅពណ៌លឿង-បៃតង ប៉ុន្តែបន្លារបស់ប្រភេទមួយចំនួនតូចដូចជាផ្តៅអារ៉ែច និងរពាក់មានពណ៌ខ្មៅ។ បន្លារបស់ផ្តៅដំបងមានពណ៌ប្រផេះ ឬពណ៌ចម្បើង។



បន្លាតម្រៀបជាជួររណែន



បន្លាចង្កុរគ្រប់ទិស



បន្លាចង្កុរចុះក្រោម



បន្លាចង្កុរឡើងលើ

**ពកគល់ទងស្លឹក** មាននៅខាងលើស្រទបស្លឹករបស់ពួក *Calamus* និងផ្ដៅសោម តែពុំមានលើដើមខ្ចីរបស់ពួកទាំងនេះទេ។ វាលេចចេញរូបរាងច្បាស់ដូចក្ដោងច្រមុះ ឬមិនសូវច្បាស់នៅត្រង់គល់ទងស្លឹក។ ពកគល់ទងស្លឹកផ្ដៅខ្មែរជាច្រើន មានរូបរាងពីរខុសគ្នាដាច់ស្រឡះគឺ រាងដុំពក និងរាងទ្រនុង។ ប្រភេទក្នុងពួក *Korthalsia, Myrialepis, Plectocomia* និង *Plectocomiopsis* មិនមានពកគល់ទងស្លឹកទេ។



គ្មានពកស្រទប



ពកស្រទបរាងដុំពក



ពកស្រទបរាងទ្រនុង

**ស្រកីស្រទប** ជាផ្នែកលូតចេញបន្តពីស្រទបស្លឹកត្រង់ខាងលើចំនុចជាប់នឹងទងស្លឹក។ វាជាផ្នែកមួយសំខាន់សម្រាប់ការធ្វើអត្តសញ្ញាណកម្មផ្ដៅ។ ពួក *Korthalsia* មានបន្លាស្រកីស្រទបដូចសំណាញ់ ចំពោះប្រភេទផ្សេងទៀតមានស្រកីស្រទបស្ដើង ពុំមានបន្លា និងស្ដើងដូចសន្លឹកក្រដាស់ដែលអាចខ្ចី ឬរវែង។ ស្រកីស្រទបរបស់ប្រភេទមួយចំនួនពុកផុយហើយដាច់ៗ ដូច្នេះហើយគេអាចឃើញវាតែនៅពេលទើបចេញស្រទបស្លឹកភ្លាមៗ។ ស្រកីស្រទបរបស់ប្រភេទមួយចំនួនតូចដូចជា រពាក់ និងផ្ដៅដឹបងមានរោមទន់ ឬរឹង។



ស្រកីស្រទបតូចល្អិត



ស្រកីស្រទបលានចេញក្រៅ



ស្រកីស្រទបមានរោមរឹង



ស្រកីស្រទបវែង



ស្រកីស្រទបដូចសំណាញ់

## ៦.៤ ស្លឹក និងកូនស្លឹក

ស្លឹកផ្តៅជាស្លឹករួមមានកូនស្លឹកច្រើននៅតាមបណ្តោយទ្រនុងស្លឹក។ ស្លឹករបស់វាបែងចែកជា ស្រទបស្លឹក ទងស្លឹក កូនស្លឹក និង(ពេលខ្លះ) ដៃតោងចុងទងស្លឹក។

ទងស្លឹកគឺជាអ័ក្សមួយចេញពីមាត់ស្រទបដល់កូនស្លឹកទីមួយ។ បណ្តោយទងស្លឹកវែង ឬខ្លីទៅតាមប្រភេទ ឬដើមផ្តៅនីមួយៗ។ ទងស្លឹកមានប្រវែងវែងនៅពេលដើមផ្តៅនៅខ្ចី និងរួញខ្លីនៅពេលដើមពេញវ័យ។ ប្រភេទផ្តៅខ្លះដូចជា ផ្តៅអារ៉េច និងផ្តៅទឹកមានទងស្លឹកខ្លីមែនទែន រហូតដល់អត់មានទងស្លឹក។ នៅខាងខ្នងទងស្លឹករបស់ប្រភេទផ្តៅនីមួយៗជួនកាលមានបន្លា ជួនកាលអត់បន្លា ប៉ុន្តែផ្តៅអារ៉េចពុំមានបន្លានៅខាងខ្នងទងស្លឹកទេ។ ទ្រនុងស្លឹកជាផ្នែកមួយរបស់អ័ក្សស្លឹកដែលមានដុះកូនស្លឹក។ កូនស្លឹកដុះតម្រៀបតាមរបៀបផ្សេងៗទៅតាមប្រភេទមួយៗ ដូច្នេះវាជារូបរាងពិសេសមួយទៀតសម្រាប់ការធ្វើអត្តសញ្ញាណ។ ប្រភេទផ្តៅខ្មែរ កូនស្លឹកតម្រៀបជាជួរឈមស្មើៗគ្នា ឈមដាច់ៗជាក្រុម និងមិនត្រង់ជួរគ្នា។ ប្រភេទខ្លះ កូនស្លឹកតម្រៀបខុសៗគ្នា។ ឧ.ទា. ផ្តៅទឹកកូនស្លឹក

តម្រៀបឈមស្មើៗគ្នាផង ឈមដាច់ៗគ្នាផង ហើយផ្តៅឬស្សី កូនស្លឹកតម្រៀបជាក្រុមផង តម្រៀបឈមផង។

កូនស្លឹកអាចមានរាងដូចពេជ្រ រាងទ្រវែង ឬមានរាងប្រែប្រួលពីដូចផ្លែលំពែងរហូតដល់ដូចផ្លែលំពែងច្រាស់។ កូនស្លឹករាងដូចពេជ្រ មានក្នុងពួក *Korthalsia* (ដែលមានគែមស្លឹកដូចធ្មេញល្អិតៗ) និងក្នុងប្រភេទ *Calamus bousigonii* (មានគែមស្លឹករលីង)។ គែមកូនស្លឹក និងបន្ទះស្លឹកជាទូទៅមានរោមរឹងៗ ប៉ុន្តែប្រភេទក្នុងពួក *Plectocomia* និងពួក *Korthalsia* ពុំមានរោមរឹងនៅតាមគែមស្លឹកទេ។




ស្លឹកបង្ហាញពីផ្នែកខុសៗគ្នា



កូនស្លឹកតម្រៀបឈម



កូនស្លឹកតម្រៀបឈមដាច់ៗ



កូនស្លឹកតម្រៀបជាក្រុម



កូនស្លឹកតម្រៀបមិនស្មើ



រាងដូចពេជ្រ



រាងផ្លែលំពែង



រាងផ្លែលំពែងច្រាស់



រាងទ្រវែង

## ៦.៥ ដៃតោង

ដៃតោងមានពីរប្រភេទគឺដៃតោងគល់ទងស្លឹក (flagellum) និងដៃតោងចុងស្លឹក (cirrus)។ (ពហុវចនៈរបស់ flagellum ហៅថា flagella ហើយពហុវចនៈរបស់ cirrus ហៅថា cirri)។ ដៃតោងគល់ទងស្លឹក គឺជាកញ្ចុំផ្កាអភេទដែលដុះចេញពីទងស្លឹក ចំណែកដៃតោងចុងស្លឹកមាននៅក្នុងពួកផ្សេងៗ និងក្នុងប្រភេទមួយចំនួនតូចរបស់ពួក*Calamus*។ វាមានមុខងារតោងដើមឈើនៅក្បែរដើម្បីលូតឡើងលើ។ រពាក់អត់មានទាំងដៃតោងគល់ទងស្លឹក និងដៃតោងចុងស្លឹក តែពេលខ្លះមានលយចេញ ២-៣សមពីចុងស្លឹក តែមិនមែនដូចដៃតោងចុងស្លឹកទេ។



ដៃតោងចុងស្លឹក



ដៃតោងគល់ទងស្លឹក



អត់មានដៃតោង

## ៦.៦ កញ្ចុំផ្កា

ផ្តៅចេញផ្កាតាមពីរបែបផ្សេងគ្នាគឺ **ផ្កាគល់ទងស្លឹក** និង**ផ្កាចុងដើម** ។ នៅក្នុងប្រទេសកម្ពុជា ពួក*Calamus* និង*Daemonorops* ចេញផ្កាគល់ទងស្លឹក ចំណែកឯ *Korthalsia, Myrialepis, Plectocomia* និង *Plectocomiopsis* ចេញផ្កាចុងដើម ។

ដើមក្នុងប្រភេទផ្តៅដែលចេញកញ្ចុំផ្កាគល់ទងស្លឹក ចេញផ្កាច្រើនលើកច្រើនសារក្នុងមួយជីវិតរបស់វា ។ វាចេញស្លឹកតាមលំដាប់លំដោយ រួមជាមួយកញ្ចុំផ្កាក្នុងរដូវចេញផ្កា និងបន្ទាប់មកទៀតបន្តដុះលូតលាស់ដូចធម្មតាតាមរដូវកាល ។ ផ្ទុយទៅវិញ ផ្តៅប្រភេទចេញផ្កាខាងចុងដើម ដុះលូតលាស់យូរឆ្នាំ ទើបចេញផ្កា និងផ្លែ ហើយងាប់តែម្តង ។ ស្រទប និងស្លឹកលូតលាស់ក្នុងកំឡុងពេលចេញផ្កា-ផ្លែ រួញតូចៗ ហើយខុសពីស្រទប និងស្លឹកនៅលើផ្នែកផ្សេងក្នុងដើមតែមួយ ។ ដោយសារថាផ្តៅប្រភេទចេញផ្កា-ផ្លែចុងដើមដុះជាគុម្ព ហើយចេញផ្កាតាមពេលខុសៗគ្នា នោះវាមិនអាចធ្វើអោយគ្រប់ដើមទាំងអស់ក្នុងគុម្ពតែមួយងាប់នោះទេ ។



កញ្ចុំផ្កាគល់ទងស្លឹក



កញ្ចុំផ្កាចុងដើម

កញ្ចុំផ្កាជាទូទៅមានទម្រង់សាំញ៉ាំតែមានបែកទងច្រើន ឬតិចខុសៗគ្នា ។ ទងកណ្តាល (អ័ក្សមេ) មួយមានបែកទងសងខាង (មែក១) ចំនួន៣-៨ ។ ទងនីមួយៗដែលបែកចេញពីទងកណ្តាលនេះ ចេញកូនទងតូចៗ (មែកទី២) ជាច្រើនទៀត ហើយកូនទងតូចៗនេះ អាចបន្តចេញកូនទងតូចៗទី៣ ឬរហូតដល់ទី៤ជាច្រើនទៀត ។

អ័ក្សកណ្តាលរបស់កញ្ចុំផ្កាហៅថា **ទងកញ្ចុំផ្កា** ។ ទងដែលបែកចេញពីអ័ក្សមេលើកទីមួយ រួមជាមួយទងមែកតូចៗជាច្រើនទៀតហៅថា**កូនកញ្ចុំផ្កា** ។ ផ្កាចេញតែពីកូនទងចុងក្រោយបង្អស់ប៉ុណ្ណោះ ហើយទងមែកទាំងនេះហៅថា**ទងកូនកញ្ចុំផ្កា** ។

ទងមែកទាំងអស់នេះព័ទ្ធជុំវិញដោយស្រទប រាងជាបំពង់។ ស្រទបនៅលើទងកូនកញ្ចុំផ្កា ហៅថាស្ទបកូនកញ្ចុំផ្កា។ ទម្រង់របស់ស្រទបតាមបណ្ដោយទងមែកមានសារៈសំខាន់ណាស់ ពិសេសសម្រាប់ការធ្វើអត្តសញ្ញាណកម្មព្រោះវាមានទម្រង់ប្លែកៗរួមមាន រាងក្ដោបណែន និងបិតជិត រាងសំប៉ែតបិទជិត និងបិតជិត រាងដាច់រយៃ រាងពុកដាច់ដុំៗ ឬរហូតដល់សំប៉ែតជាបន្ទះដូចស្លឹកឈើ (Evans et al., 2001)។ នៅក្នុងប្រភេទជាច្រើនវាពុំសូវច្បាស់ ប៉ុន្តែចំពោះផ្ដៅសោមក្ដោបកញ្ចុំផ្កាទាំងមូលដូចស្ទបកញ្ចុំផ្កាចេក ។







## ៦.៧ ផ្កា

ជាទូទៅ ផ្ដៅចេញផ្កាឈ្មោល និងផ្កាញីនៅលើរុក្ខជាតិខុសៗគ្នា ដូច្នេះគេហៅវាថា រុក្ខជាតិឯកភេទ។ ពួក *Korthalsia* ជារុក្ខជាតិទ្វេរភេទ ហើយផ្កាមានកេសរញី និងកេសរឈ្មោលនៅលើផ្កាតែមួយ(*Dransfield,* ១៩៧៩)។ ជាទូទៅ ផ្កាពុំមានរូបរាងច្បាស់ទេ ដោយសារវាមានទំហំតូច ពណ៌ស ឬស្រអាប់។ ផ្ការួមមានកញ្ចុំត្របកបីជាប់គ្នា កញ្ចុំស្រទាប់បីជាប់គ្នា កេសរឈ្មោល៦ និងកេសរញីបីថត។ កញ្ចុំត្របក ឬកញ្ចុំផ្កាមានស្រទាប់ផ្កាជាប់គ្នា ឬដាច់ពីគ្នា។ ពួក *Calamus* និង *Daemonorops* កញ្ចុំផ្កាញីមានផ្កាគូរៗដែលមានផ្កាញីបន្តពូជបាន និងផ្កាឈ្មោលមិនបន្តពូជបាន ហើយផ្កាទាំងពីរប្រភេទនេះស្ថិតនៅក្នុងស្រទបកញ្ចុំផ្កា។ អូវែមានស្រកានៅគ្របពីលើគ្នាច្រើនជាន់ និងមានស្នឹកម៉ាតព្រែកជាបីរាងកោងចេញក្រៅ (Dransfield, 1979)។



Sterile
male flower

ផ្កាឈ្មោល



Fertile
female flower

ផ្កាញី

## ៦.៨ ផ្លែ

ផ្លែផ្តៅមានសាច់ ហើយមានរាងច្រើនយ៉ាងរួមមាន រាងមូល រាងស្ទើរមូល រាងអេលីប ឬរាងផតក្បាល (Evans *et al.*, 2001) ។ ផ្នែកខាងក្រៅរបស់ផ្លែមានទម្រត្របក ស្រកា និងស្ទីកម៉ាត ហើយផ្នែកខាងក្នុងមានសាច់ និងគ្រាប់ ។

កញ្ចុំត្របក និងត្របកផ្កាដែលនៅជាប់នឹងផ្លែ ជួនកាលឆ្លាស់គ្នាដោយការរឆែកដល់គល់ដោយបង្កើតបានរាងដូចផ្កាបើកចំហ ចំណែកផ្សេងទៀតក្លែបទាំងអស់នៅជាប់គ្នាដុំៗដោយបង្កើតបានរាងពែងជាបំពង់ ដោយលើកផ្លែចេញពីទងកូនកញ្ចុំផ្កា ។

**ស្រកាសំបក** – ផ្លែរបស់ប្រភេទផ្តៅជាច្រើនតម្រៀបនៅជាប់ៗគ្នាជាជួរបញ្ឈរ និងរលោង ប៉ុន្តែពួក *Myrialepis* ស្រកាសំបកវាតូចៗ ហើយតម្រៀបមិនស្មើគ្នា ( មានសណ្ឋានដូចស្បែកឆ្លាម) ។ ស្រកាសំបកផ្លែក្នុងពួក *Calamus, Daemonorops* និង*Plectocomia* មួយចំនួនមានសភាពរឹង រលោង និងមានជាចង្អូរនៅចំកណ្តាលស្រកាវានីមួយៗ ហើយសំបករបស់ពួក *Plectocomia* មានព្រុយនៅចុង ។ ពណ៌សំបកផ្លែខ្ចី និងផ្លែស្ទើរចាស់ ជាញឹកញាប់មានពណ៌បៃតងចាស់ និងគែមពណ៌ត្នោត ហើយប្រែប្តូរបន្តិចៗទៅពណ៌ផ្សេងៗនៅពេលផ្លែទុំ ។ សំបកផ្លែទុំប្រែពណ៌ពីលឿងរាងសទៅពណ៌ត្នោតខ្ចី និងពណ៌ទង់ដែង ។



ស្រកាសំបកគ្មានរោម



ស្រកាសំបកមានរោម

**ចំពុះ** – ចំពុះផ្លែគឺជាកដែលនៅជាប់ទៅនឹងចុងអូវែ ហើយពេលអូវែវិវត្តិជាផ្លែ កកេសរញីនេះមានរាងដូចចំពុះសត្វ ។ ចំពុះផ្លែមិនមានសារៈសំខាន់សម្រាប់ការធ្វើអត្តសញ្ញាណដូចផ្នែកផ្សេងៗទៀតដូចជា:

ផ្លែ សំបក ឬផ្នែកល្ងួតលាស់មួយចំនួនទៀតដែលមានភាពខុសប្លែកគ្នាដាច់ស្រឡះ។ ចំពុះផ្លែ គេអាចប្រើប្រាស់ជាផ្នែកបន្ទាប់បន្សំសម្រាប់ការធ្វើអត្តសញ្ញាណប្រភេទ។ ប្រភេទខ្លះក្នុងពួកចំនួនពីរ ជួនកាលគេអាចច្រឡំបើមិនមានផ្លែ។ ចំពុះផ្លែក្នុងពួក *Calamus* និង *Daemonorops* ជាទូទៅជាប់គ្នានៅត្រង់គល់ ហើយបន្ទាប់មកផែកជាបីក្លែប(ស្ទីកម៉ាត)។ ចំពុះផ្លែក្នុងពួក *Plectocomiopsis* ខ្ចីមែនទែន ហើយមិនផែកជាក្លែបទេ (Evans *et al.*, 2001)។



ផ្លែរាងមូល ចំពុះខ្លី



ផ្លែរាងស៊ុត ចំពុះវែង



ផ្លែរាងអេលីប



ផ្លែរាងផតចុង

**សាច់ផ្លែ** ជាស្រទាប់ស្តើង ពណ៌ត្នោតព័ទ្ធជុំវិញគ្រាប់។ វាមានរសជាតិជូរឯម ហើយជាញឹកញាប់អាចហូបបាន។ ចំនុចឆ្នូតលើគ្រាប់ គឺ**ស្នាមជ្រួញ** ហើយនៅពេលកាត់គ្រាប់ជាពីរកំណាត់មើលខាងក្នុង ឃើញមានស្នាមខ្មៅ-សជុំៗ។ គ្រាប់ដែលមានផ្ទៃរលោង មានពណ៌សស្មើសាច់នៅខាងក្នុង គឺបញ្ជាក់ថា**គ្រាប់រលោង** (អត់ជ្រួញ) ឬផ្ទៃលាតស្មើសាច់គ្នា។



សាច់ព័ទ្ធជុំវិញផ្លែ



គ្រាប់ជ្រួញ



គ្រាប់រលោង

## ៧- ការប្រមូលសំណាក

គោលការណ៍រួមក្នុងការប្រមូលសំណាករុក្ខជាតិ ត្រូវប្រមូលផ្នែក ឬសរីរាង្គតំណាងអោយរុក្ខជាតិដូចជា សំបក កូនមែក ស្លឹក និងផ្កាផ្លែ និងប្រមូលរុក្ខជាតិទាំងមូល បើសិនជារុក្ខជាតិនោះតូច ពិសេសពពួកតិណ្ណជាតិ។ ជាទូទៅសំណាកមួយអាចប៉ុននឹងទំហំចន្លោះក្រដាស់កាសែត។ ដូចប្រភេទក្នុងពួកតាលព្រឹក្សផ្សេងៗទៀតដែរ សំណាកផ្តៅទាមទារការប្រមូលច្រើនផ្នែកចូលគ្នាដើម្បីបានសំណាកពេញលេញមួយ។ ដូច្នេះជាទូទៅត្រូវការ ពេលយូរ និងការអត់ធ្មត់ដើម្បីប្រមូលបានសំណាកដ៏ល្អមួយ។

### ៧.១ វិធីសាស្ត្រប្រមូលសំណាក

ដើមផ្តៅប្រែប្រួលលក្ខណៈរូបរាងខុសគ្នាពីដើមខ្ចី ទៅដើមពេញវ័យ ដូច្នេះសំខាន់ណាស់ត្រូវប្រុងប្រយ័ត្ន ក្នុងការប្រមូលសំណាក។ ត្រូវប្រមូលផ្នែកសរីរាង្គរបស់ដើមពេញវ័យ ផ្នែកដៃតោងរបស់ដើមដែលមានរូបរាង គ្រប់សព្វ។ ការប្រមូលសំណាកចាំបាច់ត្រូវជៀសវាង:

- ផ្នែករបស់ដើមមិនពេញវ័យ (ព្រោះវាមិនទាន់មានដៃតោង និងពកគល់ទងស្លឹក)
- ដើមចាស់ជ្រុល ដែលផ្នែកជាច្រើនរបេះចេញព្រោះវាបាត់បង់ផ្នែកសំខាន់ៗ
- ចុងដើមពេកព្រោះវាមានជាតិទឹកច្រើនដែលអាចបណ្តាលអោយសំណាកខូច ដោយសារដុះផ្សិត និង បាត់បង់រូបរាងពេលវាស្ងួត

សំណាករបស់ប្រភេទមួយចំនួនដូចជា រពាក់ និងសែសឹង/ផ្តៅចង្រិត អាចប៉ុននឹងទំហំក្រដាស់កាសែត ប៉ុន្តែសំណាករបស់ប្រភេទជាច្រើនទៀតដែលមានដើមធំជាងនេះ មិនអាចប៉ុនក្រដាស់កាសែតទេ ហើយចាំបាច់ ត្រូវបំបែកជាពីរ ឬបីចំណែក។ ចំណែកដាច់ៗពីគ្នារបស់សំណាកមួយ ត្រូវមានលេខដូចគ្នាដើម្បីជៀសវាងការ ភ័ន្តច្រឡំនៅពេលយកត្រឡប់ពីកន្លែងប្រមូលវិញ ឬពេលរក្សាទុកនៅក្នុងតិណាល័យ។ បើសិនអាចធ្វើទៅបាន ចងផ្លាកលេខជាប់ជាមួយសំណាកនៅតាមផ្នែកនីមួយៗដើម្បីការពារសំណាកមិនអោយច្របូកច្របល់គ្នា។

**ការប្រមូលសំណាកផ្តៅសមស្របត្រូវតែប្រមូលអោយបានគ្រប់ផ្នែកតំណាងជាច្រើនរួមមាន:**

**១- ផ្នែកលូតលាស់:** ដើម ស្លឹក ស្រទបស្លឹក និងដៃតោង។ ស្រទបស្លឹកមានពកគល់ទងស្លឹក ស្រកីស្រទប បន្លា និងជួនកាលមានដៃតោងគល់ទងស្លឹក។ ស្លឹករបស់ប្រភេទជាច្រើនវែង និងធំ ដូច្នេះយើងមិនអាចប្រមូលផ្នែកទាំងមូល បានទេ។ ក្នុងករណីនេះ យើងប្រមូលតែផ្នែកទងស្លឹក ផ្នែកកណ្តាល និងចុងស្លឹក។ បើសិនស្លឹកមានដៃតោងចុងស្លឹក យើងប្រមូលចុងស្លឹកដែលមានដៃតោងនេះ។ បើសិនជាកូនស្លឹកធំ និងធំជាងក្រដាស់កាសែត យើងកាត់កូនស្លឹក មួយចំហៀងចេញ (ដោយរក្សាទុកគល់កូនស្លឹក) និងមួយចំហៀងទៀតត្រូវបត់ដើម្បីអោយប៉ុនទំហំក្រដាសកាសែត

ដៃតោងគល់ទងស្លឹករបស់ប្រភេទមួយចំនួនដូចជា ផ្តៅដឹបងមានប្រវែងហួតដល់ ៨ម៉ែត្រដែលពិបាកប្រមូលទាំងមូល ដូច្នេះកាត់យកតែផ្នែកគល់ និងចុង គឺគ្រប់គ្រាន់ ។

**២- ផ្នែកបន្តពូជៈ** ផ្តៅជាច្រើនប្រភេទមានកញ្ចុំផ្កាធំ និងវែងដែលមិនអាចប្រមូលសំណាកទាំងមូលបាន ។ ដើម្បីប្រមូលសំណាកបែបនេះ ត្រូវកាត់យកផ្នែកនៅគល់ទងកញ្ចុំផ្កា និងកូនកញ្ចុំផ្កាមួយ ហើយបន្ទាប់មកប្រមូលកូនកញ្ចុំផ្កាចុងក្រោយដើម្បីបង្ហាញលំដាប់ទំហំរបស់វា ។ គេផ្តល់អនុសាសន៍យ៉ាងខ្ពង់ខ្ពស់អោយប្រមូលសំណាកលើសពីមួយឈុតដើម្បីអាចធ្វើការបែងចែក ដោយមួយឈុតរក្សាទុកនៅស្ថាប័នក្នុងប្រទេសខ្លួន និងមួយផ្សេងទៀតសម្រាប់ផ្ញើទៅកាន់តិណាល័យនៅប្រទេសផ្សេងៗទៀតសម្រាប់ការធ្វើអត្តសញ្ញាណកម្ម និងថែរក្សា ។

## ៧.២ ការកត់ត្រាសំណាក

ការកត់ត្រាសំណាក គឺសំខាន់ណាស់ ។ វាផ្តល់នូវព័ត៌មាន ដែលយើងមិនអាចមើលឃើញនៅពេលវាស្ងួត ។ ព័ត៌មានបញ្ចូលក្នុងការកត់ត្រានេះរួមមាន ឈ្មោះអ្នកប្រមូល ឈ្មោះក្នុងស្រុក ថ្ងៃបរិច្ឆេតប្រមូល និងទីកន្លែងប្រមូលដែលរួមមាន លេខអាប់ស៊ីសកូអរដោនេ ភូមិសាស្ត្រ ទីជម្រក រយៈកម្ពស់ និងរូបរាង ។ តាមលក្ខណៈរូបរាងការកត់ត្រាសំណាកផ្តៅនៅទីវាលរួមមាន ប្រភេទលូតលាស់ ប្រវែង និងមុខកាត់ដើម ប្រវែងស្លឹក និងដៃតោងគល់ទងស្លឹក (បើសិនជាវាវែងពេកមិនអាចប្រមូលបានទាំងអស់) ចំនួនកូនស្លឹករបស់ស្លឹកនីមួយៗវត្តមាន ឬអវត្តមានជាតិម្សៅនៅលើកូនស្លឹក ឬស្រទបស្លឹក ទំហំកញ្ចុំផ្កា ចំនួនកូនកញ្ចុំផ្កា និងពណ៌សរីរាង្គពេលនៅស្រស់ ។ សូមកត់ចំណាំ ការបម្រែបម្រួលសរីរាង្គផងដែរ ព្រោះថានេះនឹងមិនសូវច្បាស់ទេនៅពេលសំណាកស្ងួត ។

## ៧.៣ ការថែរក្សា និងការសំងួត

ដូចសំណាករុក្ខជាតិផ្សេងៗក្រៅពីផ្តៅដែរ សំណាកនីមួយៗត្រូវដាក់នៅក្នុងចន្លោះកាសែត គរជាបាច់និងបន្ទាប់មកចងអោយតឹងជាមួយខ្សែចំណង ។ គំនរសំណាកត្រូវរក្សាទុកក្នុងថង់ប្លាស្ទិច និងប្រោះអាកុល៩០អង្សាចូលដើម្បីការពារការខូចខាត ។ ថង់ប្លាស្ទិចដែលមានសំណាកក្នុងនោះត្រូវចងអោយជិតល្អដើម្បីការពារកុំអោយអាកុលភាយឡើង ។ ពេលសំងួតសំណាកនីមួយៗ ត្រូវដាក់នៅចន្លោះក្រដាស់កាតុងពីរ ។ សំណាកមួយដុំត្រូវចងអោយតឹងជាមួយនឹងខ្សែចងពីរ និងដាក់លើធុងចង្អើរ ។ ចង្ក្រានត្រូវមានអណ្តាតភ្លើងតិចៗដើម្បីអោយបានកំដៅភ្លើងតិចៗសំងួតសំណាកអោយបានសព្វល្អ ។ បើសិនជាកំដៅភ្លើងខ្ពស់ពេក សំណាកនេះនឹងរួញ ។

## ៨. ឈ្មោះក្នុងតំបន់

ផ្តៅជាឈ្មោះទូទៅមួយក្នុងភាសាខ្មែរ លើកលែងតែរពាក់ចេញដែលជាប្រភេទផ្តៅដុះនៅតាមវាលស្រែ។ ដោយរួមជាមួយឈ្មោះចុងក្រោយ វាក្លាយជាឈ្មោះពិតប្រាកដមួយ។ អ្នកភូមិខ្លះប្រើឈ្មោះកាត់ដោយហៅតែឈ្មោះខាងចុងជាឈ្មោះពិតប្រាកដតែម្តង។ ឧ.ទា. ផ្តៅសោម ជួនកាលគេហៅសោម។ សហគមន៍ដែលរស់នៅតំបន់ផ្សេងៗគ្នា ហៅឈ្មោះផ្តៅតាមតំបន់ខុសៗគ្នាក្នុងប្រភេទតែមួយដែលអាចនាំអោយមានការភាន់ច្រលំ។ ឧទាហរណ៍ ប្រភេទ *C. rudentum* ជាទូទៅគេហៅផ្តៅក្រែក ប៉ុន្តែសហគមន៍នៅតាមតំបន់មួយចំនួនហៅផ្តៅគោក ផ្តៅល្ងឹង ត្រេស-ស ឬផ្តៅកន្ទេល។

ប្រភេទផ្តៅផ្សេងគ្នា ក៏គេអាចហៅឈ្មោះតំបន់ដូចគ្នាដែរ។ ឧទា. ផ្តៅដំបងជាឈ្មោះវិទ្យាសាស្ត្រគឺ *C. rudentum* ប៉ុន្តែជួនកាលសហគមន៍នៅភាគខាងត្បូង និងប៉ៃលិនីរតីហៅប្រភេទ *Plectocomia elongata* ថាផ្តៅដំបងដែរ។ ផ្តៅក្រែកជាឈ្មោះវិទ្យាសាស្ត្រគឺ *C. viminalis* ប៉ុន្តែសហគមន៍នៅខេត្តព្រះវិហារហៅប្រភេទ *C. acanthophyllus* ថាផ្តៅក្រែកដែរ។ ប្រភេទ *Calamus siamensis* និង *Calamus godefroyi* មានឈ្មោះខ្មែរតែមួយគឺផ្តៅទឹក។ អ្នករស់នៅក្នុងតំបន់ព្រៃទាំងអស់ស្គាល់ឈ្មោះផ្តៅមិនគ្រប់គ្នាទេ ដែលអាចបណ្តាលអោយខុសក្នុងការប្រើឈ្មោះវិទ្យាសាស្ត្រ បើសិនជាយើងផ្អែកតែលើឈ្មោះហៅក្នុងតំបន់ទាំងស្រុងដោយពុំបានឃើញដើមរបស់វា។ សំខាន់ណាស់គឺថាត្រូវឃើញផ្តៅសិនមុននឹងដាក់ឈ្មោះប្រភេទអោយបានត្រឹមត្រូវ ហើយនៅទីណាក៏ដោយបើអាចធ្វើទៅបានត្រូវប្រមូលសំណាកដើម្បីជាជំនួយដល់ការកត់ត្រារបស់អ្នក។

## តារាង៖ បញ្ជីឈ្មោះផ្តៅនៅកម្ពុជា និងសេចក្តីសង្ខេបអំពីភាពសម្បូរ និងរបាយ

| ល.រ. | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះខ្មែរ | ឈ្មោះហៅតាមតំបន់ | ទីជម្រក | រយៈកម្ពស់ | ភូមិសាស្ត្រ | របាយ និង ភាពសម្បូរ |
|---|---|---|---|---|---|---|---|
| ១ | *Calamus palustris* Griff. | ផ្តៅឈ្វាំង | ក្បង់/ កន្ទ្រោង/ គួញ | ព្រៃស្រោង ដល់ ព្រៃពាក់កណ្តាលស្រោង | ១០០ម ដល់ ជិត៦០០ម | ជម្រាលភ្នំ/ លើដីខ្ពស់ | រាយប៉ាយ មធ្យមក្នុងប្រទេស |
| ២ | *C. viminalis* Willd. | ផ្តៅក្រែក | ផ្តៅពោក/ ផ្តៅល្វីង/ ក្រេលស ផ្តៅកន្ទេល | ព្រៃល្បោះ ដល់ ព្រៃពាក់កណ្តាលស្រោង | ទាបជាង ១០០ម ដល់ ជិត៥០០ម | លើដីខ្ពស់ ជំរូក និង តំបន់ខ្ពស់ | សម្បូរគ្រប់ទីកន្លែង |
| ៣ | *C. salicifolius* Becc. | រពាក់ | | តម្លោតព្រៃតាមវាលស្រែវាលស្មៅ ដីល្បាប់ | ទាបជាង ១០០ម | ទំនាបលិចទឹក ឬតាមភ្លឺស្រែ | សម្បូរតាមវាលស្រែ |
| ៤ | *C. bousigonii* Becc. | ផ្តៅអារ៉េច | | ព្រៃស្រោង ដល់ ព្រៃពាក់កណ្តាលស្រោង | រហូតដល់ ១០០០ម | លើដីខ្ពស់/ ជម្រាលភ្នំ | សម្បូរមធ្យមនៅប៉ែកខាងកើត និងត្បូង ភាគខាងលិច |
| ៥ | *C. rudentum* Lour. | ផ្តៅដំបង | | ព្រៃពាក់កណ្តាលស្រោង ដល់ ព្រៃតាមមាត់ទឹក | ទាបជាង១០០ ដល់ ជិត៤០០ម | មាត់ច្រាំងទន្លេ កន្លែងលិចទឹក ម្តងម្កាល និង ទីមានសំណើម | សម្បូរនៅតាមកោះ ក្នុងទន្លេមេគង្គ កែសីម៉ា និងកំពង់ធំ |
| ៦ | *C.tetradactylus* Hance | សែសឹង | ផ្តៅចង្រិត/ ផ្តៅរពាក់/ ហាពាក់ | ព្រៃស្រោង ដល់ ព្រៃពាក់កណ្តាលស្រោង | ទាបជាង ១០០ម ដល់ជិត៣០០ម | លើដីខ្ពស់ និងកន្លែងលិចទឹក ម្តងម្កាល | សម្បូរតាមតំបន់ព្រៃជាច្រើនក្នុង ប្រទេសកម្ពុជា |
| ៧ | *C. guruba* Buch. | ផ្តៅអាចម៍មាន់ | ផ្តៅក្រែស/ ក្រែសអាចម៍មាន់ | ព្រៃស្រោង ដល់ ព្រៃពាក់កណ្តាលស្រោង | ពាមក្រោម នីវ៉ូទឹកសមុទ្រ ដល់៤០០ម | តំបន់ដីខ្សាច់ មានជាតិអាស៊ីតទាប លិចទឹកម្តងម្កាល ឬនៅរដូវវស្សា។ ប្រភេទទាំងនេះមិនដុះតាមទំនាបលិចទឹក បឹងទន្លេសាបទេ។ | សម្បូរ និងមានរបាយ ពីប៉ែកនិរតីទៅភាគខាងលិចក្នុងប្រទេសកម្ពុជា |
| ៨ | *C. siamensis* Becc. | ផ្តៅទឹក | | ព្រៃតាមមាត់ទឹក | ទាបជាង ១០០ម ដល់ ២០០ម | តាមបណ្តោយ មាត់ច្រាំងស្ទឹង/ទន្លេលិចទឹក តាមរដូវ | សម្បូរនៅភាគខាងកើត ប្រទេសកម្ពុជា ប៉ុន្តែមិនមាននៅតាមជុំវិញ បឹងទន្លេសាបទេ |
| ៩ | *C. godefroyi* Becc. | ផ្តៅទឹក | | ព្រៃតាមមាត់ទឹក | ទាបជាង ១០០ម | ទំនាបលិចទឹក តាមទន្លេមេគង្គ និងបឹងទន្លេសាប | នៅជុំវិញបឹងទន្លេសាប និង អាងទឹកទន្លេមេគង្គ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១០ | *C. lateralis* Henderson, N. K. Ban & N. Q. Dung | មិនស្គាល់ | | ព្រៃពាក់កណ្តាលស្រោង | ១០០ម ដល់ ៣០០ម | ជម្រាលភ្នំ និងលើដីខ្ពស់ | ខ្សត់ណាស់មានតែនៅកែវសីម៉ា |
| ១១ | *C. erinaceus* (Becc.) J. Dransf. | ផ្តៅឯង | ផ្តៅទឹកប្រៃ | ព្រៃស្រោង និងព្រៃកោងកាង តាមបណ្តោយព្រែកទឹកសាប | ទាបជាង៥០ម | តាមបណ្តោយ ពាម/ព្រែក ទឹកសាប | សម្បូរមធ្យម មានតាមខេត្តកោះកុង កំពង់សោម និងកំពត |
| ១២ | *Calamus sp .* | ផ្តៅទឹកឃ្មុំ | | ព្រៃស្រោង | ៣០០ម ដល់ ៦០០ម | តាមបណ្តោយ មាត់ច្រាំងទន្លេ | សម្បូរមធ្យមមាននៅសំកុស និងសំឡូត |
| ១៣ | *C. acanthophyllus* | ផ្តៅក្រែក* | ផ្តៅស្បាត | តំបន់វាលរាប | គ្មានព័ត៌មាន | គ្មានព័ត៌មាន | មាននៅខេត្តព្រះវិហារ រកឃើញដោយបណ្ឌិត ថូម អេវិន |
| ១៤ | *Daemonorops jenkinsiana* (Griff.) Mart. | ផ្តៅសោម | | ព្រៃពាក់កណ្តាលស្រោង ដល់ព្រៃតាមមាត់ទឹក | រហូតដល់ ១០០០ម | តាមមាត់ទន្លេ និងទីសើម | សម្បូរមធ្យមក្នុងប្រទេសកម្ពុជា |
| ១៥ | *Korthalsia laciniosa* Mart. | ព្រះផ្តៅ | ផ្តៅក្រហម | ព្រៃពាក់កណ្តាល ស្រោង ដល់ ព្រៃតាមមាត់ទឹក | ១០០ម ដល់ ៦០០ម | តាមច្រាំងទន្លេ ទីសើម និង ជម្រាលភ្នំ | សម្បូរមធ្យមក្នុងប្រទេសកម្ពុជា |
| ១៦ | *Myrialepis paradoxa* (Kurz) J. Dransf. | ផ្តៅឫស្សី | ត្រែសណើ/ ស្នូ ឬឆ្នូ | ព្រៃរិចរិល ដល់ ព្រៃពាក់កណ្តាលស្រោង | ទាបជាង ១០០ម ដល់ ៣០០ម | លើដីខ្ពស់ និងជម្រាលភ្នំ | សម្បូរមធ្យមក្នុងប្រទេសកម្ពុជា |
| ១៧ | *Plectocomia elongata* Mart. & Blume | ផ្តៅឫស្សីយក្ស | ផ្តៅដំបង | ព្រៃស្រោង | ៥០០ម ដល់ ១០០០ម | ជំរាលភ្នំ និង តាមពូរភ្នំ | សម្បូរមធ្យមនៅប៉ែកនិរតី និងខាងកើត |
| ១៨ | *P. pierreana* Becc. | ចង្អូរ | ត្រែសអំបោះ/ផ្តៅឫស្សីម្សៅ | ព្រៃស្រោង ដល់ ព្រៃពាក់កណ្តាលស្រោង | ទាបជាង ១០០ម ដល់ ៨០០ម | តាមជម្រាលភ្នំ និងលើដីខ្ពស់ | សម្បូរនៅក្នុងប្រទេសកម្ពុជា |
| ១៩ | *Plectocomiopsis gemiflora* (Griff.) Becc. | តាំងអោ | (ផ្តៅ)ថ្ងៃ | ព្រៃស្រោង ដល់ ព្រៃពាក់កណ្តាលស្រោង | ទាបជាង១០០ម ដល់៤០០ម | លើដីខ្ពស់ | សម្បូរមធ្យម នៅកែវសីម៉ា និងទំពជាង ស្រុកស្រែអំបិល ខេត្តកោះកុង |
| ២០ | Unknown | បន្លាដងវែង * | | ព្រៃស្រោងភ្នំ | ខ្ពស់ជាង ១០០០ម | លើខ្នងភ្នំ និងពូរភ្នំ | មាននៅខេត្ត កោះកុង (ភ្នំធំ) ពោធិសាត់( ភ្នំ ខ្មោចនិងភ្នំសំកុស) |

## ៩.គន្លឹះធ្វើអត្តសញ្ញាណកម្មពួកផ្តៅ

ក១ ស្រកីស្រទបដូចសំណាញ់ កួនស្លឹករាងដូចពេជ្រ តែមស្លឹករយៃ ផ្ទៃស្លឹកខាងក្រោមពណ៌ប្រផេះ...*Korthalsia*

ក២ ស្រកីស្រទបតូច ឬវែង តែមិនដូចសំណាញ់ កួនបន្ទះស្លឹកមានតែមរលោង កម្រមានរាងដូចពេជ្រណាស់លើបន្ទះ ស្លឹកមានពណ៌បៃតង ឬពណ៌ស..............................................................................ខ

ខ១ កញ្ចុំផ្កាគ្របជិតដោយស្រទប ស្រទបរាងពកត្រម៉ោង មិនស្រោបជិតទងកញ្ចុំផ្កា...............*Daemonorops*

ខ២ ស្ទបកញ្ចុំផ្កា មានរាងមិនដូចទូក រលោង និងមានបន្លាខ្លីៗ..................................................គ

គ១ ស្រទបស្លឹកមានពក ដែលកម្រថាមិនច្បាស់ណាស់ កញ្ចុំផ្កាចេញតាមចំហៀងដើម.................... *Calamus*

គ២ ស្រទបស្លឹកអត់មានពក កញ្ចុំផ្កាចេញពីចុងដើម..........................................................ឃ

ឃ១ បន្លាលើស្រទបស្លឹករាយប៉ាយ ដោយមិនដុះតាមជួរត្រឹមត្រូវ................................... *Plectocomiopsis*

ឃ២ បន្លាលើស្រទបស្លឹកដុះជាជួរ..........................................................................................ង

ង១ កួនបន្ទះស្លឹកគ្មានជាតិម្សៅពណ៌ស ផ្លែគ្មានរង្វះកេសរឈ្មោល សំបកផ្លែមានស្រកាតូចៗពណ៌សពេលមើលកែវពង្រីកដៃ...............................................................................................................*Myrialepis*

ង២ កួនបន្ទះស្លឹកមានជាតិម្សៅពណ៌សនៅខាងក្រោមបន្ទះស្លឹក តែមស្លឹកអត់មានបន្លា ផ្លែមានស្លឹកម៉ាតវែងនៅជាប់ជាមួយ...............................................................................................................*Plectocomia*

## ៩.១. Calamus L.

**ទិដ្ឋភាពដើម:** ដើមទោល ឬដុះជាគុម្ព អត់ដើម រហូតដល់ដើមតោងឡើងខ្ពស់ៗ ចេញកញ្ចុំផ្កាចំហៀងដើម និងជាផ្កាឯកភេទ។

**ស្រោមស្លឹក:** ពណ៌បៃតង ជួនកាលមានជាតិម្សៅលើដើមខ្ចី។

**បន្លាស្រោម:** មានបន្លារង្វើល ដល់ញឹកណែន ជួនកាលអត់មាន។

**ពកគល់ទងស្លឹក:** ពកគល់ទងស្លឹកជាទូទៅលេចចេញច្បាស់ ឬមិនសូវច្បាស់ល្អ។

**ស្រកីស្រោម:** ជានិច្ចកាលមានពីខ្លីបំផុត រហូតដល់វែងបំផុត ជួនកាលមានរោម។

**ដៃតោង:** ប្រភេទជាច្រើនមានដៃតោងគល់ទងស្លឹក លើកលែងតែផ្ដៅឃ្មាំង និងផ្ដៅឯងដែលមានដៃតោងចុងស្លឹក ហើយរពាក់ និងប្រភេទ *C. acanthophyllus* អត់មានដៃតោង។

**ស្លឹក:** ស្លឹកខ្ចី ឬវែងកូនស្លឹកតម្រៀបឈមស្មើគ្នាល្អ ឈមដាច់ៗ តម្រៀបមិនស្មើល្អ ឬតម្រៀបជាក្រុម។

**កញ្ចុំផ្កា:** ផ្កាឈ្មោល និងញីពេលមើលមួយភ្លែតស្រដៀងគ្នា ទងកញ្ចុំផ្កាបែកមែកដាច់ៗឆ្ងាយពីគ្នា (កូនកញ្ចុំផ្កា) ជាទូទៅមានដៃតោងនៅខាងចុងបង្អស់ ស្បកកញ្ចុំផ្កាជាទូទៅមានរាងជាបំពង់ នៅខាងគល់ពាក់កណ្ដាលមកខាងចុងជួនកាលផែកមួយចំហៀងជាបន្ទះ។ ផ្កាឈ្មោលមានទម្រត្របករាងដូចពែងតូចៗចុងផែកជាក្លែប និងច្បាស់ត្របកមានចំនួន៣ ផែកនៅគល់កេសរឈ្មោលមាន៦ដុះខ្ចីៗលើ ត្របកកេសរញីតូច។ ផ្កាឈ្មោលអាចពុំមានប្លោកលម្អង ដុះមកជាមួយផ្កាញី។ ផ្កាញីធំជាងផ្កាឈ្មោល មានទម្រត្របកផែករាក់ៗជាបីក្លែប មានត្របកបីកេសរឈ្មោល៦ ជាប់គ្នានៅគល់ដោយបង្កើតបានជារាងរង្វង់ដូចពែង អូវែមានស្ទីកម៉ាត៣ បិតជិតដោយសំបក។

**ផ្លែ:** មានរូបរាងផ្សេងៗគ្នា ហើយគ្រាប់មានសាច់ស្តើង ឬក្រាស់នៅព័ទ្ធជុំវិញ ជ្រួញ ឬរលោង។

ពួកនេះមានប្រហែល ៣៧០ប្រភេទនៅពាសពេញពិភពលោក មានរបាយពីអាហ្វ្រិក ត្រូពិក ឥណ្ឌា អាស៊ីអាគ្នេយ៍ និងចិនខាងត្បូងរហូតដល់តំបន់ប៉ាស៊ីហ្វិកខាងលិច។ បានកត់ត្រាក្នុងប្រទេសកម្ពុជាចំនួន ១៣-១៤ប្រភេទ។

ពួកនេះមានលក្ខណៈប្រហាក់ប្រហែលទៅនឹង *Daemonorops* បើពិនិត្យមើលលើផ្នែកលូតលាស់។ ប៉ុន្តែកញ្ចុំផ្កាជាទូទៅវែង មានកូនកញ្ចុំផ្កាតិចតួចរហូតដល់ច្រើន (និងមានដៃតោងគល់ទងស្លឹកដែលមិនដែលឃើញមាននៅក្នុងពួក *Daemonorops*ទេ)។ លើសពីនេះទៀត ស្បកកញ្ចុំផ្កាជានិច្ចកាលរាងដូចបំពង់ ហើយនៅជាប់នឹងទងកញ្ចុំផ្កា ចំណែកឯ *Daemonorops* ស្បកកញ្ចុំផ្ការាងដូចទូក និងជ្រុះចេញពីកញ្ចុំផ្កា។

# គន្លឹះធ្វើអត្តសញ្ញាណកម្មក្នុងពួក Calamus L.

ក១ ផ្លែកលូតលាស់ជាដើមទោល........................................................................................ខ
ក២ ផ្លែកលូតលាស់ដុះជាគុម្ព........................................................................................គ

ខ១ អត់មានបន្លាលើស្រទបស្លឹក ឬមានរង្វើលបំផុត ស្លឹកឈមត្រង់ជួរ កូនស្លឹកដូចបន្ទាត់.............*C. lateralis*
ខ២ បន្លាស្រទបស្លឹកមានល្អម ស្លឹកមិនតម្រៀបឈម កូនបន្ទះស្លឹករាងដូចពេជ្រ......................*C. bousigonii*

គ១ អត់មានដៃតោងទាំងនៅគល់ទងស្លឹក និងចុងស្លឹក........................................................................ឃ
គ២ មានដៃតោងគល់ទងស្លឹក ឬចុងស្លឹក........................................................................ង

ឃ១ ដើមតោង ជាទូទៅដុះតាមភ្លឺស្រែ........................................................................*C. salicifolius*
ឃ២ អត់មានដើម ដុះតាមព្រៃល្បោះដែលលំហាតម្របម្លប់.........................................*C. acanthophyllus**

ង១ មានដៃតោងចុងស្លឹក........................................................................ច
ង២ មានដៃតោងគល់ទងស្លឹក........................................................................ឆ

ច១ កូនស្លឹកតម្រៀបស្មើលើជួរតែមួយ........................................................................*C. erinaceus*
ច២ កូនស្លឹកតម្រៀបជាក្រុម........................................................................*C. palustris*

ឆ១ កូនស្លឹកតម្រៀបជាក្រុម........................................................................ជ
ឆ២ កូនស្លឹកតម្រៀបតាមជួរតែមួយ ឬមិនតាមជួរ........................................................................ឈ

ជ១ កូនស្លឹកមានតិចជាង ៦ក្រុម គូរខាងចុងស្លឹកជាប់គ្នាប្រហែលពីរភាគបីរបស់បណ្តោយកូនស្លឹក.......*C. tetradactylus*
ជ២ កូនស្លឹកមានលើសពី៦ក្រុម គូរខាងចុងស្លឹកមិនជាប់គ្នា........................................*C. viminalis*

ឈ១ កូនស្លឹករាងដូចពេជ្រ មានទ្រនុងច្បាស់៤ អត់មានរោមលើបន្ទះស្លឹក..............................*C. bousigonii*
ឈ២ កូនស្លឹករាងទ្រវែង ឬស្ទើរលំពែងច្រាស់ ទ្រនុងមានតិចជាង៤ រោមទន់ ឬរោមរឹងអត់មាន លើបន្ទះស្លឹក..ញ

ញ១ ស្រកីស្រទបវែងជាង ៣សម........................................................................ដ
ញ២ ស្រកីស្រទបខ្លីជាង ១សម........................................................................ថ

ដ១ បន្លាស្រទបចង្អុរចុះក្រោម ពណ៌ចម្លើងពកគល់ទងស្លឹកអត់ច្បាស់..............................*C. rudentum*
ដ២ បន្លាស្រទបចង្អុរឡើងលើ ពណ៌ត្នោតខ្ចី ឬពណ៌បៃតង ពកគល់ទងស្លឹកច្បាស់..........................*C. guruba*

ថ១ ពកគល់ទងស្លឹករាងក្តោងទូក បន្លាខ្លីជាង ១សម គល់បន្លារាងពក......................................*Calamus sp.*
ថ២ ពកគល់ទងស្លឹករាងដុំពក ស្រទបមានបន្លាប្រវែងរហូតដល់ ៧សម គល់បន្លារាងរមូល........................ឌ

ឌ១ បន្លាពណ៌បៃតងខ្ចី ដូរទៅពណ៌ត្នោតខ្ចី ទងស្លឹកវែងជាង ១០សម កូនស្លឹកឈមជាជំ២ ឬឈមជាប់គ្នារហូត..*C. siamensis*
ឌ២ បន្លាស្រទបពណ៌ខ្មៅ អត់មានទងស្លឹក រហូតដល់ប្រហែល៥សម កូនស្លឹកជានិច្ចកាលឈមគ្នារហូត......*C. godefroyi*

## ១ *Calamus lateralis* Henderson, N. K. Ban & N. Q. Dung

ឈ្មោះខ្មែរៈ មិនស្គាល់
សទិសន័យៈ មិនមាន

### ការពិពណ៌នា

**ទិដ្ឋភាពដើម ៖** ដុះទោល ( មិនដុះជាគុម្ព) ដើមតោងឡើង មានប្រវែងរហូតដល់ ៣០ម ។
**ស្រទបស្លឹកៈ** មុខកាត់ទំហំ ១,៨-៥សម ពណ៌បៃតង មានជាតិម្សៅពណ៌ក្រម៉ៅ ។
**បន្លាស្រទបៈ** អត់បន្លា ឬមានតិចតួច ។
**ពកគល់ទងស្លឹកៈ** ច្បាស់ល្អ រាងទ្រនុងវែង ។
**ស្រកីស្រទបៈ** តូច ប្រផេះ ឆាប់ដាច់ជ្រុះ ។
**ដៃតោងៈ** ដៃតោងគល់ទងស្លឹកប្រវែង ១៥០ម-២៥០សម ។
**ស្លឹកៈ** ស្លឹកប្រវែង ៦០-៩០សម ទងស្លឹកប្រវែង ១១-១៥សម ទ្រនុងស្លឹកប្រវែង ៥៥-៧០សម ទងស្លឹកអត់មានចង្អូរ មានបន្លាមួយៗនៅតាមគែមទងស្លឹក និងខាងខ្នងទងស្លឹក កូនស្លឹកមួយគូរនៅចុងស្លឹកមិនជាប់គ្នា ។ កូនស្លឹកតម្រៀបឈមត្រង់ជួរ នៅតាមជួរនីមួយៗមានកូនស្លឹកចំនួន ៤០-៤២ កូនស្លឹកនៅទ្រនុងកណ្តាលទំហំ ១៨-២១ x ១,១-១,៥សម ខាងគល់រាងស្តួច តែមមានព្រុយ ចុងស្តួចវែង ទ្រនុងកណ្តាលផុសឡើង ទ្រនុងពីរសងខាងចេញច្បាស់ល្អ បន្ទះស្លឹកខាងលើមានរោមរឹង ។
**ដើមៈ** មុខកាត់ទំហំ ០,៨-១,៨សម ចន្លោះថ្នាំងប្រវែង ១២-១៨សម ដើមជាប់ល្អ ពុំស្វរទន់ ។

**សំគាល់ពិសេសៈ** ប្រភេទនេះខុសពីប្រភេទផ្សេងៗទៀតត្រង់រូបរាងពិសេសពីរគឺ ដើមទោល និងស្រទបស្លឹកគ្មានបន្លា ឬមានបន្លាតិចតួចបំផុត ។ ប្រភេទនេះស្រដៀងគ្នាមែនទែនទៅនឹង *C. poilanei* (Evans T2001) ប៉ុន្តែខុសប្លែកគ្នាត្រង់ផ្លែរបស់វាមានគ្រាប់ជ្រួញ និងអំប្រិយ៉ូនៅចំហៀង ។
**លក្ខណាស់ៈ** ពុំមានព័ត៌មាន ។
**ទីកន្លែងៈ** ប្រភេទនេះទំនងជាមានតែនៅក្នុងតំបន់អភិរក្សជីវចម្រុះកែវសីម៉ាក្នុងស្រុកកែវសីម៉ា ខេត្តមណ្ឌលគិរីភាគឥសាន្តប្រទេសកម្ពុជា ។
**ទីជម្រកៈ** ព្រៃពាក់កណ្តាលស្រោង ។
**រយៈកម្ពស់ៈ** ២០០-២៥០ម ។
**ការប្រើប្រាស់ៈ** មានព័ត៌មានថាដើមរបស់វាពុំស្វរទន់ល្អ ដូច្នេះវាពុំស្វរសាកសមសម្រាប់ការធ្វើគ្រឿងសង្ហារឹមទេ ព្រោះវាងាយបាក់ពេលគេពត់ ។ គមរបស់វាមិនអាចហូបបានទេ ដោយសារមានរសជាតិចត់ខ្លាំងពេក ។
**ពាណិជ្ជកម្មៈ** ឧទ្យានុរក្សនៅព្រៃការពារជីវចម្រុះកែវសីម៉ា បានប្រាប់អោយដឹងថាគេធ្លាប់ប្រមូលវាដើម្បីលក់ទៅអោយប្រទេសវៀតណាមនៅមុនឆ្នាំ ២០០៥ ប៉ុន្តែបច្ចុប្បន្ននេះគេឈប់ប្រមូលហើយ ដោយសារតែដើមមានគុណភាពអន់ ។

# **Calamus lateralis** Henderson, N. K. Ban & N. Q. Dung










១- ទីកន្លែងអង្កេតប្រភេទ *C. lateralis*

២- ស្រទបស្លឹក

៣- ស្លឹកបង្ហាញពីការតម្រៀបកូនស្លឹក

## ២ Calamus salicifolius Becc.

ឈ្មោះខ្មែរ: រពាក់

សទិសន័យ: *C. salicifolius var. leiophyllus* Becc.

### ការពិពណ៌នា

**ទិដ្ឋភាពដើម:** ដុះជាគុម្ព ដើមតោងតិចតួច មានប្រវែង ២-៦ម។

**ស្រទបស្លឹក:** មុខកាត់ទំហំ ០,៤-០,៧សម ពណ៌បៃតង មានជាតិម្សៅពណ៌សពេលដើមនៅខ្ចី ហើយជ្រុះអស់ពេលដើមកាន់តែចាស់។

**បន្លាស្រទប:** មានបន្លារង្វើលលើស្រទបស្លឹក បន្លាប្រវែង ០,៤-០,៦សម គល់បន្លារាងពក និងមានពណ៌បៃតងខ្ចី បន្លាពីលើគល់ ដល់ចុង រាងដូចម្ជុល ពណ៌ខ្មៅ។

**ពកគល់ទងស្លឹក:** ពណ៌បៃតងលាយលឿង ទៅពណ៌បៃតងខ្ចី រាងពក ឬរាងជាពួរ គ្មានបន្លា។

**ស្រកីស្រទប:** ប្រវែង ០,១-០,៥សម ពណ៌ត្នោត មានរោមរឹងៗ។

**ដៃតោង:** អត់មានដៃតោងគល់ទងស្លឹក ឬដៃតោងចុងស្លឹក។

**ស្លឹក:** ប្រវែង១៥-៣០សម ទងស្លឹកប្រវែង០,២-១សម ទ្រនុងស្លឹកប្រវែង ១៤,៧-២៨,៥សម ចុងស្លឹកមានដូចកន្ទុយលយចេញប្រវែង ១,៥សម។ កូនស្លឹកតម្រៀបជា ២-៣ក្រុមកូនស្លឹកនៅដើមទងស្លឹកវែងជាងគេ ហើយរួមខ្លីទៅៗនៅចុងកូនស្លឹកនៅទ្រនុងកណ្ដាលទំហំ៥-១១ x ០,៧-១,៥សម កូនស្លឹករាងទ្រវែងទៅរាងលំពែងគល់ស្ដួចតែមដូចធ្មេញរណា ទ្រនុងកណ្ដាលមានរោមរឹងៗ បន្ទះស្លឹកខាងក្រោមមានជាតិម្សៅពណ៌ស គ្មានរោមរឹងទេ។

**ដើម:** មុខកាត់ទំហំ ០,២៥-០,៤សម ចន្លោះថ្នាំងប្រវែង ៥-២៣សម ដើមទន់ និងជាប់មាំល្អ។

**កញ្ចុំផ្កា:** ត្រង់ទៅលើប្រវែង ២៥-៣០សមរួមទាំងផ្នែកលយចេញ ផ្កាឈ្មោលបែកទង ២ដង ស្របកញ្ចុំផ្ការាងបំពង់នៅត្រង់គល់ នែកខ្លីជាបន្ទះស្តើងនៅមាត់ស្រទប។

**ផ្លែ:** ទំហំ ០,៨-១,២ x ០,៧-១សម រាងស្ទើរមូលទៅរាងពងក្រពើ ស្រកាសំបកពណ៌លឿងចាស់ តែមពណ៌ត្នោតខ្ចី ចំពុះប្រវែង ០,១-០,២សម ។

**គ្រាប់:** មិនជ្រួញ។

**សំគាល់ពិសេស:** ប្រភេទនេះខុសប្លែកពីប្រភេទក្នុងពួក *Calamous* ផ្សេងទៀតត្រង់គ្មានដៃតោង។

**លូតលាស់:** អាចដុះលូតលាស់បាន ២ម៉ែត្រក្នុងមួយឆ្នាំ។

**ទីកន្លែង:** ដុះរាយប៉ាយគ្រប់ទីកន្លែងក្នុងតំបន់ទំនាបកណ្ដាល ពិសេសជុំវិញបឹងទន្លេសាប និងប៉ែកអាគ្នេយ៍នៃប្រទេសកម្ពុជា។

**ទីជម្រក:** នៅតាមភ្លឺស្រែ វាលស្មៅធម្មជាតិ និងគម្ពោតព្រៃ តំបន់ទំនាបដែលរិចរិលខ្លាំងមែនទែន។

**រយៈកម្ពស់:** ដុះនៅរយៈកម្ពស់ទាបជាង ១០០ម។

**ការប្រើប្រាស់:** គេប្រើវាសម្រាប់ធ្វើគ្រឿងតម្បាញដូចជា ល្អី កន្ទេល និងខ្សែចងដោយនាំមកនូវប្រភពចំណូលសម្រាប់សហគមន៍មូលដ្ឋាន។ គេប្រមូលគមរបស់វាសម្រាប់ហូបជាបន្លែ។

**ពាណិជ្ជកម្ម:** ដើមប្រវែង ៤-៥ម៉ែត្រតម្លៃ ១០០-១៥០រៀល។ គេប្រមូលដើមរបស់វាសម្រាប់ធ្វើតម្បាញក្នុងស្រុកតែប៉ុណ្ណោះ។ ពុំមានឯកសារអំពីការនាំចេញប្រភេទនេះទៅលក់នៅក្រៅប្រទេសទេ។

# *Calamus salicifolius* Becc.



















១- ទិដ្ឋភាពដើម

២- ល្អីផលិតពីរពាក់

៣- ប្រភេទដើម

៤- ស្លឹកបង្ហាញពីការតម្រៀបកូនស្លឹក

៥-ពកគល់ទងស្លឹក និងស្រកីស្រទប

៦- ផ្លែ

## ៣ **Calamus erinaceus** (Becc.) J. Dransf.

ឈ្មោះខ្មែរ: ផ្តៅឯង (ផ្តៅទឹកប្រៃ)

សទិសន័យ: *Daemonorops erinacea* Becc.; *Calamus aquatilis* Ridley

### ការពិពណ៌នា

**ទិដ្ឋភាពដើម:** ដុះជាគុម្ព ដើមតោងឡើង ប្រវែងដល់ ២០ម។

**ស្រទបស្លឹក:** មុខកាត់ទំហំ ១,៤-៣,៥សម ពណ៌ទឹកក្រូចលាយបៃតងព្រលែត។

**បន្លាស្រទប:** មានបន្លាចម្រុះវែង-ខ្លី ប្រវែងដល់ ៤សម បន្លានៅមាត់ស្រទបប្រវែងដល់ ៦សម មានសភាពរឹង តម្រៀបជាជួរខ្លី ឬវែង រាងដូចម្ជុល ចង្អុរឡើងលើ ចុះក្រោម ពណ៌លឿង-ត្នោតពីគល់ដល់ចុង។

**ពកគល់ទងស្លឹក:** លេចចេញច្បាស់ រាងពក បន្លា និងរោមរឹងតម្រៀបជាជួរនៅលើពកគល់ទងស្លឹក ពណ៌ត្នោតខ្ចី។

**ស្រកីស្រទប:** ប្រវែង ០,១-០,២សម ពណ៌ខ្មៅ គ្មានរោមរឹង។

**ដៃតោង:** ដៃតោងចុងស្លឹកប្រវែង ១,២-១,៨ម។

**ស្លឹក:** ស្រទបស្លឹកប្រវែង ៣សម ទងស្លឹកប្រវែងដល់ ២៨សម គ្មានចង្អូរ ពោះទងស្លឹកគ្មានបន្លា តែមទងស្លឹកមានបន្លាវែង ឬខ្លី ពណ៌លឿង ទ្រនុងស្លឹកប្រវែងដល់២ម។ ចុងស្លឹកមានដៃតោងដល់ ២ម។ កូនស្លឹកឈមគ្នាម្ខាងៗមានកូនស្លឹកដល់៧០។ កូនស្លឹកនៅចំកណ្តាលទ្រនុងទំហំ ៣០-៣៥ x ១-១,៥សម គល់កូនស្លឹកស្តួច តែមមានរោមរឹងរង្វើល ចុងស្លឹកស្តួចវែង ទ្រនុងកណ្តាលផុសឡើង ទ្រនុងពីរសងខាងចេញច្បាស់ បន្ទះស្លឹកខាងលើគ្មានរោមខាងក្រោម មានរោមរឹងខ្លីៗ ពណ៌ត្នោត។

**ដើម:** មុខកាត់ទំហំ ០,៨-១,៥ម ចន្លោះថ្នាំងប្រវែង ១០-២៥សម ជាប់មាំល្អ។

**កញ្ចុំផ្កា:** ប្រវែងដល់ ១,៥ម ទងកញ្ចុំផ្កាចេញពីក្នុងស្រទបស្លឹក ស្របរាងជាបំពង់ មានបន្លាមួយៗ មាត់ស្រទបសំប៉ែតដូចសន្លឹកក្រដាស់ កញ្ចុំផ្កាញីបែកទងតែមួយ។

**ផ្លែ:** ទំហំដល់ ១សម រាងមូល ទម្រត្របកឆែកនៅគល់។

**សំគាល់ពិសេស:** ប្រភេទនេះជួនកាលដុះលាយឡំជាមួយផ្តៅសោម ហើយយើងអាចភ័នច្រលំយ៉ាងងាយ ព្រោះរូបរាងវាមួយចំនួនធំដូចជា កូនស្លឹកឈមគ្នា ដៃតោងចុងស្លឹក ពកគល់ទងស្លឹក និងបន្លា ប៉ុន្តែផ្នែកបន្តពូជខុសគ្នាដាច់ស្រឡះ។ ដូច្នេះត្រូវប្រុងប្រយ័ត្នពេលដាក់ឈ្មោះនៅក្នុងព្រៃ។ ចំពោះផ្នែកលូតលាស់ប្រភេទនេះមានស្រទបស្លឹកពណ៌ទឹកក្រូច-បៃតង មានបន្លារាងភាវ ពកគល់ទងស្លឹករាងដុំមូល និងផ្នែកខាងក្រៅរបស់ទងស្លឹកគ្មានបន្លា។

**លូតលាស់:** អាចលូតលាស់បាន ១,២៥មក្នុងមួយឆ្នាំ។

**ទីកន្លែង:** ខេត្តកំពត ព្រះសីហនុ និងកោះកុង។

**ទីជម្រក:** នៅតាមតំបន់ឆ្នេរ ភាគច្រើននៅបន្ទាប់ព្រៃកោងកាង និងតាមបណ្តោយព្រែកទឹកសាប។

**រយៈកម្ពស់:** ចាប់ពីកម្ពស់ ២០មធៀបនឹងកម្ពស់ទឹកសមុទ្រ។

**ការប្រើប្រាស់:** គេប្រើធ្វើគ្រឿងសង្ហារឹមដោយផ្សំជាមួយវត្ថុធាតុផ្សេងៗទៀតដូចជាឈើជាដើម ប៉ុន្តែដើមពុំសូវទន់ល្អ ហើយអ្នកផលិតសង្ហារឹមពុំសូវនិយមប្រើច្រើនទេ។

**ពាណិជ្ជកម្ម:** ដើមប្រវែង ៤-៥មតម្លៃ ២០០រៀល។ តាមព័ត៌មានបានអោយដឹងថា ដើមវាគេនាំចេញទៅប្រទេសថៃ ប៉ុន្តែឈប់នាំចេញហើយនាពេលបច្ចុប្បន្ននេះ ពីព្រោះដើមជាទូទៅប្រេះពេលគេពត់វា។

# **Calamus erinaceus** (Becc.) J. Dransf.




១- ទីកន្លែងអង្កេតផ្តៅឯង

២- ធ្នើរសៀវភៅ ផលិតពីផ្តៅឯង

៣- ប្រភេទលូតលាស់

៤- ពកគល់ទងស្លឹក

៥- ស្លឹកបង្ហាញពីការតម្រៀបកូនស្លឹក

៦- កញ្ចុំផ្កា

## ៤ **Calamus palustris** Griff.

ឈ្មោះខ្មែរ: ផ្ដៅឈ្វាំង ( ក្បង់ កន្ទាំង ត្តូញ)
សទិសន័យ: *Calamus dumetorum* Ridl., *Calamus extensus* Roxb., *Calamus gregisectus* Burret, *Calamus humilis* Roxb., *Calamus kerrianus* Becc., *Calamus latifolius* Kurz, *Calamus latifolius* Roxb., *Calamus latifolius* var. *marmoratus* Becc., *Calamus loiensis* Hodel, *Calamus macracanthus* T. Anderson, *Calamus palustris* var. *amplissimus* Becc., *Calamus palustris* var. *cochinchinensis* Becc., *Calamus palustris* var. *malaccensis* Becc., *Calamus quinquenervius* Roxb., *Palmijuncus extensus* (Roxb.) Kuntze, *Palmijuncus humilis* (Roxb.) Kuntze, *Palmijuncus latifolius* (Roxb.) Kuntze, *Palmijuncus macracanthus* (T. Anderson) Kuntze, *Palmijuncus palustris* (Griff.) Kuntze, *Palmijuncus quinquenervius* (Roxb.) Kuntze

### ការពិពណ៌នា

**ទិដ្ឋភាពដើម:** ដុះជាគុម្ព ដើមតោងឡើង ប្រវែងរហូតដល់ ៣០ម ។

**ស្រទបស្លឹក:** មុខកាត់ទំហំ ០,៧-៣សម ពណ៌បៃតង ។

**បន្លាស្រទប:** បន្លាចម្រុះវែង-ខ្លី ជាទូទៅវែងល្មម តែប្រែប្រួលយ៉ាងខ្លាំង មានប្រវែងរហូតដល់ ៣-៥ម៉ែត្រ សំប៉ែត ពីគល់រហូតដល់ចុង គល់វានៅដាច់ៗពីគ្នា ឬជាប់គ្នា ពណ៌បៃតងស្រាល ប្រែទៅពណ៌ត្នោតស្រាល ចុងពណ៌ខ្មៅ ។

**ពកគល់ទងស្លឹក:** លេចចេញច្បាស់ រាងដុំពក ពណ៌បៃតងលាយលឿង ជួនកាលមានបន្លា ជួនកាលអត់បន្លា ។

**ស្រកីស្រទប:** ប្រវែង ០,៦-១,២សម ដុះចេញពីគល់ទងស្លឹកប្រវែង ១សម គ្មានបន្លា ឬរោមរឹងៗពណ៌ត្នោតចាស់ ។

**ដៃតោង:** ដៃតោងចុងស្លឹកប្រវែង ៤០-៥០សម ។

**ស្លឹក:** តួស្លឹកមិនបូករួមទាំងដៃតោងប្រវែង ៦០-១១០សម ទងស្លឹកប្រវែង ៥-៣០សម បន្ទះស្លឹកខាងលើរាងចង្អូរ រាក់មានបន្លាមួយៗ ទ្រនុងស្លឹកប្រវែង ៥០-១០០សម ។ កូនស្លឹកតម្រៀបជាក្រុមចំនួន ២-៥ ។ កូនស្លឹកនៅទ្រនុងកណ្ដាលទំហំ ១៧-៤០ x ២,៥-៧,៥សម គល់ស្ដួច ទៅរាងទាល តែមមានរោមរឹងមួយៗ ចុងស្លឹកស្ដួចវែង ទ្រនុងស្លឹកមាន ៤-៦ ចេញច្បាស់ បន្ទះស្លឹកទាំងសងខាងគ្មានរោមរឹងៗ ។

**ដើម:** មុខកាត់ទំហំ ០,៣-២សម ចន្លោះថ្នាំងប្រវែង ១០-២៥សម ជាប់មាំ និងទន់ល្អ ។

**កញ្ចុំផ្កា:** ផ្កាញីបែកជា ២ទង ផ្កាឈ្មោលបែកជា ៣ទង ស្នបកញ្ចុំផ្កានៅទងទីមួយរាងបំពង់ មានបន្លា ។

**ផ្លែ:** ទំហំ ០,៧-១,២ x ០,៧-១សម ចំពុះប្រវែង ០,២សម រាងពងក្រពើ ទម្រត្របកឆែកនៅគល់ ។

**លក្ខណៈសំគាល់:** ផ្ដៅឈ្វាំង យើងអាចស្គាល់តាមរយៈរូបរាងមួយចំនួនដូចជា កូនស្លឹកតម្រៀបជាក្រុមមានដៃតោងចុងស្លឹក និងស្រកីស្រទបលូតចេញមកខាងលើទងស្លឹក ។ ប្រភេទនេះប្រែប្រួលរូបរាងមែនទែន ។

**លូតលាស់:** លូតលាស់បាន ១,៨ម៉ែត្រក្នុងមួយឆ្នាំ ។

**ទីកន្លែង:** ប្រភេទនេះមាននៅគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ។

**ទីជម្រក:** ដុះក្នុងព្រៃពាក់កណ្ដាលស្រោង ព្រៃស្រោង និងជួនកាលតាមព្រៃមាត់ទឹក ។

**រយៈកម្ពស់:** រហូតដល់កម្ពស់ ៥០០ម៉ែត្រធៀបនឹងកម្ពស់ទឹកសមុទ្រ ។

**ការប្រើប្រាស់:** គេចាត់ថ្នាក់វាជាទិដ្ឋភាពដើមតូចដែលមានគុណភាពល្អសម្រាប់សិប្បកម្មតម្បាញ និងគ្រឿងសង្ហារឹម ។ គេប្រើវាសម្រាប់ធ្វើធ្នើរសៀវភៅ ។ គេក៏សកដើមវាដើម្បីត្បាញធ្វើកៅអី និងសាឡុងផងដែរ ។

**ពាណិជ្ជកម្ម:** ដើមវាគេប្រមូលសម្រាប់ការប្រើប្រាស់ក្នុងស្រុកផង នាំចេញទៅក្រៅប្រទេសផង ។ ដើមប្រវែង ៤-៥មមានតម្លៃពី ១៨០-៣៥០រៀល ។

# Calamus palustris Griff.



















១- ទីកន្លែងអង្កេតផ្តៅឈ្វាំង
២- សាឡុងធ្វើពីផ្តៅឈ្វាំង
៣- ទិដ្ឋភាពដើម
៤- ពកគល់ទងស្លឹក
៥- ស្លឹកបង្ហាញពីការតម្រៀបកូនស្លឹក
៦- ផ្លែមិនទាន់ទុំ

# ៥ Calamus tetradactylus Hance

ឈ្មោះខ្មែរ: សែសឹង (ផ្ដៅចង្រឹត រពាក់ ហាពាក់)

សទិសន័យ: *bonianus* Becc., *Calamus cambojensis* Becc., *Calamus tetradactylus* var. *bonianus* (Becc.) Conrard, *Palmijuncus tetradactylus* (Hance) Kuntze

## ការពិពណ៌នា

**ទិដ្ឋភាពដើម :** ដុះជាគុម្ព ដើមតោងឡើង ប្រវែងរហូតដល់ ៦-១០ម។

**ស្រទបស្លឹក:** មុខកាត់ទំហំ ០,៤-១,៨សម ពណ៌បៃតងចាស់ ឬបៃតងស្រាល ដើមខ្ចីមានជាតិម្សៅពណ៌ស។

**បន្លាស្រទប:** បន្លារង្វើល ទៅញឹកមធ្យម ប្រវែង ០,២-២សម បន្លានៅមាត់ស្រទបប្រវែងរហូតដល់៣សម ចង្អុរទៅគ្រប់ទិស គល់រមូល ពណ៌បៃតង ប្រែសន្សឹមៗទៅពណ៌ត្នោតនៅខាងចុង និងចុងពណ៌ខ្មៅ។

**ពកគល់ទងស្លឹក:** ច្បាស់ល្អ រាងទ្រនុង ពណ៌បៃតង គ្មានបន្លា។

**ស្រកីស្រទប:** ប្រវែងដល់ ០,២សម ពណ៌ត្នោត គ្មានរោមរឹង។

**ដៃតោង:** ប្រវែង ៣០-៧៥សម។

**ស្លឹក:** ប្រវែង ២០-៦៦សម ទងស្លឹកប្រវែង ៣-១៣សម ទ្រនុងស្លឹកប្រវែង ២៦-៥៣សម កូនស្លឹកនៅចុងស្លឹកជាប់គ្នា ១-២ភាគ៣របស់ប្រវែងកូនស្លឹក។ កូនស្លឹកតម្រៀបជា(១)២-៣(-៥)ក្រុម ក្រុមនីមួយៗមានកូនស្លឹកចំនួន ២-៤(-៥)។ កូនស្លឹកនៅទ្រនុងកណ្ដាលទំហំ ៨-២៤ x១,២-៥សម រាងផ្ទៃលំពែងទៅផ្ទៃលំពែងច្រាស់ បន្ទះកូនស្លឹកខាងលើមានរោមរឹងមួយៗ គល់ស្ងួច តែមមានរោមរឹងៗ ចុងស្ងួចមានផ្នែកលយដូចសក់ មានទ្រនុង៣ ចេញច្បាស់ល្អ។

**ដើម:** មុខកាត់ទំហំ ០,៣-១ម៉ែត្រ ចន្លោះថ្នាំងប្រវែង ១០-១៥សម។

**កញ្ចុំផ្កា:** ប្រវែង ៥០-១០០សម រួមទាំងដៃតោង ស្រទបស្រោបពីលើយ៉ាងណែន មានបន្លាខ្លី សំប៉ែតនៅមាត់ស្រទប ផ្កាឈ្មោលបែកជាបីទង ផ្កាញីបែកជាពីរទង។

**ផ្លែ:** ទំហំ ០,៥-០,៩ x ០,៥-០,៩សម រាងមូល ស្រកាសំបកពណ៌ចម្បើង តែមស្រកាពណ៌ត្នោត ទម្រត្របករាងជាបំពង់ចំពុះប្រវែងប្រហែល ០,១សម។

**គ្រាប់:** ជ្រួញតិចតួច។

**លក្ខណៈសំគាល់:** ប្រភេទនេះមានដើមរាងរាវ និងងាយស្គាល់ តាមរយៈកូនស្លឹកដែលតម្រៀបជាក្រុម ហើយកូនស្លឹកនៅចុងស្លឹកជាប់គ្នានៅគល់។ គួរកត់សំគាល់ឃើញថាសហគមន៍ខ្លះហៅវាថាផ្ដៅរពាក់ព្រោះវាមានទំហំប្រហែលរពាក់តែប្រភេទទាំងពីរនេះមានទីជម្រក និងលក្ខណៈរូបរាងខុសៗគ្នា ជាពិសេសដៃតោងគល់ទងស្លឹក បន្លា និងស្លឹក។

**លូតលាស់:** លូតលាស់បាន ២,៥-៣ម៉ែត្រក្នុងមួយឆ្នាំ។ សែសឹងដុះល្អក្នុងព្រៃស្រោង និងព្រៃពាក់កណ្ដាលស្រោងដែលមានគម្របម្លប់បង្គួរ។ គេអាចប្រមូលផលក្រោយពេលដាំបាន៧ឆ្នាំ និងផ្ដល់ទិន្នផល ១,២តោនក្នុងមួយឆ្នាំ (ធនធានរុក្ខជាតិនៅអាស៊ីអាគ្នេយ៍ ៦,១៩៩៤)។

**ទីកន្លែង:** ប្រភេទនេះដុះក្នុងតំបន់ទំនាប គ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា។

**ទីជម្រក:** ដុះក្នុងព្រៃល្បោះចម្រុះរិចរិល ដល់ព្រៃពាក់កណ្ដាលស្រោង។

**រយៈកម្ពស់:** ដុះនៅរយៈកម្ពស់រហូតដល់ ៣០០ម (រហូតដល់ ១០០០ម៉ែត្រ នៅឥណ្ឌូចិន)។

**ការប្រើប្រាស់:** មានឯកសារតិចតួចណាស់ ស្ដីអំពីការប្រើប្រាស់ប្រភេទនេះ។ សហគមន៍ខ្លះបានប្រាប់អោយដឹងថាដើមរបស់វាគេប្រើប្រាស់សម្រាប់ធ្វើល្អី និងខ្សែចងក្នុងប្រទេសកម្ពុជា។

**ពាណិជ្ជកម្ម:** ពុំមានឯកសារអំពីពាណិជ្ជកម្មរបស់ប្រភេទនេះនៅក្នុងប្រទេសកម្ពុជាទេ ក្រៅពីការប្រមូលសម្រាប់ការប្រើប្រាស់ជាលក្ខណៈគ្រួសារ។ ក៏ប៉ុន្តែប្រទេសជិតខាងដូចជាប្រទេសឡាវ និងវៀតណាមប្រើប្រាស់ប្រភេទនេះច្រើនសម្រាប់ធ្វើគ្រឿងតម្បាញ។

# **Calamus tetradactylus** Hance





















១- ទីកន្លែងអង្កេតសែសឹង

២- ល្អីធ្វើពីសែសឹង

៣- ទិដ្ឋភាពដើម

៤-ពកគល់ទងស្លឹកបង្ហាញពីរូបរាងផ្សេងៗ

៥- ផ្លែខ្ចី

៦- ស្លឹក

# ៦ Calamus viminalis Willd

ឈ្មោះខ្មែរ: ផ្តៅក្រែក (ផ្តៅគោក ផ្តៅល្វីង ត្រែសស ផ្តៅកន្ទេល)

សទិសន័យ: *Calamus extensus* Mart., *Calamus fasciculatus* Roxb., *Calamus litoralis* Blume, *Calamus pseudorotang* Mart., *Calamus viminalis var. fasciculatus* (Roxb.) Becc., *Calamus viminalis* var. *fasciculatus* subvar. *andamanicus* Becc., *Calamus viminalis* var. *fasciculatus* subvar. *bengalensis* Becc., *Calamus viminalis* var. *fasciculatus* subvar. *cochinchinensis* Becc., *Calamus viminalis* var. *fasciculatus* subvar. *pinangianus* Becc., *Palmijuncus fasciculatus* (Roxb.) Kuntze, *Palmijuncus litoralis* (Blume) Kuntze, *Palmijuncus pseudorotang* (Mart.) Kuntze, *Palmijuncus viminalis* (Willd.) Kuntze, *Rotang viminalis* (Willd.) Baill.

## ការពិពណ៌នា

**ទិដ្ឋភាពដើម :** ដុះជាគុម្ព ដើមតោងឡើង ប្រវែងរហូតដល់ ៣៥ម ។

**ស្រទបស្លឹក:** មុខកាត់ទំហំ ០,៥-៣សម ពណ៌បៃតង ស្រទបខ្ចីមានជាតិម្សៅពណ៌ស ជ្រុះអស់ពេលដើមពេញវ័យ ។

**បន្លាស្រទប:** បន្លារង្វើលដល់ញឹកមធ្យមប្រវែង៤សម គល់រមូលសំប៉ែត ពណ៌ទឹកក្រូច-បៃតងខ្ចី ចុងពណ៌ត្នោតចាស់ទៅពណ៌ខ្មៅ ។

**ពកគល់ទងស្លឹក:** ច្បាស់ល្អ រាងពក ពណ៌បៃតង គ្មានបន្លា ។

**ស្រកីស្រទប:** ប្រវែងរហូតដល់ ០,៥សម ពណ៌ប្រផេះ គ្មានបន្លា ។

**ដៃតោង:** ដៃតោងគល់ទងស្លឹក ប្រវែងដល់ ៣០០សម ។

**ស្លឹក:** ប្រវែង ១៥០-២៥០សម ទងស្លឹកប្រវែង ៥-៣៥សម ទ្រនុងស្លឹកប្រវែង ១៥០-២១០សម ជាទូទៅគ្មានបន្លានៅពោះទងស្លឹក និងខាងខ្នងទងស្លឹកជួនកាលមានបន្លានៅតាមគែមទងស្លឹកប្រវែងដល់ ០,៣សម ។ កូនស្លឹកតម្រៀប២០-៣០ក្រុមមិនសូវច្បាស់ ក្រុមនីមួយៗមានកូនស្លឹក២-៧ តម្រៀបខុសៗគ្នាជាច្រើនជួរ កូនស្លឹកមួយគូរ នៅចុងស្លឹកឆែកនៅត្រង់គល់ ។ កូនស្លឹកធំបំផុតទំហំ ១១-៣៥ x ០,៧-១,៥សម គល់កូនស្លឹកស្តួចគែមមានបន្លា រឹងមួយៗ ចុងស្តួចវែង ទ្រនុងកណ្តាលផុសឡើងបន្ទះកូនស្លឹកទាំងសងខាងមានរោមរឹងមួយៗ ។

**ដើម:** មុខកាត់ទំហំ ០,៥-១,៧ម៉ែត្រ ចន្លោះថ្នាំងប្រវែង ១០-៣០ម ។

**កញ្ចុំផ្កា:** ប្រវែង ២-៤ម កូនកញ្ចុំផ្កាមានពី ២-៧ ផ្កាញីបែក ២-៣ទង មានកូនទងតូចៗ និងផ្កាជាច្រើន ស្របទងកញ្ចុំផ្កាទីមួយស្រោបទងកញ្ចុំផ្កាយ៉ាងណែន មានរាងជាបំពង់ មានបន្លា ។

**ផ្លែ:** ទំហំ ០,៧-១ x ០,៧-១សម រាងមូល ទម្រត្របកឆែកទាំងស្រុង ចំពុះប្រវែង ០,១សម ស្រកាសំបកពណ៌ចំបើងខ្ចី គែមពណ៌ប្រផេះចាស់ ។

**គ្រាប់:** មិនជ្រួញ ។

**សំគាល់ពិសេស:** ផ្តៅក្រែកមានរូបរាងសំខាន់ៗមួយចំនួនដូចជា វត្តមានរបស់ពកគល់ទងស្លឹក ដៃតោង គល់ទង ស្លឹក និងកូនស្លឹកតម្រៀបជាក្រុម ។ ប្រភេទនេះ មានក្រុមកូនស្លឹកច្រើនជាងប្រភេទប្រហាក់ប្រហែលគ្នា ហើយចំនួនបន្លានៅលើស្រទបស្លឹកប្រែប្រួលពីមួយដល់ច្រើនជួនកាលគេអាចច្រឡំវាជាមួយផ្តៅទឹកពេលមើលមួយភ្លែត ។ ប៉ុន្តែវាខុសគ្នាត្រង់ថាផ្តៅទឹកមានកូនស្លឹកឈមដាច់ៗ ហើយនៅតាមលើជួរតែមួយ ។

**លូតលាស់:** ដុះលូតលាស់ ២,២៥មក្នុងមួយឆ្នាំ ។

**ទីកន្លែង:** ដុះរាយប៉ាយគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ។

**ទីជម្រក:** ប្រភេទនេះចូលចិត្តដុះនៅទីកន្លែងស្ងួត ជាងប្រភេទផ្តៅផ្សេងៗ ។ វាដុះនៅក្នុងព្រៃពាក់កណ្តាលស្រោងព្រៃល្បោះចម្រុះ និងតាមដំបូកក្នុងព្រៃល្បោះឪបតេរ៉ូកាប ហើយវាធន់ទៅនឹងភ្លើងព្រៃបានល្អ ។

**រយៈកម្ពស់:** ដុះនៅរយៈកម្ពស់ ៥០-៥០០ម ។

**ការប្រើប្រាស់:** ដើមវាល្អមានទំហំមធ្យមសម្រាប់ធ្វើគ្រឿងតម្បាញ និងសង្ហារឹម ។ ផលិតផលមួយចំនួនធំ ដែលផលិតពីប្រភេទនេះរួមមាន ដៃល្អី ល្អី កន្ទេល ។ គេប្រើប្រាស់វាសម្រាប់ធ្វើជញ្ជាំង កម្រាល ធ្នើរ ត្រែ កៅអី និងសាឡុង ។

**ពាណិជ្ជកម្ម:** ដើមប្រវែង ៤-៥ម៉ែត្រ តម្លៃ ២២០-៣៥០រៀល ។ ដើមរបស់វាគេប្រមូលច្រើនណាស់នៅក្នុងប្រទេសសម្រាប់តម្រូវការទីផ្សារក្នុងស្រុក និងអន្តរជាតិ ដូច្នេះហើយប្រភេទនេះគេប្រមូលលើសលប់នៅសព្វថ្ងៃនេះ ។

# **Calamus viminalis** Willd














១- ទីកន្លែងអង្កេតផ្តៅក្រែក

២- ធុងសម្រាមធ្វើពីផ្តៅក្រែក

៣- ទិដ្ឋភាពដើម

៤- ពកគល់ទងស្លឹក

៥- ស្លឹកបង្ហាញពីការតម្រៀប កូនស្លឹកៈ

៦- ផ្លែ

## ៧ Calamus bousigonii Becc.

ឈ្មោះខ្មែរ: ផ្តៅអារ៉ែច
សទិសន័យ: មិនមាន

### ការពិពណ៌នា

**ទិដ្ឋភាពដើម:** ដុះមួយៗ ឬដុះជាគុម្ពដែលមាន ២-៣ដើមក្នុងមួយគុម្ព ដើមតោងឡើង ប្រវែងដល់ ១៥ម។
**ស្រទបស្លឹក:** មុខកាត់ទំហំ ០,៧-១,៥សម ពណ៌បៃតងចាស់។
**បន្លាស្រទប:** បន្លាច្រើនបង្គរប្រវែង ០,៥-២សម គល់រាងពក ពណ៌បៃតង រាងដូចម្ជុល ពណ៌ត្នោត ចុងពណ៌ខ្មៅ។
**ពកគល់ទងស្លឹក:** ច្បាស់ល្អ រាងទ្រនុង គ្មានបន្លា ឬមានតិចតួចបំផុត ពណ៌បៃតងលាយលឿង។
**ស្រកីស្រទប:** ប្រវែង ០,១-០,៣ សម លយចេញពីទងស្លឹក គ្មានបន្លា ឬរោមរឹង ពណ៌ប្រផេះចាស់។
**ដៃតោង:** ដៃតោងចុងស្លឹកប្រវែង ៦០-១៧០សម។
**ស្លឹក:** ទងស្លឹកប្រវែង ៦-២២សម ទ្រនុងស្លឹកប្រវែង ៣៧-៦៦សម ទងស្លឹកគ្មានចង្អូរ មានរោមរឹង និងបន្លាមួយៗ នៅចំហៀងនីមួយៗមានកូនស្លឹកចំនួន៦-៨ តម្រៀបតាមជួរស្មើគ្នា កូនស្លឹកនៅទ្រនុងកណ្តាលទំហំ ១០-២០ x ៤-៨សម រាងដូចពេជ្រ គល់ស្តួច-អត់ស្មើគ្នា គែមមានរោមរឹងៗច្រើន ចុងស្តួចវែង មានទ្រនុងចំនួន ៦-៨ ផុសចេញច្បាស់ៗ បន្ទះកូនស្លឹកទាំងសងខាងគ្មានរោមរឹង។
**ដើម:** មុខកាត់ទំហំ ០,៨-១,១សម ចន្លោះថ្នាំងប្រវែង ៨-២៣សម ជាប់មាំល្អ ទន់ងាយបត់បែន។
**កញ្ចុំផ្កា:** មិនមានព័ត៌មាន។
**ផ្លែ:** ទំហំ ១,៨សម រាងស្ទើរស្វ៊ែរ។
**គ្រាប់:** ទំហំ ៩,៥ x ៧មម រាងពងក្រពើ ជ្រាវជ្រួញ។

**លក្ខណៈសំគាល់:** លក្ខណៈពិសេសរបស់ប្រភេទនេះគឺ ស្លឹករាងដូចពេជ្រ គែមកូនស្លឹកមានរោមរឹងៗច្រើន និងគល់បន្លារាងពក។
**លូតលាស់:** អាចលូតលាស់បាន ១,៥-២ម ក្នុងមួយឆ្នាំ។
**ទីកន្លែង:** រកឃើញនៅក្នុងតំបន់ចំនួនពីរគឺ តំបន់ទំនាបក្នុងឧទ្យានជាតិ បូកគោប៉ែកនីរតីនៃប្រទេសកម្ពុជា និងតំបន់អភិរក្សជីវចម្រុះសីមា ភាគឥសាន្តប្រទេសកម្ពុជា។
**ទីជម្រក:** ប្រភេទព្រៃពាក់កណ្តាលស្រោង ដល់ព្រៃស្រោង។
**រយៈកម្ពស់:** ដុះនៅរយៈកម្ពស់ ១០០-១០០០ម។
**ការប្រើប្រាស់:** ដើមជាប់មាំល្អ ដូច្នេះគេប្រើប្រាស់វាសម្រាប់ធ្វើជាខ្សែពួរ និងគ្រឿងតម្បាញសម្រាប់ប្រើប្រាស់នៅតាមផ្ទះ។
**ពាណិជ្ជកម្ម:** គ្រួសារខ្លះដែលរស់នៅក្បែរឧទ្យានជាតិបូកគោបានរាយការណ៍ថា ពួកគាត់ប្រមូលដើមរបស់វាសម្រាប់លក់ទៅអោយអ្នកនេសាទត្រីនៅបឹងទន្លេសាបសម្រាប់ក្រងព្រួល។

# *Calamus bousigonii* Becc.
















១- ទីកន្លែងអង្កេតផ្តៅអារ៉េច   ២- ទិដ្ឋភាពដើម

៣- ស្រទប   ៤- ស្លឹកបង្ហាញពីការតម្រៀបកូនស្លឹក   ៥-រូបរាងស្លឹក

# ៨ Calamus rudentum Lour.

ឈ្មោះខ្មែរ: ផ្ដៅដំបង
សទិសន័យ: *Palmijuncus rudentum* (Lour.) Kuntze, *Rotang rudentum* (Lour.) Baill.

## ការពិពណ៌នា

**ទិដ្ឋភាពដើម:** ដុះជាគុម្ព ដើមតោងឡើង ប្រវែង ៣០-៤៥សម។
**ស្រទបស្លឹក:** មុខកាត់ទំហំ ២,៥-៧សម ពណ៌បៃតងខ្ចី ឬពណ៌លឿង។
**បន្លាស្រទប:** បន្លាវែង តម្រៀបជាជួរទទឹងវែងៗ និងមានបន្លាខ្លីៗនៅចន្លោះជួរនីមួយៗ បន្លាប្រវែង ៥-៧សម បន្លានៅជិតមាត់ស្រទបប្រវែងដល់ ១០សម គល់បន្លាពណ៌ លឿង-ត្នោតខ្ចី ផ្នែកកណ្ដាលសំប៉ែត ពណ៌ចម្បើង ចុងពណ៌ខ្មៅ បន្លាលើស្រទបស្លឹកចង្អុរចុះក្រោម បន្លាមាត់ស្រទបចង្អុរឡើងលើ។
**ពកគល់ទងស្លឹក:** មិនសូវច្បាស់ ពណ៌បៃតងខ្ចី មានបន្លាញឹកស្អេកស្កះ។
**ស្រកីស្រទប:** ប្រវែង ៥-១០សម សម្បុរដោយរោមរឹងៗ ពណ៌ប្រផេះ ឆាប់ពុក។
**ដៃតោង:** ដៃតោងគល់ទងស្លឹកប្រវែង ៤-៨ម មានបន្លាញឹកមធ្យម តម្រៀបជាជួរនៅគល់ដៃតោង។
**ស្លឹក:** ទងស្លឹកប្រវែង ២០-៦៣សម ទ្រនុងស្លឹកប្រវែង ១៦០-៣៨០សម។ ពោះទងស្លឹកមានចង្អូរ គ្មានបន្លា ខាងខ្នងមានបន្លា តែមទងស្លឹកមានបន្លាចង្អុរឡើងលើប្រវែងដល់ ១៨សម កូនស្លឹកមួយគូរនៅចុងស្លឹកជាប់គ្នាជិតពាក់កណ្ដាល។ កូនស្លឹកតម្រៀបឈមម្ខាងៗមានចំនួន៣៥-៦០។ កូនស្លឹកនៅទ្រនុងកណ្ដាលទំហំ ៤០-៦៥ x១-៥សម គល់មូល តែមមានរោមរឹងៗ ចុងស្លួចវែង មានរោមរឹងច្រើន ទ្រនុងកណ្ដាលផុសឡើង រោមរឹងប្រវែង ២,៥-៣,៥ សម។
**ដើម:** មុខកាត់ទំហំ ១,៨-៣,៥ម៉ែត្រ ចន្លោះថ្នាំងប្រវែង ១២-២០សម និងជាប់មាំល្អ។
**កញ្ចុំផ្កា:** ប្រវែងសរុប ៣៥០-៧៥០សមបូករួមទាំងដៃតោងគល់ទងស្លឹក ផ្កាញីបែកជាពីរទង ផ្កាឈ្មោលបែកជាបីទង ស្រទបរបស់ទងមេមានរាងបំពង់ មានបន្លាមធ្យម រាងសំប៉ែតដូចសន្លឹកក្រដាស់នៅមាត់ស្រទប។
**ផ្លែ:** ទំហំ ១,៤-១,៨ x ០,៧-១,២សម ទម្រង់ត្របកឆែកនៅគល់ ចំពុះប្រវែង ០,២-០,៣សម សំបកស្រកាស្ងួតពណ៌លឿង-ទឹកក្រូច តែមពណ៌ទងដែងព្រលែត។

**លក្ខណៈសំគាល់:** ផ្ដៅដំបងប្លែកពីប្រភេទផ្សេងៗទៀត តាមរយៈរូបរាងសំខាន់ៗមួយចំនួនដូចជា បន្លាច្រើន ពណ៌ចម្បើង ចុងពណ៌ខ្មៅ។ គេកត់សំគាល់ឃើញថាស្រកីស្រទបប្រភេទនេះវែង និងមានបន្លា តែគេកម្រឃើញណាស់ព្រោះវាពុកផុយ ហើយឆាប់របេះដាច់។ ដៃតោងគល់ទងស្លឹកមានប្រវែងរហូតដល់៨ម ហើយមុខកាត់គល់របស់វាទំហំ ០,៤-០,៨សម និងដុះពេញដោយបន្លា បន្ទះកូនស្លឹកមានរោមវែងៗ។
**លូតលាស់:** ដុះលូតលាស់បាន ១ម៉ែត្រក្នុងមួយឆ្នាំ។
**ទីជម្រក:** ព្រៃពាក់កណ្ដាលស្រោង និងព្រៃតាមមាត់ទឹកដែលព័ទ្ធជុំវិញដោយព្រៃល្បោះឪបតេរ៉ូកាប។
**រយៈកម្ពស់:** ដុះនៅរយៈកម្ពស់ ៥០-៣០០ម។
**ការប្រើប្រាស់:** ដើមរបស់វាគេប្រើប្រាស់សម្រាប់ធ្វើស៊ុម និងឆ្អឹងទម្រគ្រឿងសង្ហារឹមគ្រប់ប្រភេទរួមមាន ធ្នើរសៀវភៅ គ្រែ កៅអី ។ល។ វាមានមុខកាត់ធំ ជាប្រភេទផ្ដៅដែលមានគុណភាពល្អសម្រាប់គ្រឿងសង្ហារឹម ដែលមានតម្រូវការខ្ពស់ ដូច្នេះហើយនាំអោយមានការប្រមូលផលច្រើនលើសលប់។
**ពាណិជ្ជកម្ម:** នៅភ្នំពេញ ដើមប្រវែង ៤-៥ម៉ែត្រ មានតម្លៃ ៤០០០រៀល ប៉ុន្តែនៅតាមភូមិតម្លៃវាប្រែប្រួលពី ៥០០-៣៣០០រៀលក្នុងមួយដើម។ វាជាប្រភេទមួយដែលមានតម្លៃខ្ពស់ជាងគេបង្អស់។ មានរបាយការណ៍មកថាប្រភេទនេះគេនាំចេញទៅវៀតណាម និងហុងកុង តែមិនដឹងបរិមាណនាំចេញទេ។

# **Calamus rudentum** Lour.












១- ទីកន្លែងអង្កេតផ្ដៅដំបង ២- ឡប់ឡែធ្វើពីផ្ដៅដំបង

៣- ទិដ្ឋភាពដើម ៤- ពកគល់ទងស្លឹក ៥-ផ្លែ

# Calamus sp.

ឈ្មោះខ្មែរៈ ផ្តៅទឹកឃ្មុំ
សទិសន័យៈ មិនមាន

## ការពិពណ៌នា

**ទិដ្ឋភាពដើមៈ** ដុះជាគុម្ព ដើមតោងឡើង ប្រវែង ១៥-៧០ម៉ែត្រ។
**ស្រទបស្លឹកៈ** មុខកាត់ទំហំ ១,៥សម ពណ៌បៃតង មានជាតិម្សៅពណ៌ខ្មៅ។
**បន្លាស្រទបៈ** បន្លារធ្វើលប្រវែង ០,១-០,២សម គល់រាងដូចកោន ពណ៌បៃតង ចុងបន្លាពណ៌ត្នោតក្រម៉ៅ។
**ពកគល់ទងស្លឹកៈ** ច្បាស់ល្អ រាងទ្រនុង ពណ៌បៃតង បន្លាដុះមួយៗ ជាជួរលើទ្រនុង។
**ស្រកីស្រទបៈ** ប្រវែង ០,២-០,៤សម ពណ៌ប្រផេះ គ្មានបន្លា។
**ដៃតោងៈ** ដៃតោងគល់ទងស្លឹកប្រវែង ១,៥-៣សម។
**ស្លឹកៈ** ទងស្លឹកប្រវែង ១៥សម គ្មានចង្អូរ ទ្រនុងស្លឹកប្រវែង ៧៥-៨៤សម កូនស្លឹកនៅចុងស្លឹកឆែកត្រង់គល់។ កូនស្លឹកតម្រៀបឈមឃ្លាតពីគ្នា ៣-៤សម កូនស្លឹកនៅទ្រនុងកណ្តាលទំហំ ៣៥-៣៦,៥ x ១,៥-១,៧សម គល់កូនស្លឹកទាល តែមានរោមរឹងមួយៗ ចុងស្ទួចវែង ទ្រនុងមានបីផុសឡើងច្បាស់ មានរោមរឹងមួយៗ។
**ដើមៈ** មុខកាត់ទំហំ ១-២,៣សម ចន្លោះថ្នាំងប្រវែង ១២-៣០សម រឹងមាំល្អ និងទន់។
**កញ្ចុំផ្កាៈ** មិនមានព័ត៌មាន។
**ផ្លែៈ** មិនមានព័ត៌មាន។
**គ្រាប់ៈ** មិនមានព័ត៌មាន។

**លក្ខណៈសំគាល់ៈ** តាមលក្ខណៈលូតលាស់ ប្រភេទនេះស្រដៀងគ្នាទៅនឹងផ្តៅទឹក(*C. siamensis*) ទាំងប្រភេទលូតលាស់ការតម្រៀបកូនស្លឹក និងដៃតោង ប៉ុន្តែខុសប្លែកគ្នាត្រង់បន្លារបស់វាខ្លីជាង និងគល់រាងពក និងពកគល់ទងស្លឹកពុំសូវច្បាស់ដូចផ្តៅទឹក។ លើសពីនេះទៀត វាមានឬសប្រចាក់។
**លូតលាស់ៈ** ពីកូនសំណាបដល់ដើមពេញវ័យ វាត្រូវការរយៈពេល ៧-៩ឆ្នាំ។
**ទីកន្លែងៈ** ប្រភេទនេះហាក់ដូចជាមានតែនៅប៉ែកនិរតី ចាប់តាំងពីដែនជម្រកសត្វព្រៃភ្នំសំកុស។
**ទីជម្រកៈ** ប្រភេទព្រៃស្រោង ចូលចិត្តដុះតាមដងអូរ/ស្ទឹង ដែលលិចទឹកម្តងម្កាលពេលភ្លៀង។
**រយៈកម្ពស់ៈ** ដុះនៅរយៈកម្ពស់ ៣០០-៥០០ម។
**ការប្រើប្រាស់ៈ** ដោយសារតែដើមជាប់មាំ និងទន់ងាយបត់បែន គេចូលចិត្តប្រើវាសម្រាប់ធ្វើជាស៊ុម ឬគ្រោងគ្រឿងសង្ហារិមដូចជា ធ្នើរសៀវភៅ គ្រែ និងកៅអី។
**ពាណិជ្ជកម្មៈ** គេប្រមូលវាយ៉ាងច្រើនដើម្បីលក់ទៅប្រទេសថៃ ដូច្នេះប្រភេទនេះទទួលរងការប្រមូលផលលើសកម្រិត។ នៅខេត្តបាត់ដំបង ដើមប្រវែង ៤-៥ម៉ែត្រ តម្លៃ ៧០០រៀល និងនៅស្រុកក្រវាញ ខេត្តពោធិសាត់ តម្លៃ ៩០០-១១០០រៀល។

# *Calamus* sp.
















១- ទីកន្លែងអង្កេតផ្ដៅទឹកឃ្មុំ ២- ធ្នើរសៀវភៅធ្វើពីផ្ដៅទឹកឃ្មុំ ៣- ទិដ្ឋភាពដើម

៤- ស្លឹកបង្ហាញពីការតម្រៀបកូនស្លឹក ៥- ពកគល់ទងស្លឹក

# ១០ *Calamus guruba* Buch - Ham

ឈ្មោះខ្មែរ: ផ្តៅអាចម៍មាន់ (ផ្តៅត្រែស ត្រែសអាចម៍មាន់)
សទិសន័យ: *Calamus guruba* var. *ellipsoideus* S. Y. Chen & K. L. Wang, *Calamus mastersianus* Griff., *Calamus multirameus* Ridl., *Calamus nitidus* Mart., *Daemonorops guruba* (Buch.-Ham.) Mart., *Daemonorops guruba* var. *hamiltonianus* Mart., *Daemonorops guruba* var. *mastersianus* (Griff.) Mart., *Palmijuncus guruba* (Buch.-Ham.) Kuntze, *Palmijuncus nitidus* (Mart.) Kuntze

## ការពិពណ៌នា

**ទិដ្ឋភាពដើម :** ដុះជាគុម្ព ដើមតោងឡើង ប្រវែង ៨-១០ម៉ែត្រ ។
**ស្រទបស្លឹក:** មុខកាត់ទំហំ ១-៣សម ពណ៌បៃតងចាស់ ។
**បន្លាស្រទប:** សម្បុរបន្លា និងមានលាយបន្លាវែង-ខ្លី ចង្អុរឡើងលើ ប្រវែងប្រហែល ៣,៥សម និងរហូតដល់៧សម នៅមាត់ស្រទបរាងសំប៉ែតពីគល់ដល់ចុង ពណ៌បៃតងលាយត្នោតស្រាល នៅគល់ពណ៌ត្នោតចាស់ ឬក្រម៉ៅនៅខាងចុង ។
**ពកគល់ទងស្លឹក:** ចេញច្បាស់ រាងដុំពក បន្លាញឹក ពណ៌លឿង-បៃតងខ្ចី ។
**ស្រកីស្រទប:** ប្រវែងជិត១០សមស្តើងដូចក្រដាស់គ្មានរោមរឹង រាងត្រកួញ (រមួល) ដាច់ជ្រុះបណ្តើរៗពេលដើមកាន់តែចាស់ ។
**ដៃតោង:** ដៃតោងគល់ទងស្លឹកប្រវែង៣-៤ម៉ែត្រ ។
**ស្លឹក:** ប្រវែង ៦០-១៦០ម៉ែត្រ ទងស្លឹកប្រវែង ១០-២៥សម មានចង្អុរ មានបន្លាខ្លីៗពាសពេញទងស្លឹក ខាងខ្នងទងស្លឹក និងតាមគែមទងស្លឹក មានបន្លាវែងៗដុះជាជួរ កូនស្លឹកនៅចុងស្លឹកឆែកត្រឹមគល់ ។ កូនស្លឹកតម្រៀបលើជួរតែមួយស្មើរឈមគ្នា ឃ្លាតគ្នាពីមួយទៅមួយប្រវែង ១,៣-៣សម ។ កូនស្លឹកធំជាងគេទំហំ ៣០-៤៥ x ១-២,៥សម រាងទ្រវែង គល់ស្តួច តែមមានរោមរឹងៗ ចុងស្តួចវែង ទ្រនុងកណ្តាលផុសឡើង ទ្រនុងខាងមាន៤ ច្បាស់ល្អ បនះស្លឹក ទាំងសងខាងមានរោមរឹងៗ ។
**ដើម:** មុខកាត់ទំហំ ០,៥-២សម ចន្លោះថ្នាំងប្រវែង ៥-២០សម សាច់ក្នុងផុសៗ មិនអាចពត់បាន ។
**កញ្ចុំផ្កា:** ប្រវែង ៣០-២៥០សម បូករួមទាំងដៃតោង កូនកញ្ចុំផ្កាចំនួន៣-៥ ផ្កាឈ្មោលបែកជាបីទង រាងបត់បែន កញ្ចុំផ្កាញីបែកជាពីរទង ស្រទបជាប់នឹងទងកញ្ចុំផ្កា រាងបំពង់នៅត្រង់គល់ និងឆែកជាបន្ទះស្តើងនៅមាត់ស្រទប ។ ស្រទបប្រវែង៤០សម ពណ៌ត្នោត ទ្រនុងកណ្តាល និងតែមមានរោមរឹងៗ ។
**ផ្លែ:** ទំហំ ០,៦-០,៨ x ០,៦-០,៨សម រាងមូល ស្រកាសំបករបស់ផ្លែខ្ចីពណ៌បៃតងចាស់ ពេលស្ងួតប្រែទៅពណ៌លឿង និងគែមពណ៌ត្នោត ទម្រត្របកមាន៦ និងចំពុះប្រវែង ០,១-០,២សម ។
**គ្រាប់:** មិនជ្រួញ ។

**លក្ខណៈសំគាល់:** ប្រភេទនេះខុសពីប្រភេទក្នុងពួកផ្សេងៗទៀត តាមរយៈបន្លាស្រទបចង្អុរឡើងលើ កូនស្លឹកតម្រៀបឈម និងជាទូទៅនៅជិតៗគ្នាមានពកគល់ទងស្លឹក និងច្បាស់ល្អ ស្រទបស្លឹកខ្ចី និងពេញវ័យមានស្រកីវែង និងកញ្ចុំផ្កាមានស្រទបវែង ។ គេអាចច្រឡំវាជាមួយពួក *Daemonorops* ប៉ុន្តែវាមានដៃតោងគល់ទងស្លឹកមិនមែនដៃតោងចុងស្លឹកទេ ហើយបន្លាស្រទបមានពណ៌ខុសគ្នា ។ សំណាកដែលប្រមូលពីខេត្តកំពង់ធំ មានរូបរាងខុសគ្នាមួយចំនួនដូចជា ពកគល់ទងស្លឹករាងទ្រនុង ដើមតូចជាង និងបន្លាស្រទបចង្អុរគ្រប់ទិស ។ គួរធ្វើការសិក្សា រូបរាងសំណាកនេះបន្ថែមទៀត ដោយប្រុងប្រយ័ត្នដើម្បីបញ្ជាក់អំពីប្រភេទអោយបានច្បាស់ ។
**លូតលាស់:** លូតលាស់បាន ១-១,៥ម៉ែត្រក្នុងមួយឆ្នាំ ។
**ទីកន្លែង:** ប្រភេទនេះមានរបាយពីឧទ្យានជាតិបូកគោរហូតដល់តំបន់សំឡូត នៅតំបន់ភាគខាងលិចនៃប្រទេស ។
**ទីជម្រក:** រាយប៉ាយពីតំបន់គ្មានគម្របព្រៃ ដល់ព្រៃស្រោង ។ ដុះនៅតាមតំបន់មានកម្ពស់ទឹកភ្លៀងខ្ពស់ លើដីអាសុីតខ្ពស់ ។
**រយៈកម្ពស់:** រយៈកម្ពស់ប្រហែល ៣០០ម (រយៈកម្ពស់ ៧៥០ម៉ែត្រនៅប្រទេសថៃ) ។
**ការប្រើប្រាស់:** សាច់ក្នុងរបស់ដើមនេះផុយៗ ដូច្នេះដើមរបស់វាមិនអាចធ្វើគ្រឿងសង្ហារឹមបានទេ ។ ប៉ុន្តែដើមរបស់វាអាចពុះជាបួនចំរៀកសម្រាប់ក្រង និងធ្វើខ្សែចង ។
**ពាណិជ្ជកម្ម:** ពុំទាន់មានសេចក្តីរាយការណ៍អំពីទូរលេខពាណិជ្ជកម្មច្បាស់លាស់ទេ រហូតមកដល់ពេលនេះ ។ គេប្រមូលប្រភេទនេះសម្រាប់តែការប្រើប្រាស់ក្នុងស្រុកតែប៉ុណ្ណោះ តែមិនដើម្បីការនាំចេញទេ ដោយសារតែមានគុណភាពអន់ ។ ដើមរបស់វាពុះជាបួនចំរៀក ហើយលក់ក្នុងតម្លៃ ១០០រៀលក្នុងមួយចំរៀក ។

# **Calamus guruba** Buch - Ham



















១- ទីកន្លែងអង្កេតផ្តៅអាចម៍មាន់ ២- កៅអីធ្វើពីផ្តៅអាចម៍មាន់

៣- ទិដ្ឋភាពដើម ៤- ពកគល់ទងស្លឹក

៥- ស្លឹកដែលបង្ហាញពីការតម្រៀបកួនស្លឹក ៦- ផ្លែ

## ១១ *Calamus siamensis* Becc.

ឈ្មោះខ្មែរ: ផ្តៅទឹក

សទិសន័យ: *C. siamensis* Becc. var. *malaianus* Furtado

### ការពិពណ៌នា

**ទិដ្ឋភាពដើម :** ដុះជាគុម្ព ដើមតោងឡើងប្រវែងដល់ ២០ម៉ែត្រ។

**ស្រទបស្លឹក:** មុខកាត់ទំហំ ០,៧-២សម ពណ៌បៃតង ដើមខ្ចីមានជាតិម្សៅពណ៌ស លាយប្រផេះ ឬពេលខ្លះពណ៌ត្នោត ជ្រុះអស់ពេលដើមកាន់តែចាស់។

**បន្លាស្រទប:** បន្លាញឹកមធ្យមទៅរង្វើលប្រវែងដល់ ៤សម កម្រមានដល់ ៧សមណាស់ គល់រមូល ពណ៌បៃតង បន្លាសំប៉ែត ពីគល់ដល់ចុង ផ្នែកបន្លាខាងលើពណ៌លឿង-បៃតង ទៅពណ៌ត្នោត ចុងពណ៌ត្នោតក្រម៉ៅ ឬពណ៌ខ្មៅ។

**ពកគល់ទងស្លឹក:** ច្បាស់ល្អ រាងពក ពណ៌បៃតងចាស់ គ្មានរោម។

**ស្រកីស្រទប:** ប្រវែង០,៧-១,៤សម ឆាប់ពុកផុយ និងរបេះដាច់នៅសល់តែស្រកីស្រទបខ្ចី ពណ៌ប្រផេះចាស់ គ្មានរោម។

**ដៃតោង:** ដៃតោងគល់ទងស្លឹកប្រវែង ១០០-១៧៥សម។

**ស្លឹក:** ប្រវែង ៧០-១២០សម ទងស្លឹកប្រវែង៧-២២សម ទ្រនុងប្រវែង៧១-៧៩សម ទងស្លឹកមានបន្លារង្វើល និងវែងៗ កូនស្លឹកនៅចុងស្លឹកឆែកត្រឹមគល់។ កូនស្លឹក តម្រៀបឈម ឬឈមដាច់ៗ តម្រៀបលើជួរតែមួយ ម្ខាងៗមានចំនួន ៣៥-៤៥ កូនស្លឹកទំហំ ១១-១៣ x ១-២សម រាងទ្រវែង បន្ទះស្លឹកខាងលើពណ៌បៃតងចាស់ រោមរឹងៗ គល់ស្តួចតែមស្លឹកមានរោមរឹងរង្វើល ចុងស្តួចវែង ចុងឆ្មា ទ្រនុងកណ្តាលផុសឡើង បន្ទះកូនស្លឹកទាំងសងខាងមានរោមរឹងៗ។

**ដើម:** មុខកាត់ទំហំ ០,៥-២សម ចន្លោះថ្នាំងប្រវែង ១២-២៥សម ជាប់មាំល្អ មិនទន់ល្អ។

**កញ្ចុំផ្កា:** ប្រវែង ៦០-៣០០សមបូករួមទាំងដៃតោង កូនកញ្ចុំផ្កាមានចំនួន ៣-៥កម្រមានមួយណាស់ ស្ទបទងកញ្ចុំផ្ការាងបំពង់នៅជាប់ទៅនឹងទង។ កញ្ចុំផ្កាញីបែកជាពីរទង ទងទី២ប្រវែង ៨-៣០សម រាងបត់បែន ស្រទបទងទីពីរមានបន្លារង្វើល។ កញ្ចុំផ្កាឈ្មោលបែកជា៣ទង កូនទងវែង ឬស្មើ១សម ចេញផ្កាពេញទង។

**ផ្លែ:** ប្រវែង ០,៧-០,៩ x ០,៨-១សម រាងស្ទើរមូល ស្រកាសំបកពណ៌ស ទម្រត្របកឆែកនៅគល់ ចំពុះខ្លី។

**គ្រាប់:** មិនជ្រួញ។

**លក្ខណៈសំគាល់:** ប្រភេទនេះស្រដៀងទៅនឹងផ្តៅក្រែក តាមរយៈរូបរាងមួយចំនួនដូចជា ទិដ្ឋភាពដើម បន្លាស្រទប ពកគល់ទងស្លឹក ដៃតោងគល់ទងស្លឹក និងស្រកីស្រទប។ ចំនុចខុសប្លែកគ្នាដ៏សំខាន់គឺ ការតម្រៀបកូនស្លឹកជាជួរ និងឈមគ្នាឥតដាច់ ឬឈមដាច់ៗ។ ដូចប្រភេទជាច្រើនទៀតដែរ បន្លាស្រទបប្រែប្រួលពីតិចតួច ដល់ញឹកមធ្យម។ ប្រភេទនេះ គេក៏អាចច្រឡំ ជាមួយផ្តៅអាចម៍មាន់ផងដែរ ដោយសារកូនស្លឹកតម្រៀបស្រដៀងគ្នា ប៉ុន្តែស្រកីស្រទប បន្លា និងកញ្ចុំផ្កាមានលក្ខណៈខុសគ្នា។ គេក៏អាចច្រឡំវាជាមួយប្រភេទផ្តៅទឹកជុំវិញបឹងទន្លេសាបផងដែរ ប៉ុន្តែផ្តៅទឹកជុំវិញបឹងទន្លេសាបមានទងស្លឹកខ្លីបំផុត បន្លាស្រទបខ្មៅ ហើយជាទូទៅមានបន្លាតូចៗនៅខាងលើទ្រនុងស្លឹកនៅក្បែរគល់កូនស្លឹក។

**លូតលាស់:** ពុំទាន់មានព័ត៌មានស្តីពីការលូតលាស់របស់ប្រភេទនេះទេ ប៉ុន្តែសហគមន៍មូលដ្ឋានបានរាយការណ៍មកថាវាត្រូវការរយៈពេលប្រហែល ៧-៩ឆ្នាំចាប់ពីកូនសំណាបរហូតដល់ដើមពេញវ័យ និងសមល្មមអាចដកហូតបាន។

**ទីតាំង:** ប្រភេទនេះភាគច្រើនមាននៅភាគខាងកើត និងទិសឥសាន្តនៃប្រទេស។

**ទីជម្រក:** នៅតាមព្រៃ ឬព្រៃគម្ពោតនៅតាមមាត់ច្រាំងស្ទឹង ឬទន្លេដែលមានទឹកជន់លិចដោយពេល ឬតាមរដូវ។ ឈ្មោះក្នុងស្រុករបស់ប្រភេទនេះគឺ អាស្រ័យលើទីជម្រករបស់វា ឧទា. នៅជាប់នឹងមាត់ទឹក។

**រយៈកម្ពស់:** ដុះនៅរយៈកម្ពស់ទាបជាង ២០០ម។

**ការប្រើប្រាស់:** សហគមន៍ប្រើដើមវាធ្វើជារនាប ឬជញ្ជាំង គ្រឿងសង្ហារឹម។ គេពុំសូវនិយមប្រើប្រភេទនេះនៅក្នុងរោងចក្រទេ ដោយសារតែវាមានគុណភាពអន់ទាំងភាពជាប់មាំ និងបត់បែន។ គមអាចហូបបានហើយច្រើនហូបនៅក្នុងប្រទេសថៃ និងឡាវ។

**ពាណិជ្ជកម្ម:** ដើមប្រវែង ៤-៥ម៉ែត្រ មានតម្លៃ ១៥០-៣០០រៀល។ អ្នករកស៊ីកាប់ផ្តៅនៅស្រុកស្នួល ខេត្តក្រចេះ បានរាយការណ៍ថាគេកាប់ដើមលក់ទៅប្រទេសវៀតណាម។ ប៉ុន្តែដើមនេះគេមិនសូវនិយមប្រើនៅក្នុងប្រទេសកម្ពុជាទេ ព្រោះរបស់វាមានគុណភាពអន់ជាងផ្តៅក្រែក និងផ្តៅឈ្វាំងដែលមានទំហំប៉ុនគ្នា។

# **Calamus siamensis** Becc.












១- ទីកន្លែងអង្កេតផ្តៅទឹក  ២- ធ្នើរសៀវភៅធ្វើពីផ្តៅទឹក

៣- ពកគល់ទងស្លឹក ស្រកីស្រទប និងការតម្រៀបបន្លា ៤- ស្លឹកដែលបង្ហាញពីការតម្រៀបកូនស្លឹក  ៥- ផ្លែ

# ១២ Calamus godefroyi Becc.

ឈ្មោះខ្មែរៈ ផ្តៅទឹក
សទិសន័យៈ មិនមាន

## ការពិពណ៌នា

**ទិដ្ឋភាពដើមៈ** ដុះជាគុម្ព ដើមតោងឡើង ប្រវែងរហូតដល់ ៥ម ។
**ស្រទបស្លឹកៈ** មុខកាត់ទំហំ ១,៥-៤សម ពណ៌បៃតងមធ្យម ។
**បន្លាស្រទបៈ** បន្លារង្វើល ដុះរាយបាយមួយៗ ឬកម្រជាប់គ្នានៅគល់ណាស់ ប្រវែងដល់ ២សម គល់រីកធំ រាងរមូល ពណ៌ទឹកក្រូច-បៃតង ខាងលើគល់ពណ៌ខ្មៅ ។
**ពកគល់ទងស្លឹកៈ** ច្បាស់ល្អ រាងពក ពណ៌ទឹកក្រូច-បៃតង អត់មានបន្លា ។
**ស្រកីស្រទបៈ** ប្រវែង ០,៦សម ពណ៌ត្នោត គ្មានរោមរឹង ។
**ដៃតោងៈ** ដៃតោងគល់ទងស្លឹក ប្រវែង ១៥០-២៥០សម ។
**ស្លឹកៈ** ប្រវែង៥០-៨០សមពីអត់មានទងស្លឹក រហូតដល់មានទងស្លឹកប្រវែង៤សម មានចង្កូររាក់ៗទ្រនុងស្លឹក ប្រវែង ៥០-៨០សម កូនស្លឹកនៅចុងស្លឹកជាប់ទ្រនុងស្លឹក ប្រវែង ០,៥-០,៨សម បន្ទាប់មកផែកជាពីរ ។ កូនស្លឹកតម្រៀបឈម មានចំនួន ២៦-៣៥នៅលើជួរនីមួយៗ ។ កូនស្លឹកនៅទ្រនុងកណ្តាលទំហំ ២២-៣០ x ១,៥-២សម រាងទ្រវែងអេលីបទិច គល់ស្ទួច តែមមានរោមរឹងៗ ចុងស្ទួចវែងបន្ទះស្លឹកខាងលើមានទ្រនុងកណ្តាលផុសឡើង បន្ទះស្លឹកទាំងសងខាងមានរោមរឹងៗ ។
**ដើមៈ** មុខកាត់ទំហំ ១-១,៣សម ចន្លោះថ្នាំងប្រវែង ១០-១៥សម មិនជាប់មាំល្អ និងទន់ ។
**កញ្ចុំផ្កាៈ** ប្រវែង ១-១,៥ម បូករួមទាំងដៃតោង កូនកញ្ចុំផ្កាតូចៗ បែកចេញពីក្នុងស្បបរបស់ទងទីមួយ ស្បទងទីមួយមានរាងជាបំពង់ ។
**ផ្លែៈ** ទំហំ ១,២ x ១,៦សម រាងស្វើរស្វែរ ទម្រគ្របកជាប់គ្នារាងជាបំពង់នៅគល់ ផែកនៅចុង ។
**គ្រាប់ៈ** មិនជ្រួញ ។

**លក្ខណៈសំគាល់ៈ** ប្រភេទនេះមានឈ្មោះក្នុងស្រុកដូចផ្តៅទឹកនៅភាគឥសាន្ត *C. siamensis* ដោយសារតែវាដុះតាមតំបន់ដីសើម ។ សូមមើលការពណ៌នារបស់ប្រភេទ *C. siamensis* ដើម្បីពិនិត្យមើលចំនុចខុសប្លែកគ្នារបស់ប្រភេទនេះ ។
**លូតលាស់ៈ** លូតលាស់បានប្រហែល ១,២-១,៦មក្នុងមួយឆ្នាំ ។
**ទីកន្លែងៈ** ដុះនៅតាមព្រៃលិចទឹកតាមរដូវកាល តាមបណ្តោយទន្លេមេគង្គ និងជុំវិញបឹងទន្លេសាប ។ បើប្រៀបធៀបទៅនឹង *C. siamensis* វាដុះនៅតាមទន្លេដែលលិចទឹកជ្រៅក្នុងរយៈពេលយូរ ។
**ទីជម្រកៈ** ព្រៃលិចទឹក ឬតំបន់វាលភក់ ។
**រយៈកម្ពស់ៈ** រយៈកម្ពស់ទាបជាង ១០០ម ។
**ការប្រើប្រាស់ៈ** សហគមន៍មូលដ្ឋានច្រើនប្រមូលដើមវាធ្វើគ្រឿងល្អី និងកន្ទេលសម្រាប់ការប្រើប្រាស់នៅមូលដ្ឋាន ។
**ពាណិជ្ជកម្មៈ** ដើមប្រវែង ៤-៥ម៉ែត្រ មានតម្លៃ ១៥០-២៥០រៀល ។ បច្ចុប្បន្ននេះ គេប្រមូលប្រភេទនេះដើម្បីត្បាញធ្វើល្អីនៅឃុំក្របីក្រាល ខេត្តសៀមរាប ។

# Calamus godefroyi Becc.
















១- ទីកន្លែងអង្កេតផ្តៅទឹក ២- ល្អីធ្វើពីផ្តៅទឹក ៣- ទិដ្ឋភាពដើម

៤- ពកគល់ទងស្លឹក ស្រកីស្ងួប និងការតម្រៀបបន្លា ៥- ស្លឹកដែលបង្ហាញពីការតម្រៀបកូនស្លឹក

## 9.2 Daemonorops Blume.

**ទិដ្ឋភាពដើម:** ដុះជាគុម្ព ដើមតោងឡើង ចេញកញ្ចុំផ្កានៅចុងដើម ផ្កាឯកភេទ ។

**បន្ទាស្រទបៈ** បន្លាញឹក ដុះចេញជាជួរ ។

**ពកគល់ទងស្លឹកៈ** មានពកគល់ទងស្លឹក ។

**ស្រកីស្រទបៈ** មានទំហំតូច ពណ៌ត្នោតចាស់ ។

**ដៃតោងៈ** ដៃតោងចុងស្លឹក ។

**ស្លឹកៈ** កូនស្លឹកតម្រៀបឈម ។

**កញ្ចុំផ្កាៈ** កញ្ចុំផ្កាឈ្មោល ឬញីស្រដៀងគ្នាពេលមើលមួយភ្លែត ។ ស្រទបក្តោបជិតកញ្ចុំផ្កាទាំងមូល បន្ទាប់មកផែកចេញផ្កា ។ ផ្កាឈ្មោលមាន៣ក្លែប ទម្រត្របកតូច រាងដូចពែង មានត្របក៣ ស្ទើរផែកនៅគល់ កេសរឈ្មោលមាន៦នៅខាងលើត្របកផ្កា កេសរញីតូចៗ ។ ផ្កាឈ្មោលអាចនៅជាមួយផ្កាញី មានប្លោកលំអងតែគ្មានលំអង ហើយឆាប់ជ្រុះ ។ ផ្កាញីធំជាងផ្កាឈ្មោល មាន៣ស្រទាប់ ទម្រត្របករាងកំបុតចុង ត្របកមានចំនួន៣ កេសរឈ្មោលមាន៦ជាប់គ្នានៅគល់ បង្កើតបានជារាងជញ្ជៀន ។

**ផ្លែៈ** បិតជិតដោយសំបកមានលក្ខណៈជាស្រកា ។ មានរង្វះកេសរឈ្មោលបី ។ គ្រាប់មានសាច់ស្តើងទៅក្រាស់ ផ្អែម ឬជូ ។

ពួកនេះមានខ្សែស្រឡាយយ៉ាងជិតជាមួយពួក*Calamus* ប៉ុន្តែស្រទបកញ្ចុំផ្កាញែកពួកទាំងពីរនេះដាច់ចេញពីគ្នា ។ ស្ទបកញ្ចុំផ្ការបសពួកនេះមានរាងដូចទូក និងប្រេះតាមបណ្តោយតែម ចំណែកស្ទបកញ្ចុំផ្ការបស់ពួក *Calamus* ជាទូទៅក្តោបទងកញ្ចុំផ្កា និងមិនជ្រុះ ។

មានប្រហែល ១១៥ប្រភេទ ដុះរាយបាយពីប្រទេសឥណ្ឌា និងប្រទេសចិន ពីខាងលិចរហូតដល់ប៉ាពួរញូគីនី ។ នៅប្រទេសកម្ពុជាមានប្រភេទតែមួយប៉ុណ្ណោះគឺ *D. jenkinsiana* ។

## ១៣ *Daemonorops jenkinsiana* (Griff.) Martius.

**ឈ្មោះខ្មែរ:** ផ្ដៅសោម

**សមិសន័យ:** *Calamus jenkinsianus* Griff., *Calamus margaritae* Hance, *Calamus nutantiflorus* Griff., *Daemonorops jenkinsiana* var. *tenasserimica* Becc., *Daemonorops margaritae* (Hance) Becc., *Daemonorops margaritae* var. *palawanica* Becc., *Daemonorops nutantiflora* (Griff.) Mart., *Daemonorops pierreana* Becc., *Daemonorops schmidtiana* Becc., *Palmijuncus jenkinsianus* (Griff.) Kuntze, *Palmijuncus margaritae* (Hance) Kuntze, *Palmijuncus nutantiflorus* (Griff.) Kuntze.

### ការពិពណ៌នា

**ទិដ្ឋភាពដើម :** ដុះជាគុម្ព ដើមតោងឡើង រហូតដល់ ៣០ម៉ែត្រ ។
**ស្រទបស្លឹក:** មុខកាត់ទំហំ ២-៦សម ពណ៌បៃតង ។
**បន្លាស្រទប:** បន្លាញីក ដុះចម្រុះគ្នាវែង-ខ្លី រហូតដល់ប្រហែល ៦សម រាងសំប៉ែត ពណ៌ត្នោតខ្ចី រហូតដល់ពណ៌ខ្មៅ គល់បៃតងខ្ចី មានសភាពទន់ ។
**ពកគល់ទងស្លឹក:** ច្បាស់ល្អ រាងពក ពណ៌បៃតង ដល់ពណ៌ត្នោត-លឿង បន្លារង្វើលមធ្យម ដល់ញីក ។
**ស្រកីស្រទប:** ប្រវែង ០,១-០,២សម ពណ៌ត្នោតចាស់ គ្មានរោមរឹង ។
**ដៃតោង:** ដៃតោងចុងស្លឹក ប្រវែង ៥០-៨០សម ។
**ស្លឹក:** ប្រវែង ១០០-២៥០សម ទងស្លឹកប្រវែង ២០-៥០សម ទ្រនុងស្លឹកប្រវែង ១៦៥-២២០សម ។ ពោះទងស្លឹកគ្មានបន្លា មានទ្រនុងកណ្ដាលផុសឡើង ខាងខ្នងទងស្លឹក និងតាមបណ្ដោយតែមមានបន្លារង្វើល បន្លាវែងបំផុតនៅគល់ទងស្លឹកប្រវែង ៤-៦សម ចុងស្លឹកមានដៃតោង ។ កូនស្លឹកតម្រៀបឈមមានចំនួន ៥០-១០០ នៅតាមជួរនីមួយៗ ។ កូនស្លឹកនៅទ្រនុងកណ្ដាល មានទំហំ ៣០-៧៥ x ១,៥-៣សម រាងទ្រវែង គល់រាងទាល តែមមានរោមរឹងៗ ចុងស្ទួចវែង ទ្រនុងកណ្ដាលផុសឡើង បន្ទះស្លឹកទាំងសងខាងមានរោមរឹងមួយៗតាមបណ្ដោយទ្រនុង ។
**ដើម:** មុខកាត់ទំហំ ០,៨-១,៨ម៉ែត្រ ចន្លោះថ្នាំងប្រវែង ១០-២៥សម ជាប់មាំល្អ ទន់ងាយបត់បែន ។
**កញ្ចុំផ្កា:** ស្បូកក្រោបជិតប្រវែង ១៧-៤០សម ស្បូកទងទីមួយរាងទូក មានបន្លារង្វើលល្មមនៅខាងខ្នង ដាច់ជ្រុះពេលផ្លែពេញវ័យ កញ្ចុំផ្កាញីបែកជាពីរទង កញ្ចុំផ្កាឈ្មោលបែកជាបួនទង ទងរាងបត់បែន ។
**ផ្លែ:** ទំហំ ១-១,៩ x ១-១,៩សម រាងមូល ទៅរាងពងក្រពើ ស្រកាសំបកពណ៌ត្នោតខ្ចី គែមពណ៌ត្នោតស្រគាំ ទម្រត្របកឆែក នៅគល់ចំពុះប្រវែង ០,២-០,៣សម ។
**គ្រាប់:** ជ្រួញ ។

**លក្ខណៈសំគាល់:** ស្បូកកញ្ចុំផ្កាដែលមានរាងដូចទូកសម្បូរដោយបន្លា គឺជាលក្ខណៈពិសេសរបស់ប្រភេទនេះ ។ វាមានរូបរាងមួយចំនួនទៀតដែរដូចជា: វត្តមានពកគល់ទងស្លឹក ដៃតោងចុងស្លឹក កូនស្លឹកតម្រៀបឈម និងបន្លាស្រទបស្លឹកពណ៌ត្នោតខ្ចីទៅពណ៌ខ្មៅ ។ បើសិនអង្កេតមួយភ្លែតវាស្រដៀងទៅនឹងផ្ដៅឯង ប៉ុន្តែផ្ដៅសោមមានស្រទបស្លឹកពណ៌ទឹកក្រូច-បៃតងខ្ចី ហើយខាងខ្នងទងស្លឹកគ្មានបន្លា ។
**លូតលាស់:** លូតលាស់បាន ០,២៦មក្នុងមួយឆ្នាំ ។
**ទីកន្លែង:** ជារួមវាដុះរាយប៉ាយច្រើនកន្លែងក្នុងប្រទេសកម្ពុជា ។
**ទីជម្រក:** វាចូលចិត្តតំបន់សើមក្នុងព្រៃពាក់កណ្ដាលស្រោង ព្រៃស្រោង និងព្រៃតាមមាត់ទឹក ។
**រយៈកម្ពស់:** ប្រហែលរយៈកម្ពស់ ៥០០ម ។
**ការប្រើប្រាស់:** គមរបស់វាអាចហូបបាន ហើយសហគមន៍មូលដ្ឋានហូបជាបន្លែ ។ (ដង្កូវ)ដូងដែលរស់ក្នុងគមរបស់វាកគេប្រមូលសម្រាប់ហូបជាអាហារ និងលក់ផងដែរ ។ ដូងមួយតម្លៃ ២០០០-៤០០០រៀល នៅផ្សារក្នុងស្រុកឬនៅភូមិ និងរហូតដល់ប្រហែល ៨០០០រៀលនៅផ្សារក្នុងក្រុង ។ ដើមរបស់វាងាយបត់បែន និងជាប់មាំល្អ ដូច្នេះគេចូលចិត្តបត់ធ្វើគ្រឿងតុបតែង គ្រឿងសង្ហារិម ។
**ពាណិជ្ជកម្ម:** គេប្រមូលវាយ៉ាងច្រើនសម្រាប់ពាណិជ្ជកម្មក្នុងស្រុក ឬអន្តរជាតិ ប៉ុន្តែបរិមាណប្រមូលមិនដឹងច្បាស់ទេ ។ ដើមប្រវែង ៤-៥ម៉ែត្រមានតម្លៃ ៣០០-៥០០រៀល ហើយតម្លៃនេះកើនដល់ ១២០០រៀលក្នុងមួយដើមបន្ទាប់ពីឆ្លង កាត់តំណាក់កាលកែច្នៃហើយ ។

# **Daemonorops jenkinsiana** (Griff.) Martius.




១- ទីកន្លែងអង្កេតផ្តៅសោម ២- ទិដ្ឋភាពដើម

៣- ពកគល់ទងស្លឹក ៤- កញ្ចុំផ្លែ និងផ្លែ ៥- ស្លឹកដែលបង្ហាញពីការតម្រៀបកូនស្លឹក

## 9.3 Korthalsia Blume.

**ទិដ្ឋភាពដើម៖** គុម្ពតូច ដល់គុម្ពធំ ដើមតោង ចេញផ្កាចុងដើម ជាញីកញ្ចាប់បែកមែកនៅលើគម្របម្លប់។
**បន្លាស្រទប៖** បន្លារង្វើល ដល់ញីកល្មម។
**ពកគល់ទងស្លឹក៖** គ្មានពកគល់ទងស្លឹក។
**ស្រកីស្រទប៖** មានលក្ខណៈជាសរសៃ ដូចសំណាញ់។
**ដៃតោង៖** មានដៃតោងចុងស្លឹក។
**ស្លឹក៖** ទងស្លឹកខ្លី កូនស្លឹកតម្រៀបរង្វើល និងនៅតាមជួរតែមួយ រាងដូចពេជ្រ គែមដាច់រយ៉ៃ បន្ទះស្លឹកមានទ្រនុងច្រើន មានសណ្ឋានផ្នត់ៗ គ្មានរោម បន្ទះស្លឹកខាងក្រោមជាញីកញ្ចាប់មានជាតិម្សៅពណ៌ប្រផេះ។
**កញ្ចុំផ្កា៖** ចេញព្រមគ្នានៅខាងចុងដើម ស្លឹករួមតូច ដើមងាប់បន្ទាប់ពីចេញផ្លែ។ កញ្ចុំផ្កាបែកទងចេញកូនដៃតោងសំយ៉ុងចុះក្រោម មានរាងជាគួរ(ជាតិកិន) ទងនីមួយៗមានស្រទបរាងតូចខ្យង ណែន ឬរលុង។ ផ្កាឯកភេទរីបជាប់ដោយស្រទប ដែលមានរោមញីកស្អេកស្កះ ទម្រត្របកមាន៣ ត្របកមាន៣ វែងជាងទម្រត្របក មានសណ្ឋានជាបំពង់ខ្លីនៅគល់ កេសរញីមាន៦ កម្រមានដល់៧ណាស់ ចេញពីលើត្របក អូវែមានស្នាកម៉ាតរាងដូចពីរ៉ាមីត និងមុត មាត់ស្តើង និងរាងពីរ៉ាមីត និងមានស្រកាសំបកតម្រៀបជាជួរ។
**ផ្លែ៖** ផ្លែមានស្នាកម៉ាត គ្របជិតដោយត្របក ស្រកាសំបកពណ៌ត្នោត តម្រៀបជាជួរបញ្ឈរណែនល្អ មានសាច់ផ្លែផ្អែម។
**គ្រាប់៖** ជ្រួញ។

មានប្រហែល ២៦ប្រភេទដែលទាំងអស់នេះដុះនៅអាស៊ីអាគ្នេយ៍ រាយប៉ាយចាប់តាំងពីភូមា និងឥណ្ឌូចិនដល់ញូគីនី។ រហូតដល់បច្ចុប្បន្ននេះ គេបានកត់ត្រាចំនួនពីរប្រភេទនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែប្រភេទមួយទៀតមិនមានលក្ខណៈច្បាស់លាស់ ហើយប្រហែលជាមិនមានលក្ខណៈខុសប្លែកពីគ្នាទេ។

វាជាប្រភេទដែលគេងាយស្គាល់បំផុតក្នុងចំណោមប្រភេទនានាតាមរយៈរូបរាងជាច្រើនដូចជា ស្រកីជា សរសៃ និងដូចសំណាញ់ និងរាងកូនស្លឹក។ កញ្ចុំផ្ការបស់វាក៏មានលក្ខណៈខុសប្លែកដាច់ស្រឡះពីពួកផ្សេងៗទៀត ដែរតែកញ្ចុំផ្កាវាគេកម្រឃើញណាស់។

# ១៤ **Korthalsia laciniosa** Martius.

***ឈ្មោះខ្មែរៈ*** ព្រះផ្ដៅ (ផ្ដៅក្រហម)

***សមិសន័យៈ*** *Calamosagus harinifolius Griff., Calamosagus laciniosus Griff., Calamosagus wallichiifolius Griff., Korthalsia andamanensis Becc., Korthalsia grandis Ridl., Korthalsia scaphigera Kurz, Korthalsia teysmannii Miq., Korthalsia wallichiifolia (Griff.) H. Wendl.*

## ការពិពណ៌នា

**ទិដ្ឋភាពដើមៈ** ដុះជាគុម្ព ដើមតោងឡើង បែកមែក មានប្រវែងរហូតដល់ប្រហែល ៨០ម៉ែត្រ។
**ស្រទបស្លឹកៈ** មុខកាត់ទំហំ ១,៥-៦សម ពណ៌បៃតងព្រលែតនៅផ្នែកកណ្ដាល។
**បន្លាស្រទបៈ** ប្រវែង ០,៧-១,២សម ដុះរាយមួយៗលើស្រទបស្លឹក ពកនៅគល់ រាងដូចម្ជុល មានសភាពរឹង គល់ពណ៌ត្នោតចាស់ ចុងពណ៌ខ្មៅ។
**ពកគល់ទងស្លឹកៈ** គ្មានពកគល់ទងស្លឹក។
**ស្រកីស្រទបៈ** ប្រវែង ១០-៣០សម មានលក្ខណៈជាសរសៃ ដូចសំណាញ់ ពណ៌ប្រផេះ មានបន្លាមួយៗ។
**ដៃតោងៈ** ដៃតោងចុងស្លឹកប្រវែង ៣៥-១៣០សម។
**ស្លឹកៈ** ប្រវែង ៧០-២៥០សម ទងស្លឹកប្រវែង ៧-៦៥សម ទ្រនុងប្រវែង ៦០-២១០សម។ ទងស្លឹកមានចង្អូររាក់ៗ ខាងខ្នងមានបន្លាមួយៗ មានជាតិម្សៅ ចុងស្លឹកមានដៃតោង។ កូនស្លឹកតម្រៀបលើជួរ តែមួយជួរនីមួយៗមានកូនស្លឹកចំនួន ៧-១០។ កូនស្លឹកនៅទ្រនុងកណ្ដាលៈ ទងកូនស្លឹកប្រវែង ១-៣សម បន្ទះស្លឹកទំហំ ១៦-៤០ x៩-២២សម គល់ស្ដួច តែមរលោង ពីត្រឹមកណ្ដាលដល់ចុងរាងដាច់រយ៉ៃ ចុងស្លឹករាងស្ដួច-ស្ដួចវែង មានទ្រនុង ៥-១៦ ច្បាស់ល្អ បន្ទះស្លឹករាងផ្នត់ អត់មានរោម បន្ទះស្លឹកខាងលើពណ៌បៃតងខ្ចីទៅបៃតងចាស់ បន្ទះស្លឹកខាងក្រោមពណ៌ប្រផេះ។
**ដើមៈ** មុខកាត់ទំហំ ១,៤-២,៥សម ពណ៌ក្រហម ជាប់មាំល្អ និងពុំសូវទន់។ ជាទូទៅគេចាត់ថ្នាក់ជាដើមមានមុខកាត់ធំ។
**កញ្ចុំផ្កាៈ** មានផ្កាញី-ឈ្មោលនៅជាមួយគ្នា មានប្រវែងរហូតដល់ ៧៥សម ត្រង់។
**ផ្លែៈ** ទំហំ ២ x ២សម រាងមូល ស្រកាសំបកពណ៌ត្នោតពេលទុំ តែមពណ៌ព្រលែត។
**គ្រាប់ៈ** ជ្រួញ។

**លក្ខណៈសំគាល់ៈ** ប្រភេទនេះ គេអាចស្គាល់តាមរយៈស្រកីស្រទបពិសេសរបស់វា កូនស្លឹកតម្រៀបមិនស្មើគ្នា រាងដូចពេជ្រ និងមានសណ្ឋានផ្នត់ និងតែមដាច់រយ៉ៃ។
**ឈ្មួញលាស់ៈ** ពុំមានព័ត៌មាន។
**ទីតាំងៈ** គេអាចឃើញគ្រប់ទីកន្លែងក្នុងប្រទេស។
**ទីជម្រកៈ** ព្រៃពាក់កណ្ដាលស្រោង ដល់ព្រៃស្រោង ដែលមានកម្ពស់ទឹកភ្លៀងខ្ពស់។
**រយៈកម្ពស់ៈ** រយៈកម្ពស់ពីកម្ពស់ទឹកសមុទ្រដល់ ៥០០ម។
**ការប្រើប្រាស់ៈ** គេប្រើប្រាស់វាធ្វើស៊ុមគ្រឿងសង្ហារឹម។
**ពាណិជ្ជកម្មៈ** គេប្រមូលវាយ៉ាងច្រើនសន្ធឹកសន្ធាប់សម្រាប់ធ្វើពាណិជ្ជកម្ម និងការនាំចេញ។ ដើមប្រវែង ៤-៥ម៉ែត្រ មានតម្លៃ ៤៥០-១០០០រៀល រហូតដល់ ១៨០០រៀល តែកម្រមានដល់តម្លៃនេះណាស់។

# Korthalsia laciniosa Martius.













១- ទីកន្លែងអង្កេតព្រះផ្តៅ

២- ទិដ្ឋភាពដើម

៣- គ្មានពកគល់ទងស្លឹក និងស្រកីស្តបរាងដូចសំណាញ់

៤- ស្លឹកដែលបង្ហាញពីការតម្រៀប កូនស្លឹក

## 9.4 **Myrialepis** Becc.

**ទិដ្ឋភាពដើម:** ដុះជាគុម្ពធំ ដើមតោងឡើង ចេញកញ្ចុំផ្កាចុងដើម ផ្កាឯកភេទ។

**បន្លាស្រទប:** បន្លាស្រទប ដុះចេញជាជួរវែង មានទម្រង់កោង។

**ពកគល់ទងស្លឹក:** គ្មានពកគល់ទងស្លឹក។

**ស្រកីស្រទប:** ទំហំតូច មិនសូវច្បាស់។

**ដៃតោង:** មានដៃតោងចុងស្លឹក។

**ស្លឹក:** មានទងស្លឹក កូនស្លឹកតម្រៀបជាក្រុម ឬជាជួរ រាងទ្រវែង-អេលីប។

**កញ្ចុំផ្កា:** កញ្ចុំផ្កាឈ្មោលតូច ទម្រត្របកផែកជាបី ទំហំតូច ត្របកមានបី កេសរឈ្មោលមាន៦ ជាប់គ្នារាងដូចពែង ជាប់ទៅនឹងត្របក កេសរញីតូច។ កញ្ចុំផ្កាញីមាំល្អ ទម្រត្របកមានបី ទំហំធំ ត្របកមានបី ទំហំធំ កេសរឈ្មោល មាន ៦ជាប់គ្នានៅគល់ ប្លោកលំអងគ្មានលម្អង អូវែរាងមូល ស្ទីកម៉ាតផែកជាបី។

**ផ្លែ:** រាងមូល ស្រកាសំបកតូច មិនតម្រៀបជាជួរ កេសរឈ្មោលមិនជាប់គ្នា។

**គ្រាប់:** មិនជ្រួញ ។

មានតែមួយប្រភេទនៅប្រទេសឡាវ កម្ពុជា វៀតណាម ថៃឡង់ ភូមា ឧបទ្វីបម៉ាឡេស៊ី និងស៊ូម៉ាត្រា។

ពួកនេះស្រដៀងគ្នាទៅនឹងពួក*Plectocomia* Beccប៉ុន្តែបន្លាស្រទប ខ្លីៗមានរោមរឹងនៅតាមគែមកូនស្លឹក ហើយផ្លែមានស្ទីកម៉ាត។ វាក៏ស្រដៀងទៅនឹង *Plectocomiopsis* Becc ប៉ុន្តែបន្លាស្រទបមិនតម្រៀបជាជួរទេ ទោះបីជាពេលខ្លះនៅក្នុងពួកនេះមានបន្លាដុះជាក្រុមតិចតួច និងមានរោមរឹងពណ៌មាសនៅលើបន្ទះកូនស្លឹកក៏ដោយ។

## ១៥ **Myrialepis paradoxa** (Kurz) . Dransf.

**ឈ្មោះខ្មែរ:** ផ្ដៅឬស្សី (ព្រែសឈើ)
**សទិសន័យ:** *Bejaudia cambodiensis* Gagnep., *Calamus paradoxus* Kurz, *Myrialepis floribunda* (Becc.) Gagnep., *Myrialepis scortechinii* Becc., *Palmijuncus paradoxus* (Kurz) Kuntze, *Plectocomiopsis annulata* Ridl., *Plectocomiopsis floribunda* Becc., *Plectocomiopsis paradoxa* (Kurz) Becc., *Plectocomiopsis scortechinii* (Becc.) Ridl.

### ការពិពណ៌នា

**ទិដ្ឋភាពដើម:** ដុះជាគុម្ព ដើមតោងឡើងប្រវែងដល់ ៣០ម៉ែត្រ។
**ស្រទបស្លឹក:** មុខកាត់ទំហំ ២-៧សម ដើមខ្ចីពណ៌បៃតងមានជាតិម្សៅពណ៌ត្នោតខ្ចី ជ្រុះអស់ពេលដើមពេញវ័យ។
**បន្លាស្រទប:** បន្លាលើដើមខ្ចីតម្រៀបដូចស្និត ខ្លី ឬវែង ចង្អុរឡើងលើ និងចុះក្រោម ប្រវែងដល់ជិត៤សម ពណ៌បៃតងលឿងខ្ចី ចុងពណ៌ត្នោតខ្ចី។ ដើមចាស់មានបន្លាខ្លី និងតម្រៀបជាជួរខ្លីៗ ស្រដៀងផ្ដៅចង្អូរដែរ។
**ពកគល់ទងស្លឹក :** គ្មានពកគល់ទងស្លឹក។
**ស្រកីស្រទប:** ប្រវែង ០,២-០,៤សម។
**ដៃតោង:** ប្រវែង ៥០-១៥០សម។
**ស្លឹក:** ប្រវែង ១០៥-២៤០សម ទងស្លឹកប្រវែង ១២-៣២សម ទ្រនុងប្រវែង ៩២-២១១សម ចុងស្លឹកមានដៃតោង ទងស្លឹកមានចង្អូរធំទូលាយ បន្ទះស្លឹកខាងលើគ្មានបន្លា បន្ទះស្លឹកខាងក្រោម និងតាមគែមស្លឹកមានបន្លា។ កូនស្លឹកនៅទ្រនុងកណ្ដាលទំហំ ៣៥-៧០ x ២-៤,៥សម គល់រាងស្ដួច ចំហៀងម្ខាងរបស់គែមស្លឹកមានឆ្នូតជាបន្ទាត់ពណ៌ត្នោត មានរោមរឹងមួយៗ ចុងរាងស្ដួចវែង ទ្រនុងកណ្ដាលផុសឡើង បន្ទះស្លឹកទាំងសងខាងគ្មានរោមរឹង បន្ទះស្លឹកខាងលើមានស្នាមអុចសៗ (អាចមើលឃើញដោយកែវពង្រីកដៃ)។
**ដើម:** មុខកាត់ទំហំ ១,២-៣សម ចន្លោះថ្នាំងប្រវែង ១២-២៧សម សាច់ក្នុងផុយ ដើមមិនសូវទន់។
**កញ្ចុំផ្កា:** ប្រវែង ០,៦-២ម ត្រង់ឡើងលើ ស្រទបទងកញ្ចុំផ្កាបិតជិត ក្ដោបយ៉ាងណែន គ្មានបន្លា កញ្ចុំផ្កាឈ្មោលបែកទងជាបី ប៉ុន្តែទងកូនកញ្ចុំផ្កាប្រវែងខ្លីជាង ៣សម កញ្ចុំផ្កាញីបែកទងជា ៣។
**ផ្លែ:** ទំហំ ២,៥ x ២,៥សម ស្រកាសំបកតូចៗ ពណ៌ប្រផេះ-បៃតង។
**គ្រាប់:** មិនជ្រួញ។

**លក្ខណះសំគាល់:** រូបរាងលេចធ្លោរបស់ប្រភេទនេះ គឺបន្លា (បន្លាចាស់-ខ្ចី តម្រៀបរាងជាស្និត) និងស្រកាសំបកតូចៗនៅជុំវិញផ្លែ។ រូបរាងសំខាន់ផ្សេងទៀត មានរោមរឹងនៅតាមគែមកូនស្លឹក និងបន្ទះកូនស្លឹកទាំងសងខាងរលោង។
**លូតលាស់:** លូតលាស់ ០,៧-១,២ម៉ែត្រ ក្នុងមួយឆ្នាំ ។
**ទីកន្លែង:** ប្រភេទនេះអាចរកឃើញនៅគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា។
**ទីជម្រក:** ទីជម្រករបស់វាមានរបាយធំ ពីព្រៃរិចរិលបំផុត ដល់ព្រៃពាក់កណ្ដាលស្រោង។
**រយះកម្ពស់:** ដុះនៅរយះកម្ពស់រហូតដល់ជិត ៣០០ម។
**ការប្រើប្រាស់:** សាច់ក្នុងដើមផុសៗ និងសំបកដើមរឹងដែលមិនអាចបត់បាន។ គេប្រើវាសម្រាប់ធ្វើស៊ុមគ្រឿងសង្ហារឹមដែលមានគុណភាពទាប (សម្រាប់ប្រើក្នុងមូលដ្ឋានតែប៉ុណ្ណោះ)។
**ពាណិជ្ជកម្ម:** នៅប៉ែកនិរតីនៃប្រទេសកម្ពុជា គេប្រមូលវាដើម្បីលក់ទៅរោងសិប្បកម្មមូលដ្ឋានដើម្បីធ្វើគ្រឿងសង្ហារឹម។ វាមិនសមស្របសម្រាប់ការនាំចេញទេ។ ដើមប្រវែង ៤-៥ម៉ែត្រ មានតម្លៃ ៦០០- ១០០០រៀល ហើយវាអាចធ្លាក់ថ្លៃដល់ ៣០០រៀល ឬថ្លៃជាង ១៣០០រៀល។

# **Myrialepis paradoxa** (Kurz) . Dransf.














១- ទីកន្លែងអង្កេតផ្តៅឫស្សី   ២- ធ្នើរសៀវភៅផលិតពីផ្តៅឫស្សី   ៣- ទិដ្ឋភាពដើម   ៦- ផ្លែ

៤- គ្មានពកគល់ទងស្លឹក បន្លាតម្រៀបដូចស្និត និងស្រកីស្រទបតូចៗ ៥- ស្លឹកបង្ហាញពីការតម្រៀបកូនស្លឹក

# 9.5 Plectocomia C. Martius. ex Blume.

**ទិដ្ឋភាពដើម:** គុម្ពតូចល្មមដល់ធំ ដើមតោងឡើងខ្ពស់ៗ ផ្កាឯកភេទ ចេញកញ្ចុំផ្កាពីចុងដើម។
**បន្ទាស្រទប:** បន្ទាតម្រៀបជាជួរខ្លី ឬវែង។
**ពកគល់ទងស្លឹក:** គ្មានពកគល់ទងស្លឹក។
**ស្រកីស្រទប:** ទំហំតូច មិនសូវច្បាស់។
**ដៃតោង:** ដៃតោងចុងស្លឹក។
**ស្លឹក:** ទងស្លឹកជួនមានជួនអត់ កូនស្លឹកតម្រៀបជាក្រុមមិនច្បាស់លាស់ មានដៃតោងនៅខាងចុង។ បន្ទះកូនស្លឹកខាងក្រោមមានជាតិម្សៅ តែមរលោង។
**កញ្ចុំផ្កា:** កញ្ចុំផ្កាឈ្មោល ឬញីស្រដៀងគ្នាពេលមើលមួយភ្លែត ចេញផ្កាព្រមគ្នាតាមថ្នាំងខាងលើបង្អស់ ស្លបក្តោបមែកទងដែលមានផ្កា និងក្តោបស្ទើរជិតទាំងស្រុង។ ផ្កាឈ្មោលមានទម្រត្របកខ្លីៗ មានផែកចុង រាងដូចធ្មេញ ត្របកមានបី គល់ស្ទើរដាច់ចេញគ្នា កេសរឈ្មោលមាន៦ ជាប់ទៅនឹងត្របកកេសរញីតូច។ ផ្កាញីមានទម្រត្របកផែកជាបីក្លែប ត្របកមានបី គល់ស្ទើរដាច់ពីគ្នា កេសរញីមានកន្ទ្បាមដែលមានស្រកាដូចសក់ និងមានស្ទីកម៉ាតបី។
**ផ្លែ:** ស្រកាសំបកតម្រៀបជារាងតូចខ្សែង ស្ទីកម៉ាតមានបី សាច់ក្រាស់។

វាស្រដៀងទៅនឹងពូក *Myrialepis* ពេលមើលមួយភ្លែត ពិសេសបន្ទាស្រទបតម្រៀបរាងដូចស្និត។ ប៉ុន្តែចំពោះពូក*Plectocomia* តែមកូនស្លឹក និងបន្ទះកូនស្លឹកទាំងសងខាងពុំមានរោមវែងៗដូចពូក *Myrialepis*។ ផ្លែរបស់ពូក *Plectocomia* មានស្រកាសំបកវែងមិនដូច*Myrialepis*ទេ។ សូមមើលផ្នែក*Plectocomiopsis* សម្រាប់ការប្រៀបធៀបរវាងពូកទាំងពីរនេះ។

ពូកនេះមានប្រហែល ១៦-១៨ប្រភេទ មានរបាយចាប់ពីតំបន់ហិម៉ាឡាយាប្រទេសចិនខាងត្បូង រហូតដល់អាស៊ីអាគ្នេយ៍។ ប្រទេសកម្ពុជាមានតែពីរប្រភេទប៉ុណ្ណោះ។

## គន្លឹះធ្វើអត្តសញ្ញាណកម្មក្នុងពួក Plectocomia

**ក១** មុខកាត់ស្រទបស្លឹកធំជាង ឬស្មើ៤សម បន្លាស្រទបតម្រៀបដូចស្និត គល់បន្លាវៀច ប្រវែងរហូតដល់៤សម ទងស្លឹកវែងជាង១០សម ស្រកាសំបកផ្លែមានសណ្ឋានជាបន្លា..........................................P. elongata

**ក២** មុខកាត់ស្រទបស្លឹកតូចជាង៤សម បន្លាស្រទបដុះរាយប៉ាយ ខ្លីជាងឬស្មើ២សម ទងស្លឹកខ្លីជាង១០សម ស្រកាសំបកផ្លែរលោង..........................................................................................P. pierreana

## ១៦ **Plectocomia elongata** Martius. & Blume

**ឈ្មោះខ្មែរ:** ផ្ដៅឬស្សីយក្ស (សហគមន៍នៅភាគខាងត្បូង និងប៉ៃលិននិរតី ក៏ហៅប្រភេទនេះថាផ្ដៅដំបងផងដែរ)
**សទិសន័យ:** *Calamus maximus* Reinw., *Plectocomia crinita* Gentil, *Plectocomia elongata* var. *bangkana* Becc., *Plectocomia griffithii* Becc., *Plectocomia hystrix* Linden, *Plectocomia ichythospinus* auct., *Plectocomia macrostachya* Kurz, *Plectocomia sumatrana* Miq., *Rotang maximus* Baill.

### ការពិពណ៌នា

**ទិដ្ឋភាពដើម:** ដុះជាគុម្ព ដើមតោងឡើងប្រវែង ៣០-៤០សម។
**ស្រទបស្លឹក:** មុខកាត់ទំហំ ៤-១០សម ពណ៌បៃតង។
**បន្លាស្រទប:** តម្រៀបជាជួរ បន្លាប្រវែងដល់ ៤សមកម្រដល់ ៤.៥សមណាស់ គល់បន្លាជាប់គ្នា ពណ៌បៃតងខ្ចី រាងដូចម្ជុល ពណ៌ត្នោតខ្ចី ចុងពណ៌ត្នោតចាស់។
**ពកគល់ទងស្លឹក:** គ្មានពកគល់ទងស្លឹក។
**ស្រកីស្រទប:** មានទំហំតូច។
**ដៃតោង:** ដៃតោងចុងស្លឹកប្រវែង ៧០-៩០សម។
**ស្លឹក:** ទងស្លឹកប្រវែង ១០-៣០សម មានចង្កូរជ្រៅ ចុងស្លឹកមានដៃតោង។ កូនស្លឹកតម្រៀបជាក្រុម ដែលម្ខាងៗមានស្លឹក ២-៣។ កូនស្លឹកនៅទ្រនុងកណ្ដាលទំហំ ៤៤-៦៥ x ៣-៤សម គល់ស្ដួច តែមគ្មានបន្លា ចុងស្ដួចវែង ទ្រនុងកណ្ដាលផុសឡើង បន្ទះស្លឹកខាងលើពណ៌បៃតងភ្លឺរលោង បន្ទះស្លឹកខាងក្រោមមានជាតិម្សៅ ពណ៌ស។
**ដើម:** មុខកាត់ទំហំ ៣-៥សម ចន្លោះថ្នាំងប្រវែង ១០-២៥សម ពុំសូវជាប់មាំល្អ និងពុំសូវងាយបត់បែន។
**កញ្ចុំផ្កា:** កញ្ចុំផ្កាបែកទងជាពីរ ទងទីមួយប្រវែង ៥៥-៦៥សម ស្នបទងទីមួយប្រវែងរហូតដល់ ១០សម ពណ៌ត្នោតចាស់ ក្ដោបជុំវិញទងកញ្ចុំផ្កា។ ស្នបទងទីពីរ តម្រៀបជាជួរឈម ទំហំ ៤-៦ x ៤-៦សម រាងដូចទូក ក្ដោបទងបន្ទាប់ដែលមានផ្កា ៣-៤ ផែកជាបន្ទះរឹងនៅពេលផ្លែពេញវ័យ។ ផ្កាឈ្មោល ឬញីស្រដៀងគ្នាពេលមើលមួយភ្លែត។
**ផ្លែ:** ទំហំ២ x ២សម រាងដូចស៊ុត ស្រកាសំបកមិនមានចង្អូរ មានរោមរឹងក្រាស់ឃ្មឹប ពណ៌ត្នោត ចុងមានចំពុះ៣ ប្រវែង ១-១.៥សម។

**លក្ខណៈសំគាល់:** ផ្ដៅឬស្សីយក្សមានរូបរាងមួយចំនួនខុសពីផ្ដៅចង្អូរ។ រូបរាងពិសេសទាំងនេះរួមមាន ដើមធំបន្លាស្រទបវែងៗ និងស្រកាសំបករបស់ផ្លែមានរោមរឹងៗ។ វាជាទិដ្ឋភាពដើមធំជាងគេនៅក្នុងប្រទេសកម្ពុជា។ នៅភាគខាងត្បូង និងប៉ៃលិននិរតី គេហៅវាថាផ្ដៅដំបង (ដោយសារតែមានដើមធំ) ដែលអាចច្រឡំនឹងប្រភេទផ្ដៅដំបង (*C. rudentum*) បើសិនជាពុំបានឃើញដើមវាពិតប្រាកដ។
**លូតលាស់:** ពុំមានព័ត៌មានអំពីអត្រាដុះលូតលាស់របស់វាទេ។
**ទីកន្លែង:** វាដុះនៅតំបន់កូនភ្នំ និងភ្នំខ្ពស់ៗដែលមានព្រៃស្រោងនៅក្នុងខេត្តកំពត កំពង់ស្ពឺ កោះកុង និងពោធិ៍សាត់ដែលមានទីតាំងនៅប៉ែកនិរតី និងប៉ែកអាគ្នេយ៍នៃប្រទេស។
**ទីជម្រក:** ដុះក្នុងព្រៃពាក់កណ្ដាលស្រោង និងព្រៃស្រោង។
**រយៈកម្ពស់:** ដុះនៅរយៈកម្ពស់ ៥០០-១១០០ម។
**ការប្រើប្រាស់:** គេកម្រប្រើដើមវាណាស់ លើកលែងតែប្រើក្នុងមូលដ្ឋានសម្រាប់ធ្វើជាស៊ុមកៅអី តុ គ្រែ ។ល។
**ពាណិជ្ជកម្ម:** សិប្បកម្មគ្រឿងសង្ហារឹមផ្ដៅនៅវាលរេញ ទិញផ្ដៅមួយដើមប្រវែង ៤-៥ម៉ែត្រ តម្លៃ១៥០០រៀល។ គេប្រមូលវាច្រើនសម្រាប់ការប្រើប្រាស់នៅក្នុងស្រុក តែមិនសម្រាប់ការនាំចេញទេ។

# **Plectocomia elongata** Martius. & Blume













១- ទីកន្លែងអង្កេតផ្តៅឬស្សីយក្ស

២- គ្មានពកគល់ទងស្លឹក និងការតម្រៀបបន្លា

៣- កញ្ចុំផ្លែ និងស្លឹកបង្ហាញពីការតម្រៀបកូនស្លឹក

៤- ផ្លែ

# ១៧ **Plectocomia pierreana** Becc.

ឈ្មោះខ្មែរ: ចង្អូរ (ព្រៃស អំបោះ ផ្តៅឬស្សីម្សៅ)
សទិសន័យ: *Plectocomia cambodiana* Gagnep.; *Plectocomia barthiana* Hodel.

## ការពិពណ៌នា

**ទម្រង់ភាពដើម:** ដុះជាគុម្ព ដើមតោងឡើងខ្ពស់ ប្រវែងដល់ ៣០ម៉ែត្រ។
**ស្រទបស្លឹក:** មុខកាត់ទំហំ ០,៥-៩សម ដើមខ្ចីពណ៌បៃតងលាយត្នោត ឬមានជាតិម្សៅពណ៌ស។
**បន្លាស្រទប:** តម្រៀបជាជួរខ្លីៗ (ឬជួនកាលវែង) បន្លាជាទូទៅប្រវែង ១-២សម ជាប់គ្នានៅគល់ គល់ពណ៌បៃតង-ត្នោតខ្ចី តួបន្លាពណ៌ទឹកក្រូចចាស់ ឬពណ៌ត្នោតខ្ចី ចុងពណ៌ខ្មៅ ចង្អុរទៅគ្រប់ទិស។
**ពកគល់ទងស្លឹក:** គ្មានពកគល់ទងស្លឹក។
**ស្រកីស្រទប:** ប្រវែង ០,២-០,៣សម ពណ៌ប្រផេះចាស់ គ្មានរោម។
**ដៃតោង:** ដៃតោងចុងស្លឹក ប្រវែង ៣០-៧០សម។
**ស្លឹក:** ប្រវែង ៥៥-៣០០សម ទងស្លឹកប្រវែង ០-៩សម មានចង្អូរ តាមគែមចង្អូរគ្មានបន្លា ខ្នងទងស្លឹកមានបន្លាមួយៗចុងស្លឹកមានដៃតោង។ កូនស្លឹកតម្រៀបជាក្រុមរង្វើល ម្ខាងៗមានកូនស្លឹក ២-៣ កូនស្លឹកនៅទ្រនុងកណ្តាលទំហំ ១៣-៥៥ x ៣-៤,៥សម រាងអេលីបទិច គល់ស្តួច គែមរលីង ចុងស្តួចវែង ទ្រនុងចេញច្បាស់ បន្ទះស្លឹកខាង លើពណ៌បៃតងរលោង បន្ទះស្លឹកខាងក្រោមមានជាតិម្សៅពណ៌ស ដែលជ្រុះបន្តិចម្តងៗទៅតាមអាយុស្លឹក។
**ដើម:** មុខកាត់ទំហំ ០,៥-៤សម ចន្លោះថ្នាំងប្រវែង ១១-២៤សម សាច់ខាងក្នុងផុយៗ ពុំសូវជាប់មាំ និងបត់បែនបានល្អ។
**កញ្ចុំផ្កា:** ប្រវែង ០,៥-១ម ទងសំយ៉ុងចុះក្រោម ប្រវែងដល់ ៧០សម ស្នបទងទីមួយរលីង សំប៉ែតបន្តិច គ្មានដៃតោង ស្នបទងទីពីរគងលើគ្នា លូតវែង គ្របលើទងតូចៗ ផ្កាឈ្មោលប្រវែង ១,៩-៤សម ផ្កាញីប្រវែង ២,៥-៤សម ផ្កាឈ្មោល និងផ្កាញីបែកជាពីរទង។
**ផ្លែ:** ទំហំ២ x ២ រាងមូល ស្រកាសំបកពេញវ័យ ពណ៌បៃតង មានគែមក្រហម។

**លក្ខណៈសំគាល់:** ខុសពីផ្តៅឬស្សីយក្ស ដូចបានរៀបរាប់ត្រង់ប្រភេទនោះ។
**ល្អតលាស់:** មិនមានព័ត៌មាន។
**ទីកន្លែង:** មាននៅតាមតំបន់ព្រៃនានាក្នុងប្រទេសកម្ពុជា។
**ទីជម្រក:** មានចាប់ពីព្រៃពាក់កណ្តាលស្រោងដែលមានការរំខាន រហូតដល់ព្រៃស្រោង។
**រយៈកម្ពស់:** រយៈកម្ពស់ទឹកសមុទ្រដល់កម្ពស់ ប្រហែល ១០០០ម។
**ការប្រើប្រាស់:** គេប្រើប្រាស់ដើមរបស់វាសម្រាប់ធ្វើជាគ្រឿងតម្បាញ និងគ្រឿងសង្ហារឹមដែលមានគុណភាពទាប។
**ពាណិជ្ជកម្ម:** ដើមប្រវែង ៤-៥ម៉ែត្រ មានតម្លៃ ១៥០-២២០រៀល។ គេប្រមូលវាសម្រាប់ការប្រើប្រាស់ក្នុងស្រុក ប៉ុន្តែមិនមែនសម្រាប់ការនាំចេញទេ។

# *Plectocomia pierreana* Becc.




១- ទីតាំងអង្កេតផ្តៅចង្អូរ ២- ប្រភេទដើម ៣-គ្មានពកគល់ទងស្លឹកការតំរៀបបន្លា និងស្រកីស្រទបតូច

៤- ស្លឹកបង្ហាញពីការតម្រៀបកូនស្លឹក ៥-ផ្លែ

# 9.6 Plectocomiopsis Becc.

**ទិដ្ឋភាពដើម:** ដុះជាគុម្ព ដើមតោងឡើង។
**បន្លាស្រទប:** បន្លាស្រទបដុះរាយប៉ាយ ជួនកាលមានបន្លា ២-៣ ជាប់គ្នានៅត្រង់គល់បង្កើតបានជាជួរខ្លីៗ។
**ពកគល់ទងស្លឹក:** គ្មានពកគល់ទងស្លឹក។
**ស្រកីស្រទប:** វែង តែពុកផុយ។
**ដៃតោង:** ដៃតោងចុងស្លឹក។
**ស្លឹក:** កូនស្លឹកតម្រៀបតាមបណ្ដោយជួរ តែមកូនស្លឹកមានរោមរឹងៗ។
**កញ្ចុំផ្កា:** ចេញព្រមគ្នាតាមថ្នាំងខាងចុងដើម។ ផ្កាឈ្មោល និងញីស្រដៀងគ្នាពេលមើលមួយភ្លែត ទងទីមួយបែកចេញជា ២-៣បន្តទៀត កូនទងមានស្រទបរាងបំពង់ និងខាងចុងរាងត្រីកោណ ដែលកូនស្រទបនីមួយៗក្តោបកញ្ចុំផ្កា ២-៧។ ផ្កាឈ្មោលមានទម្រត្របករាងជាបំពង់ ផ្នែកជាបីក្លែប រាងត្រីកោណ ជាប់គ្នានៅគល់ កេសរឈ្មោលមាន៦ ជាប់ទៅនឹងត្របក។ ផ្កាញីមានទម្រត្របករាងជាបំពង់ ផ្នែកខ្លីៗជាបីក្លែប មានចុងទាល ត្របកផ្នែកជាបីក្លែប កេសរឈ្មោលមាន៦ ជាប់ទៅនឹងស្លឹកម៉ាតតូចៗចំនួន៣ ស្លឹកម៉ាតនៅពីលើអូវ៉ែ ញែកចេញក្រៅ។ ទម្រត្របករីកធំ ផ្នែកមិនស្មើគ្នា និងជាប់ទៅនឹងផ្លែពេញវ័យ។
**ផ្លែ:** ផ្លែពេញវ័យមានស្លឹកម៉ាតតូចៗ ស្រកាសំបកតម្រៀបជាជួរបញ្ឈរមិនស្មើរគ្នា។
**គ្រាប់:** មានសាច់ស្តើង។

ពួកនេះស្រដៀងទៅនឹង *Plectocomia* ពេលមើលមួយភ្លែត។ ប៉ុន្តែពួកនេះគេអាចស្គាល់តាមរយៈរូបរាងមួយចំនួនដូចជា ស្រកីស្រទបស្តើងដូចសន្លឹកក្រដាស់ បន្លាដុះរាយប៉ាយលើស្រទបស្លឹក តែមកូនស្លឹកមានរោមរឹងៗ បន្ទះស្លឹកខាងក្រោមគ្មានជាតិម្សៅ មានស្លឹកម៉ាតតូចៗនៅលើផ្លែ។

នៅក្នុងពិភពលោកនេះមានប្រភេទចំនួន៥ ដែលមានតែនៅក្នុងអាស៊ីអាគ្នេយ៍នេះ (កម្ពុជា ឡាវ ថៃ ឧបទ្វីបម៉ាឡេស៊ី បូនីអូ និងស៊ូម៉ាត្រា)។ ប្រទេសកម្ពុជាមានតែមួយប្រភេទប៉ុណ្ណោះ។ គេមិននិយមប្រើធ្វើជាគ្រឿងតម្បាញ និងគ្រឿងសង្ហារឹមទេ ដោយសារតែដើមមានគុណភាពអន់។

## ១៨ **Plectocomiopsis** geminiflora (Griff.) Becc

ឈ្មោះខ្មែរ: ផ្តៅតាំងអោ ផ្តៅថ្ងៃ
សទិសន័យ: *Calamus geminiflorus* Griff., *Calamus turbinatus* Ridl., *Plectocomia geminiflora* (Griff.) H. Wendl., *Plectocomiopsis geminiflora* var. *billitonensis* Becc., *Plectocomiopsis geminiflora* var. *borneensis* Becc.

### ការពិពណ៌នា

**ទិដ្ឋភាពដើម:** ដុះជាគុម្ព ដើមតោងឡើង ប្រវែងដល់ ៥០ម ។
**ស្រទបស្លឹក:** មុខកាត់ទំហំ ១,៥-៦សម ពណ៌បៃតង ។
**បន្លាស្រទប:** ដុះរាយប៉ាយ រង្វើលល្មម ប្រវែង ០,៣-៣សម បន្លានៅមាត់ស្រទបប្រវែងដល់ ៤សម ស្តើងមិនរឹង ពណ៌បៃតងលាយលឿងខ្ចី ។
**ពកគល់ទងស្លឹក:** គ្មានពកគល់ទងស្លឹក ។
**ស្រកីស្រទប:** ប្រវែង ៣-១០សម ស្តើងដូចក្រដាស់ ពណ៌ប្រផេះ ស្ងួត និងពុកផុយ ។
**ដៃតោង:** ដៃតោងចុងស្លឹកប្រវែង ៧០-១២០សម ។
**ស្លឹក:** ប្រវែង ៨០-១២០សម ទងស្លឹកប្រវែង ០-១៣សម ទ្រនុងស្លឹកប្រវែង ៧០-១៦០សម ទងស្លឹកអត់មានចង្អូរ ពោះទងស្លឹកគ្មានបន្លា ខាងខ្នងទងស្លឹកមានបន្លាដុះជាជួរ ចុងស្លឹកមានបន្លា ។ កូនស្លឹកតម្រៀបលើជួរតែមួយ ម្ខាងៗមានចំនួន ១៥-៣០ ។ កូនស្លឹកនៅទ្រនុងកណ្តាលមានទំហំ ២៥-៤០ x ១,៥-៤សម រាងបន្ទាត់-អេលីបទិក គល់ស្ងួច តែមមានរោមរឹងៗ ចុងស្លួចវែង ទ្រនុងកណ្តាលផុសឡើង បន្ទះស្លឹកខាងលើមានរោមរឹងមួយៗ ពណ៌មាស បន្ទះស្លឹកខាងក្រោមគ្មានរោម ។
**ដើម:** មុខកាត់ទំហំ ១-៣សម ចន្លោះថ្នាំងប្រវែង ៨-២៧សម សាច់ក្នុងផុយៗពុំសូវរឹងមាំ និងបត់បែនបានល្អ ។
**កញ្ចុំផ្កា:** ប្រវែង ០,៤ម គ្មានដៃតោង ស្នបទងទីមួយរលីងរាបសំប៉ែត គ្មានដៃតោង ។
**ផ្លែ:** ទំហំ ៣ x ៣សម រាងមូល ខាងចុងរាងកំបុត ស្រកាសំបកពណ៌ត្នោតរាងក្រហមស្រគាំ មានគែមព្រលែត ។
**គ្រាប់:** មិនជ្រួញ ។

**លក្ខណៈសំគាល់:** រូបរាងសំខាន់ចំនួនពីរ របស់ប្រភេទនេះដូចជា បន្លាដុះរាយប៉ាយលើស្រទបស្លឹក និងវត្តមានរោមរឹងៗនៅតាមគែមកូនស្លឹក ងាយញែកដាច់ចេញពី *Plectocomia* spp ។
**កម្រិតលូតលាស់:** លូតលាស់ ១,៥-២ម៉ែត្រ ក្នុងមួយឆ្នាំ ។
**ទីកន្លែង:** មាននៅស្រុកកែវសីម៉ា ខេត្តមណ្ឌលគីរី និងឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង ។
**ទីជម្រក:** ព្រៃពាក់កណ្តាលស្រោងលាយឫស្សី និងព្រៃស្រោង ។
**រយៈកម្ពស់:** ១០០-៨០០ម ។
**ការប្រើប្រាស់:** គេមិនប្រើវាទេ ដោយសារតែវាមានគុណភាពអន់ ហើយប្រភេទដែលមានគុណភាពល្អជាងនេះនៅមានច្រើននៅឡើយ ។
**ពាណិជ្ជកម្ម:** ប្រភេទនេះពុំមានតម្លៃពាណិជ្ជកម្មក្នុងស្រុក ឬអន្តរជាតិទេ ។

# **Plectocomiopsis geminiflora** (Griff.) Becc.












១- ទីកន្លែងអង្កេតផ្ដៅតាំងអោ

២- ទិដ្ឋភាពដើម

៣- គ្មានពកកគល់ទងស្លឹក មានបន្លារាយប៉ាយ និងស្រកីតូចល្អិត

៤- ស្លឹកបង្ហាញការតម្រៀបកូនស្លឹក

# បច្ចេកសព្ទ

ចុងស្តួចវែង : ដែលរួមតូចទៅៗនៅខាងចុង។

ល្អោកលំអង : ផ្នែករបស់កេសរឈ្មោលដែលផលិតលំអង។

ស្រទប : ស្លឹកដែលមានទំហំតូចមែនទែន នៅជាប់ទៅនឹងកញ្ចុំផ្កា។

ទម្រត្របក : ផ្នែកខាងក្រៅបង្អស់ ដែលរួមជាប់គ្នា ឬនៅដាច់ៗពីគ្នា។

ដៃតោង : ដែលមានដៃតោងចុងស្លឹក។

ដៃតោងចុងស្លឹក : ផ្នែកលយចេញពីទ្រនុងស្លឹក មានដៃ ដែលមានបន្ទារាងកោង។

ដែលជាប់គ្នា : រួមគ្នាជាមួយផ្នែកស្រដៀងៗគ្នាដូចជាខ្នាយស្ទប ស្រទប ឬកេសរឈ្មោល។

ត្របក : ផ្នែកខាងក្នុងដែលអាចជាប់គ្នា ឬនៅដាច់ៗពីគ្នា។

ស្តួច : រាងស្មៀត។

ឯកភេទ : ដែលមានផ្កាឈ្មោល និងផ្កាញីនៅលើដើមខុសៗគ្នាក្នុងប្រភេទតែមួយ។

ខាងខ្នង : ផ្នែកចំហៀងរបស់សរីរាង្គដែលបែរមុខចេញពីអ័ក្ស។

ដៃតោងគល់ទងស្លឹក : កញ្ចុំផ្កាអភេទ ដែលប្រែក្លាយជាសរីរាង្គតោងឡើង។

ផ្កាចុងដើម : ចេញផ្កានៅខាងចុងបង្អស់របស់ដើមដែលការលូតលាស់របស់ដើមត្រូវបញ្ចប់ដោយកញ្ចុំផ្កា។

រោម : ដែលគ្រប់ដណ្តប់ដោយរោម ឬស្រកាសំបក។

កញ្ចុំផ្កា : ការតម្រៀបផ្កាជាច្រើននៅលើអ័ក្ស ជាចង្កោមផ្កា។

ពកគល់ទងស្លឹក : ដុំរមូលរបស់ស្រទបស្លឹក នៅជាប់ពីក្រោមទងស្លឹក។

កូនស្លឹក : ផ្នែកដែលដូចស្លឹករបស់ស្លឹកសមាស។

ស្រទបស្លឹក : ផ្នែកខាងក្រោមរបស់ទងស្លឹកដែលរុំព័ទ្ធជុំវិញដើម។

រាងដូចបន្ទាត់ : បណ្តោយវែង ហើយទទឹងតូច ដែលមានផ្នែកសងខាងស្របគ្នា។

ក្លែប : ការខ័ណ្ឌចែកផ្នែកណាមួយរបស់សរីរាង្គ ជាពិសេសបើសិនជាផ្នែកនេះរាងមូល។

តែម : ផ្នែកសងខាងរបស់ស្លឹក ឬទងស្លឹក។

ចុងទាល : រាងទាល ឬរាងមូលនៅខាងចុង។

ស្រកីស្រទប : ផ្នែកលយចេញពីស្រទបស្លឹក លូតបញ្ច្រាស់ពីស្រទបស្លឹក។

អូវែ : ផ្នែកខាងក្រោមរបស់កេសរញីដែលមានអូវុល។

ត្របក : ផ្នែកទោលរបស់កញ្ចុំត្របក។

ទងស្លឹក : ទងរបស់ស្លឹក។

កេសរញី : សរីរាង្គកេសរញីមួយ នៅក្នុងផ្កាដែលមានកេសរញីដាច់គ្នា ឬសរីរាង្គភេទញីនៅក្នុងផ្កាដែលមានកន្សោមសរីរាង្គញីជាប់គ្នា។

ផ្កាចំហៀងដើម : ដែលចេញផ្កាតាមអ័ក្ស ដែលក្នុងនោះដើមមិនងាប់។

កូនទង : មែកខាងចុងបង្អស់របស់កញ្ចុំផ្កាផ្តៅដែលមានចេញផ្កា។

ទ្រនុង : អ័ក្សរបស់កន្សោមស្លឹក ឬកញ្ចុំផ្កា។

សាច់ផ្លែ : ផ្នែកសាច់គ្របលើគ្រាប់។

ស្រកាសំបក : ភ្នាសស្តើង រឹង និងភ្លឺ ដែលព័ទ្ធជុំវិញផ្លែ។

ស្ទប : សូមមើលការពណ៌នាស្ទបស្លឹក។

ទោល : ដែលដុះលូតលាស់ ឬចេញមកតែមួយៗ។

កេសរឈ្មោល : សរីរាង្គមួយ ក្នុងចំណោមសរីរាង្គភេទឈ្មោលទាំងអស់ ជាទូទៅមាន ថង់លំអង ផ្នែកភ្ជាប់ និងបំពង់លំអង។

ស្ទីកម៉ាត : ខាងចុងរបស់បំពង់កេសរញី ដែលលំអងសំរូតចុះ និងបន្តពូជ។

# ឯកសារយោង


Dransfield, J. (1979) A manual of the Rattans of the Malay Peninsula. P271. Malayan Forest Records No. 29. Forest Department, Ministry of Industries Malaysia.

Dransfield, J. (1984) The rattans of Sabah. Sabah Forest Record No. 13. P182. Forest Department, SABAH.

Dransfield, J. and Manokaran, N. (1994) Rattans. P137. Plant Resources of South-East Asia No 6. Prosea, Bogor, Indonesia.

Dransfield, J. et al. (2000) Rattan Current research issues and prospects for sustainable development. P271. Non-Wood Forest Products.

Dy Phon, P. (2000) Dictionary of Plants Used in Cambodia. PP 119-122, 388, 451, 504. Imprimerie Olympic, Phnom Penh.

Evans, T. et al. (2001) A field Guide to the Rattans of Lao PDR. P98. Royal Botanic Gardens, Kew.

Evans, T. et al. (2002) Asynopsis of the rattans (Arecaceae: Calamoideae) of Laos and neighbouring parts of Indochina. Kew Bulletin.

Gagnepain F. and Conrarad (1937) Palmiers. PP 946-1056 in Lecomte, H. (ed.) Flore Générale de l'Indochine. Vol. 6 (parts 7) Muséum National d'Histoire Naturelle, Paris, France.

Vuthy L. and Eang Hourt K. (2006) Cambodia Rattan Status Report. PP 53. A switch to sustainable rattan harvest and production. WWF Greater Mekong Cambodia Country Programme.

## បញ្ជីប្រភេទផ្ដៅ


| បញ្ជីប្រភេទផ្ដៅ | លេខទំព័រ |
|---|---|
| Calamus lateralis | 22 |
| Calamus salicifolius | 24 |
| Calamus erinaceus | 26 |
| Calamus palustris | 28 |
| Calamus tetradactylus | 30 |
| Calamus viminalis | 32 |
| Calamus bousigonii | 34 |
| Calamus rudentum | 36 |
| Calamus sp. | 38 |
| Calamus guruba | 40 |
| Calamus siamensis | 43 |
| Calamus godefroyi | 46 |
| Daemonorops jenkinsiana | 49 |
| Korthalsia laciniosa | 52 |
| Myrialepis paradoxa | 55 |
| Plectocomia elongata | 59 |
| Plectocomia pierreana | 61 |
| Plectocomiopsis geminiflora | 64 |


## សំណាកផ្ដៅដែលបានសិក្សា

EH & V1; EH & V2; EH & V3; EH & V4; EH & V5; EH & V6; EH & V7; EH & V8; EH & V9; EH & V10; EH & V11; EH & V12; EH & V13; EH & V14; EH & V15; EH & V16; EH & V17; EH & V18; EH & V19; EH & V20; EH & V23; EH & V24; EH & V25; EH & V26; EH & V27; EH & V28; EH & V29; EH & V30; EH & V31; EH & V32; EH & V33; EH & V34; EH & V35; EH & V36; EH & V37; EH & V38; EH & V39; EH & V40; EH & V41; EH & V42; EH & V43; EH & V44; EH & V45; EH & V46; EH & V47; EH & V48; EH & V49; EH & V50; EH & V51; EH & V52; EH & V53; EH & V54; EH & V55; EH & V56; EH & V57; EH & V58; EH & V59; EH & V60; EH & V61; EH & V62; KH5; KH125; KH273; Maxwell07-130; V63; V64



ផលិតផលទាំងអស់ដែលផលិតចេញពីដើមផ្តៅ



ដើមផ្តៅដំបងដែលមានស្រទបប្រកបដោយបន្លា



ដើមផ្តៅដែលសកសំបកចេញ



ផលិតផលទាំងអស់ដែលផលិតចេញពីដើមផ្តៅ

WWF

*for a living planet®*